BIBLIOTHÈQUE
NATIONALE
DU CAMBODGE

P. K. 1

1967 _ 6

K. 213

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — *ទំព័រ*

១– បញ្ហាព្យាករណ៍ពីពុទ្ធសាសនា លោក សម-ថាំង ប្រែ-រៀបរៀង (ត) . . . ៥៦៩

២– ករណីយកិច្ចរបស់ពុទ្ធបរិស័ទ លោក ប៊ូ-ប៉ូ រៀបរៀង . . . . . . . . ៥៧៩

៣– ការគប់មិត្ត លោក ព្រួច-ភុម រៀបរៀង . . . . . . . . . . . ៦០៩

*ផ្នែកអក្សរសាស្ត្រ*

៤– ហេតុដូចម្ដេចក៏សុំឲ្យទេវតាជួយ? លោក ផេង-ត្រីវ រៀបរៀង . . . . . . . ៦២០

៥– ពិចារណាដើម្បីយល់តក្កវិជ្ជា លោក ហ៊ុន គីមសៀ រៀបរៀង (ត) . . . ៦៣០

៦– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង–ខាត់ រៀបរៀង (ត) . . . . . ៦៣៨

៧– ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឧ. ពាម ស្រាវជ្រាវ (ត) . . . . . . . ៦៤២

៨– ឯកសារ សាស្ត្រស្លឹករឹតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . . ៦៤៤

៩– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . . ៦៤៩

១០– ជីវប្រវត្តិរបស់ខ្ញុំ ឈ្មោះ អៀង-សាយ (ត) . . . . . . . . . . ៦៥៧

១១– ឯកសារកម្ពុជសុរិយា លោក ឧ.ពាម ប្រមូលរៀបរៀង (ត) . . . . . . ៦៦៧

*ផ្នែកកំណត់ និង ប្រវត្តិការណ៍*


១២– ពុទ្ធសាសនបណ្ឌិត្យ បានទទួលព្រះរាជបុត្តហ្មាយ . . . . . ៦៦៩

១៣– សកម្មភាព នៃពុទ្ធសាសនបណ្ឌិត្យ ក្នុងខែឧសភា ១៩៦៧ . . . . ៦៧៤



មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០,០០ ។

# ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ,
ឲ្យផុសខាតចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ក.ព.

## បញ្ហាព្យាករណ៍ពីពុទ្ធសាសនា

(ត)

លោក សម-ចាំង ប្រែ - រៀបរៀង

ប្ញ. គម្ពីរណា ដែលមានចារិកព្រះពុទ្ធដីកាដ៏ប្រសើរ របស់ព្រះសម្មាសម្ពុទ្ធ ?

វិ. គឺគម្ពីរ ៣ ផ្នែកដែលហៅថា ព្រះត្រៃបិដក ឬល្អី ឬកំណាត់ទ: ៣ ។

ប្ញ. គម្ពីរព្រះត្រៃបិដកនោះ មានឈ្មោះអ្វីខ្លះ ?

វិ. វិនយបិដក, សុត្តន្តបិដក និងអភិធម្មបិដក ។

ប្ញ. ក្នុងគម្ពីរទាំងនោះ មាននិយាយពីអ្វីខ្លះ ?

វិ. ក្នុងគម្ពីរវិនយបិដក ព្រះអង្គសំដែងអំពីសិក្ខាបទ សណ្តាប់ធ្នាប់ ច្បាប់របស់ព្រះសង្ឃ, ក្នុងសុត្តន្តបិដក ព្រះអង្គសំដែងអំពីនិទានរឿងរ៉ាវ ដែលនាំឲ្យកើតបញ្ញា អំពីសម្មាប្រតិបត្តិទូទៅគ្រប់គ្នាទាំងអស់,

កុងអភិធម្មបិដក ព្រះអង្គសំដែងអំពីផ្លូវបរមត្ថរបស់ព្រះពុទ្ធជាម្ចាស់ មាន ២៤ គម្ពីរ ពន្យល់អំពីចិត្ត, ចេតសិក, រូប និង និព្វាន ។

ប្ុ. ពុទ្ធសាសនិកជនទាំងឡាយ ទំងគិតស្មានថា គម្ពីរទាំងឡាយនេះ គឺវិសេសទេពណាម្នួយបានទ្រទ្រង់ទុក ឬប្រកាសប្រាប់ ឬ ?

វិ. ទេ, ដែលគេជឿគោរពដូច្នេះ មកពីក្នុងគម្ពីរទាំងនេះ មានសំដែងអំពីធម៌វិន័យ ដែលបុគ្គលរៀនសូត្រចេះចាំប្រតិបត្តិតាម ហើយអាចផ្តាច់បង់នូវសង្សារទុក្ខបាន ។

ប្ុ. នៅក្នុងផ្លូវគម្ពីរព្រះត្រៃបិដកទាំងមូលនេះ មានពាក្យប៉ុន្មានម៉ាត់?

វិ. តាមលោកបណ្ឌិតឈ្មោះ ( de DR. Rhys Davids ) រីសដាវិឌស៍ ថាមាន ១៧៥២.០០ ម៉ាត់ ។

ប្ុ. គម្ពីរទាំងនេះ លោករៀបរៀងឡើងពីកាលណា ?

វិ. ពីក្នុងរវាង ៨០ ឆ្នាំមុនគ្រិស្តសករាជ ក្នុងរាជព្រះចៅលង្កាទ្វីប ព្រះនាមវដ្តគាមិនី, ៣៣០ ឆ្នាំក្រោយព្រះពុទ្ធជាម្ចាស់បរិនិព្វាន ។

ប្ុ. គេនឹងអាចជឿបានថា ធម៌ទេសនារបស់ព្រះពុទ្ធជាម្ចាស់នៅគង់ទ្រង់មកដល់យើងទាំងអស់ ឬ ?

វិ. ទេ, ព្រោះថា ប្រហែលជារវាង ៤៥ ឆ្នាំ ដែលព្រះអង្គត្រាស់ទេសនា ព្រះអង្គបានសំដែង ជាច្រើនរយដងណាស់ហើយ

ប្រហែលត្រូវការរឹបជាន់បំផ្លាញ កាលគ្រាចម្បាំង និងសេចក្ដីផ្ដាញ់ផ្ដាល របស់សត្រូវ ធ្វើឲ្យវិនាសអស់ជាច្រើនហើយ ។

ប្ញ. ពពួកពុទ្ធមាមកៈទាំងឡាយទឹងសំគាល់ថា ព្រះពុទ្ធជាម្ចាស់ ជាបុគ្គលប្រកបព្រមដោយឥទ្ធិឫទ្ធិ និងគុណធម៌អាចជួយដោះទុក្ខទោស របស់យើងបាន ឬដូចម្ដេច ?

វិ: ពុំមែនដូច្នោះឡើយ, បុគ្គលនីមួយ ៗ ត្រូវតែរកឧបាយ ដោះទោសទុក្ខខ្លួនឯង ព្រោះត្រូវតែវិលកើតវិលស្លាប់រាប់គ្រាពុំបាន ហើយ ត្រូវជាចំណីនៃអវិជ្ជា និងជាខ្ញុំនៃតណ្ហាដរាបទាល់តែបានសម្រេចមគ្គផល ដល់នូវទីបំផុតជាតិ ។

ប្ញ. ចុះព្រះពុទ្ធជាម្ចាស់ មានឧបការគុណដូចម្ដេច ចំពោះយើង រាល់គ្នា ?

វិ. ព្រះអង្គជាព្រះអគ្គនាយក យ៉ាងចំណានវិសេសបំផុត ដែល រកឃើញផ្លូវនាំឲ្យរលាស់រួចស្រឡះចាកទុក្ខ ហើយបានបង្ហាញពន្យល់ ដល់សត្វលោក, ទ្រង់បានចង្អុលប្រាប់ហេតុដែលបង្កើតទុក្ខ ដល់សត្វលោក និងផ្លូវឯកតែមួយ, ដែលអាចឲ្យជាសះស្បើយបាន ព្រះអង្គជាមគ្គនាយក បង្ហាញផ្លូវ ត្រាស់ប្រាប់ឧបាយស្រោចស្រង់ ឲ្យចៀស វាងគ្រោះថ្នាក់ ឧបទ្រពអន្តរាយទាំងពួង ដូចបុគ្គលដែលជួយយកអាយុ ជីវិតមនុស្សម្នាក់ ដោយដឹកនាំចម្លងតាមស្ពានតូចចង្អៀតនៃជ្រោះជ្រៅមួយ យ៉ាងនោះ ។

ប្រ. បើយើងល្បងឲ្យឈ្មោះធម៌វិន័យរបស់ព្រះពុទ្ធជាម្ចាស់ជាពាក្យមួយម៉ាត់ តើទំនងជាដូចម្ដេច ទើបសម ?

វិ. ថា "យុត្តិធម៌"

ប្រ. ហេតុដូចម្ដេច ?

វិ. ព្រោះធម៌វិន័យនេះ ប្រដៅថា បុគ្គលនីមួយ ៗ ត្រូវទទួលកម្រៃផលល្អឬអាក្រក់ ដែលខ្លួនត្រូវបាន មិនលើសមិនខ្វះអំពីយថាកម្មរបស់ខ្លួន ៗ ការធ្វើល្អឬអាក្រក់ ទោះបីតិចតួចក្ដី ស្ងាត់កំបាំងក្ដី ក៏ពុំអាចគេចវៀសឲ្យផុតពីតុល្យភាពនៃកម្មឡើយ ៗ

ប្រ. កម្មនោះ ជាអ្វី ? (១)

វិ. ជាហេតុដែលគេធ្វើ ដោយមានចាក់ចងដល់មនោទ្វារ និងកាយទ្វារឬទ្វារដទៃ ៗ ពុទ្ធមាមកជនទាំងឡាយ តែងមិនពោលសរសើរចំពោះកិច្ចរបស់មនុស្ស ថាជាអស្ចារ្យទេ, បុគ្គលសាបព្រោះបែបណា ត្រូវបានផលបែបនោះវិញ ជាដាច់ខាត ៗ

ប្រ. អ្វីជាអត្តរសរបស់ព្រះពុទ្ធសាសនា ?

វិ. គឺការបណ្ដុះសេចក្ដីល្អផ្ទាល់ខ្លួន និងមេត្រីចិត្តស្នេហាសត្វលោកទូទៅ ៗ

---

១ កម្មគឺអំពើល្អអាក្រក់គ្រប់យ៉ាងនៃបុគ្គលនីមួយៗ, ព្រះធម៌ដែលសំដែងអំពីហេតុនិងផល ហៅថា បដិច្ចសមុប្បាទធម៌ មានក្នុងគម្ពីរអង្គុត្តរនិកាយ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា «សត្វលោកមានកម្មជារបស់ខ្លួន ជាកេរ្តិ៍មរតក ជាដែនកើត ជាផៅពង្ស ជាទីជ្រកប្រាស្រ័យ» ។

ប្រ. ធម៌វិន័យត្រង់ណាដែលស្ទួយតំកើងព្រះពុទ្ធសាសនា ឲ្យបានខ្ពង់ខ្ពស់ ជាងសាសនាទាំងអស់ ក្នុងលោកនេះ ?

ឆ្លើ. គឺធម៌ មេត្តា " សេចក្ដីមេត្រីរាប់អាន ", ឯពាក្យដ៏សំខាន់ជាគ្រឿងបង្ហាញឲ្យឃើញជាក់ស្ដែងនោះគឺ ( មេត្តិយ ) ដែលជានាមរបស់ព្រះពុទ្ធមួយអង្គក្នុងអនាគតកាល ។

ប្រ. គឺកាលព្រះអង្គគង់នៅក្រោមដើមពោធិព្រឹក្ស ឬ ដែលទ្រង់បានត្រាស់ដឹងនូវធម៌ដែលអ្នកទើបនឹងអធិប្បាយមកនេះឬ ?

ឆ្លើ. មែនពិតហើយ គឺព្រះអង្គពិចារណាតាមផ្លូវនេះ ដូចគេឃើញមាននៅក្នុងគម្ពីរព្រះពុទ្ធសាសនាជាច្រើនកន្លែង ។ ព្រះអង្គបានត្រាស់ដឹងនូវព្រះធម៌ទាំងពួង ដែលរាប់ថា ជាព្រះពុទ្ធសាសនា ដោយប្រពៃចំពោះព្រះអង្គក្នុងពេលនោះ ។

ប្រ. ព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅនាទីដើមពោធិព្រឹក្សចំនួនប៉ុន្មានថ្ងៃ ?

ឆ្លើ. សែសិបប្រាំបួនថ្ងៃ ។

ប្រ. ធម្មទេសនា ដែលព្រះអង្គត្រាស់សំដែងជាដំបូងបង្អស់ ចំពោះបញ្ចវគ្គិយភិក្ខុ មាននាមថាដូចម្ដេច ?

ឆ្លើ. ថា "ធម្មចក្កប្បវត្តនសូត្រ" គឺ "សូត្រដែលសំដែងពន្យល់អំពីផ្លូវប្រតិបត្តិក្នុងព្រះពុទ្ធសាសនា" ។

ប្រ. សូត្រនេះ មានសេចក្ដីអធិប្បាយដូចម្ដេចខ្លះ ?

វិ. មានអធិប្បាយអំពីអរិយសច្ចទាំង ៤ និងអដ្ឋង្គិកមគ្គ, ព្រះអង្គត្រាស់តិះដៀលការប្រព្រឹត្តរបស់ពួកតាបស ដែលជាអត្តកិលមថានុយោគ ( ធ្វើឲ្យលំបាកខ្លួនហួសប្រមាណ ) និងការស្វែងរកត្រេកត្រអាលក្នុងកាមទាំងឡាយដែលហៅថា "កាមសុខល្លិកានុយោគ", ព្រះអង្គត្រាស់សរសើរអំពីមគ្គប្រកបដោយអង្គប្រាំបី ថាជា "មជ្ឈិមាបដិបទា" គឺផ្លូវនៃសេចក្តីប្រតិបត្តិជាកណ្តាល ។

បុ. ព្រះបរមគ្រូ ទ្រង់ទទួលយល់ព្រម នូវការបូជាចំពោះទេវរូបទាំងឡាយឬទេ ?

វិ. ទេ, ព្រះអង្គបញ្ញត្តិហាមដោយដាច់ខាត ទ្រង់តិះដៀលការគោរពទេវរូប, អារក្ស, អ្នកតា និងដើមឈើជាដើម, ការគោរពជាខាងក្រៅព្រះពុទ្ធសាសនា មិននាំមកនូវសេចក្តីក្សេមឡើយ, បុគ្គលដែលបានដឹងហើយ ត្រូវតែលះបង់ ។

បុ. បើដូច្នោះ ពួកពុទ្ធសាសនិកជន មិនធ្វើការសំពះគោរពព្រះបដិមា ព្រះពុទ្ធរូប ព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ ឬស្តូបព្រះចេតិយដែលតម្កល់នូវវត្ថុទាំងនោះទេ ឬ ?

វិ. ធ្វើដែរ, ប៉ុន្តែមិនមែនសំពះដោយតាំងចិត្តគោរព ចំពោះតែរូបនោះទេ ។

បុ. ចុះខុសគ្នាដូចម្តេច ?

វិ. មនុស្សក្រៅព្រះពុទ្ធសាសនា តែងសំគាល់កាន់យកនូវរូបទាំងនេះ ថាជាតំណាងអគ្គិទេវតាឥន្ទ្រព្រហ្មទាំងឡាយ ។ អ្នកបូជាតែងកំណត់ទុកក្នុងចិត្ត ជារូបដែលខ្លួនគោរពនេះ ជាការបែងភាគនៃទេវរូបដោយជាក់ស្តែង ។

បុ. ចុះអ្នកកាន់ព្រះពុទ្ធសាសនា គិតដូចម្តេចវិញ ?

វិ. អ្នកកាន់ព្រះពុទ្ធសាសនា គោរពបូជាព្រះពុទ្ធរូបធង់វត្ថុឯទៀតនោះ គ្រាន់តែជាទីរលឹកដល់ព្រះបរមសម្មាសម្ពុទ្ធ ដែលជាមហាបុរសប្រកបព្រម ដោយសេចក្តីករុណាអាណិតសត្វក្នុងកប្បនេះ, មនុស្សគ្រប់ជាតិគ្រប់សាសន៍ ដែលថែរក្សាបូជាធាតុវត្ថុដែលគួរគោរពទាំងនោះ ព្រោះមានសេចក្តីសម្គាល់ទុកដូចជារបស់ដ៏ថ្លៃថ្លាប្រពៃ ដោយប្រការផ្សេង ៗ បុគ្គលទាំងពួងដែលបានជួបប្រទះនឹងទុក្ខលំបាក គប្បីស្រឡាញ់ហើយគោរពកោតខ្លាចព្រះបរមសម្ពុទ្ធជាងសាស្តាឯទៀត ។

បុ. ចុះព្រះអង្គបានប្រទានពុទ្ធានុញ្ញាតក្នុងរឿងនេះឬទេ ។

វិ. បានប្រទានពិតប្រាកដ, ក្នុងមហាបរិនិព្វានសូត្រ ព្រះអង្គទ្រង់ត្រាស់សំដែងថា បុគ្គលលោសះចេញចាកទុក្ខបានតែដោយការដើរតាមផ្លូវអដ្ឋង្គិកមគ្គដែលហៅថា "បដិបត្តិបូជា" ពុំមែនដោយការបូជាខាងក្រៅគឺអាមិសបូជា ឬដោយការគោរពកោតក្រែងចំពោះព្រះអង្គឬសាស្តារូបដទៃណាមួយទេ ។

ប៉ុ. ព្រះពុទ្ធជាម្ចាស់ព្រះអង្គទុកដាក់ការបូជាដូចម្ដេច ?

វិ. ព្រះអង្គតិះដៀលតាំងអំពីដំបូង នូវពិធីបូជានិងពិធីដទៃក្រៅទៀត ដែលជាហេតុនាំឲ្យងងឹតវង្វេង និងនាំឲ្យជំពាក់ចិត្តចំពោះរូបដែលគ្មានវិញ្ញាណ ។

ប៉ុ. ព្រះអង្គយល់ព្រមតាមអំពើទាំងនេះឬទេ ?

វិ. ទ្រង់ត្រាស់បដិសេធរឿងទម្លាប់នេះ ដោយធម៌ទេសនាជាច្រើនកន្លែង, ព្រះអង្គបានបញ្ញត្តសិក្ខាបទ ហាមប្រាមភិក្ខុទាំងឡាយ ដែលធ្វើឲ្យខាតពេលវេលា ដោយការពិគ្រោះជជែកគ្នាពីរឿងកិច្ចការឥតប្រយោជន៍ និងពីល្បិចឧបាយផ្លូវបរមត្ថនាំឲ្យថយកម្លាំងសតិបញ្ញា ។

ប៉ុ. មន្ត ស្នេហ៍ អាគម ជោគជ័យ ឫក្សពេលាល្អ និងការលៀងអារក្ស ទាំងនេះ មានក្នុងព្រះពុទ្ធសាសនាឬទេ ?

វិ. ទេ, ជាទំនាស់នឹងព្រះពុទ្ធសាសនាធំណាស់ គឺជាលទ្ធិដទៃខាងក្រៅទេ ។ ក្នុងព្រហ្មជាលសូត្រ ព្រះអង្គបានត្រាស់តឲ្យល់ដោយពិស្ដារអំពីការជឿលទ្ធិទាំងនេះ និងជំនឿដទៃបែបនេះថា ជាជំនឿក្រៅសាសនា ជាជំនឿដ៏ថោកទាបប្រាសចាកសេចក្ដីពិត (១) ។

---

១ សេចក្ដីច្របូកច្របល់លទ្ធិនិងទំនៀមទម្លាប់ទាំងនេះ នាំឲ្យសៅហ្មងដល់ព្រះពុទ្ធសាសនាខ្លាំងណាស់ ។ មានកិច្ចខ្លះ ជាការពិតមែនហើយ អាចនឹងពន្យល់ដោយផ្លូវវិជ្ជាសាស្ត្របាន, ការកាន់បែបនេះ កាលបើប្រព្រឹត្តធ្វើដោយអសប្បុរស អាចនិងនាំមកនូវអកុសលចិត្ត តែបើប្រើវេទមន្តនេះ ជាប្រយោជន៍ដល់អ្នកដទៃ មានការមើលជម្ងឺនិងជួយជីវិតជាដើម ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យប្រើបានខ្លះដែរ ។

ប្រ. ព្រះពុទ្ធសាសនា មានសេចក្ដីប្លែក ជាទំនាស់នឹងសាសនាឬលទ្ធិដទៃ ដូចម្ដេចខ្លះ ? ចូរអ្នកអធិប្បាយមកមើល !

វិ. ព្រះពុទ្ធសាសនាប្រដៅប្លែក អំពីសាសនាដទៃ គឺឲ្យធ្វើចិត្តសុភាពសប្បុរសបំផុត ឥតមានព្រះជាម្ចាស់សួគ៌អ្នកកសាងលោកទេ មានការយកជាតិកំណើតជាលំដាប់លំដោយ, មិនទទួលជឿលទ្ធិដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន, ពុំជឿថា មានវិញ្ញាណដទៃឋិតនៅក្រៅអំពីខ្លួនជានិច្ចនោះទេ. សេចក្ដីល្អអាក្រក់មានសម្រាប់បុគ្គលអ្នកប្រព្រឹត្តពល់រូប, ធ្វើការពិចារណាឲ្យរួចចាកទុក្ខទាំងពួង ដោយឥតមាននរណាទទួលជួស, សេចក្ដីបរិសុទ្ធិនិងមិនបរិសុទ្ធិ មានចំពោះខ្លួនឯង ៗ គ្មានពិធីបូជាបន់ស្រន់អង្វរសុំពរ ឬក៏សូមឲ្យជ្រះបាបទេ, គ្មានអ្នកដែលជួយអង្វររំដោះបាបឡើយ ។ បុគ្គលអាចបានដល់នូវព្រះនិព្វាន ក្នុងលោកនេះ និងក្នុងបច្ចុប្បន្នជាតិនេះ ដោយការចិញ្ចឹមជីវិតដ៏បរិសុទ្ធផ្លូវផង់ប្រកបព្រមដោយបញ្ញា ប្រាជ្ញាប្រយោជន៍និងសេចក្ដីសុខចំរើន ដើម្បីអ្នកដទៃផង ដើម្បីខ្លួនផង ផ្សាយមេត្តាចិត្តចំពោះសត្វទាំងអស់ ។

ប្រ. ចូរអ្នកញែកពិធីនៃវិបស្សនាធុរៈទាំងពីរប្រការ ដែលជាផ្លូវនាំឲ្យកំចាត់បង់នូវតណ្ហា ហើយដល់នូវវិជ្ជានោះមកមើល ?

វិ គឺសមថៈ និងវិបស្សនា, ដែលអាចនឹងបន្ថយនូវតណ្ហាបាន ដោយបួសជាបព្វជិត ហើយខំព្យាយាមសង្រួមនូវឥន្ទ្រិយទាំងឡាយ

ដោយយកកម្មដ្ឋានណាមួយមកជាអារម្មណ៍, ដល់ភាពជាបុគ្គលវិសេសនោះ ដោយការរំពឹងពិចារណា ។ របៀបចំរើនវិធីទាំងពីរប្រការនេះមាន ៤ យ៉ាង តែពុំបាននាំមកអធិប្បាយក្នុងទីនេះទេ ព្រោះជាការឥតប្រយោជន៍ ( បើចង់ច្បាស់សូមមើលក្នុងសមាធិនិទ្ទេស ) ។

បុ. មគ្គទាំង ៤ ប្រការ ដែលព្រះអរិយបុគ្គលបានសំរេចជាលំដាប់នោះ គឺអ្វីខ្លះ ?

វិ. ១. សោតាបត្តិមគ្គ គឺការឃើញច្បាស់នូវអរិយសច្ចទាំង ៤ ជាផ្លូវនាំទៅកាន់ព្រះនិព្វាន ។

២ - សកិទាគាមិមគ្គ ជាផ្លូវបង្ក្រាបនូវសេចក្ដីស្រើបស្រាល, សេចក្ដីព្យាបាទ និងសេចក្ដីវង្វេង ។ អ្នកបាននូវមគ្គនេះ នឹងមកកាន់ភពនេះតែមួយជាតិទៀតប៉ុណ្ណោះ ។

៣ – អនាគាមិមគ្គ ជាថ្នាក់ដែលបុគ្គលអាចឈ្នះសឹកសត្រូវ គឺកិលេសគ្រប់យ៉ាង រហូតដល់គ្មានត្រឡប់មកកាន់ភពនេះទៀតឡើយ ។

៤ – អរហត្តមគ្គ ជាថ្នាក់លោកុត្តរចិត្ត ពុំដែលគ្រាន់តែរួចផុតចាកកិរិយាកើតក្នុងភពទេ គឺដល់នូវថ្នាក់ជាន់ខ្ពស់បំផុត មានកិរិយាស្ងួតស្ងប់អស់កិលេសតណ្ហា មានមេត្តាទូទៅគ្មានទីបំផុត ចំពោះមនុស្សល្ងង់ខ្លៅក្រីក្រដល់នូវទុក្ខលំបាក គឺមានតែសេចក្ដីករុណា ស្រឡាញ់ អាណិតសត្វទាំងអស់ ឥតរើសមុខ ។

(នៅមានត)

# ករណីយកិច្ចរបស់ពុទ្ធបរិស័ទ

## ពាក្យរបស់អ្នករួបរួម

ករណីយកិច្ចរបស់ពុទ្ធបរិស័ទនេះ មិនមែនជាយោបល់ផ្ទាល់ខ្លួនរបស់ខ្ញុំអ្នករួបរួមទេ គឺជាយោបល់របស់លោកអ្នកប្រាជ្ញពុទ្ធសាសនា ដែលលោកបានរៀបចំទុកជាយូរឆ្នាំហើយ ៗ ខ្ញុំបានដកស្រង់យកចំពោះតែត្រង់គោលធម៌ជាសារៈសំខាន់បំផុតអំពីច្បាប់របស់លោកនោះ គឺច្បាប់ពុទ្ធសាសនាថៃ, ច្បាប់អរិយសច្ចកជាខ្មែរ និងច្បាប់ពោធិបក្ខិយធម៌ខ្មែរ មករួបរួមបញ្ចូលគ្នាជាសៀវភៅ ១ ក្បាលនេះ សន្មតឈ្មោះថា ករណីយកិច្ចរបស់ពុទ្ធបរិស័ទ លុះរួបរួមចប់ហើយ ខ្ញុំបានប្រគេនព្រះពុទ្ធាចារ្យ កុល-ទេស ពជាគណៈវត្តបទុមវតី សូមជួយពិនិត្យផង លោកក៏យកព្រះទ័យទុកដាក់ជួយពិនិត្យដោយហ្មត់ចត់ យល់ឃើញត្រឹមត្រូវល្អមយកជាផ្លូវប្រតិបត្តិបានហើយ ៗ

សូមលោកអ្នកប្រាជ្ញពុទ្ធសាសនាទាំងឡាយ អភ័យទោសចំពោះខ្លួនខ្ញុំ ក្រែងមានសេចក្ដីភាន់ខុសឆ្គាំឆ្គង ឬប្រើពាក្យពេចន៍មិនសមរម្យ សូមមេត្តាត្រាប្រណីជួយកែតម្រង់ឲ្យបានផង ព្រោះខ្ញុំគ្មានចេតនាប៉ុនប៉ងនឹង

បង្ខុសទេ ចង់ឲ្យតែបានត្រឹមត្រូវណាស់ ប៉ុន្តែគង់នៅមានភ្លាត់ខុសខ្លះ ជាមិនខាន ព្រោះតាមធម្មតាសតិបញ្ញារបស់ខ្ញុំជាបុថុជ្ជន នឹងចៀសវាងឲ្យផុតពីការភ្លាំងភ្លេចឬភាន់ច្រឡំមិនបានឡើយ ។

ប៊ូ ប៉ូ បុគ្គលិកក្នុងក្រុមពុទ្ធសាសនបណ្ឌិត្យ

ក្រសួងធម្មការ ក្រុងភ្នំពេញ

ព.ស. ២៤៩៨ គ.ស ១៩៥៥

# ករណីយកិច្ចរបស់ពុទ្ធបរិស័ទ

## ពាក្យបរិយាយខាងដើម

មនុស្សយើងកើតមកហើយ មិនថាអ្នកមានឬអ្នកក្រ អ្នកខ្ពង់ខ្ពស់ ឬអ្នកថោកទាបទេ សុទ្ធតែស្អប់ខ្ពើមទុក្ខ ចង់បានសុខដូចគ្នាទាំងអស់ គ្មានអ្នកណាចង់បានទុក្ខស្រឡាញ់ទុក្ខសោះ កុំថាដល់ទៅខ្លួនឯងទុក្ខ សូម្បីគ្រាន់តែពាក្យថាទុក្ខ ៗ ក៏មិនចង់ឲ្យឮផង ៗ ហេតុនេះ បានជាមនុស្សគ្រប់រូបខំគិតរកឧបាយ ដើម្បីធ្វើឲ្យខ្លួនផុតពីទុក្ខទោស ឲ្យខ្លួនបានសុខដោយវិធីផ្សេង ៗ គ្នា, អ្នកខ្លះខំធ្វើការងារចិញ្ចឹមជីវិតត្រឹមត្រូវតាមផ្លូវលោកផ្លូវធម៌ក៏មាន អ្នកខ្លះខំធ្វើការងារទុច្ចរិត ខុសផ្លូវលោកផ្លូវធម៌ក៏មាន សូម្បីនឿយហត់យ៉ាងណាក៏មិនរញ្ញាក ទាំងនេះ ក៏ព្រោះតែគេចង់ឲ្យខ្លួនបានសុខតែម្យ៉ាងប៉ុណ្ណោះ ៗ ប៉ុន្តែអ្នកស្វែងរកសុខនោះមិនមែនចេះតែបានសុខគ្រប់រូបទេ ៗ បើអ្នកណាធ្វើត្រូវតាមផ្លូវឲ្យកើតសុខ អ្នកនោះទើបបានសុខដូចចិត្តប្រាថ្នា ៗ បើអ្នកណាធ្វើខុសផ្លូវឲ្យកើតសុខ អ្នកនោះមិនបានសុខទេ ត្រឡប់ជាបានទុក្ខផ្ទុយនឹងចំណង់ខ្លួនទៅវិញ ព្រោះខ្លួនមិនដឹងដើមហេតុដែលឲ្យកើតសុខទុក្ខសោះ ៗ

តាមពិត សុខទុក្ខ ជាផលរបស់កម្ម ៗ ជាហេតុ ៗ បើកម្មល្អជាហេតុ តែងបានសុខជាផល, បើកម្មអាក្រក់ជាហេតុ តែងបានទុក្ខជាផល ៗ សុខទុក្ខនឹងកើតមានឡើងដោយសារតែខ្លួនឯងជាអ្នក

ធ្វើ អ្នកណាធ្វើល្អ អ្នកនោះបានសុខ អ្នកណាធ្វើអាក្រក់ អ្នកនោះបានទុក្ខ ៗ សុខទុក្ខនេះចែករំលែកឲ្យគ្នាមិនបានទេ បើគ្រាន់តែពន្យល់ប្រាប់ដើមហេតុឲ្យកើតសុខទុក្ខដល់គ្នាបាន ដូចជាប្រាប់គ្នាថា បើអ្នកចង់ដឹងត្រជាក់ត្រូវអ្នកងូតទឹក បើអ្នកចង់ដឹងក្តៅ ត្រូវអ្នកហាលថ្ងៃឬអាំងភ្លើងជាដើម ៗ ត្រជាក់និងក្តៅមានចំពោះតែខ្លួនអ្នកងូតទឹកឬហាលថ្ងៃប៉ុណ្ណោះ ចំណែកអ្នកប្រាប់មិនត្រជាក់ឬក្តៅទេ, សុខទុក្ខក៏ដូចជាត្រជាក់និងក្តៅនេះដែរ ៗ

លទ្ធិសាសនាទាំងពួង ដែលកើតមានឡើងក្នុងលោក ក៏កើតមកអំពីគំនិតរបស់លោកជាសាស្តានោះ ៗ គិតចៀសវាងទុក្ខទោសហើយស្វែងរកសុខតែម្យ៉ាងប៉ុណ្ណោះ ៗ ប៉ុន្តែសាសនាទាំងនោះ មានពាក្យប្រៀនប្រដៅប្លែក ៗ គ្នា ទៅតាមគំនិតយោបល់សាស្តានោះ ៗ ៗ

ចំពោះព្រះពុទ្ធសាសនា មានពាក្យប្រៀនប្រដៅ អំពីផ្លូវចៀសវាងទុក្ខទោសនិងផ្លូវធ្វើឲ្យកើតសុខ ក្នុងលោកនេះនិងលោកខាងមុខ ដោយបរិយាយដ៏ជ្រាលជ្រៅល្អិតសុខុមណាស់ ដូចកាលព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹងថ្មី ៗ ជាដំបូងបំផុត ទ្រង់ប្រដៅសាវ័កឲ្យស្គាល់ទុក្ខ, ឲ្យស្គាល់ហេតុកើតទុក្ខ, ឲ្យស្គាល់ទីរលត់ទុក្ខ និងឲ្យស្គាល់ផ្លូវប្រតិបត្តិឲ្យដល់ទីរលត់ទុក្ខ ៗ រួមន័យថា ព្រះពុទ្ធអង្គទ្រង់ប្រាប់ឲ្យស្គាល់ហេតុឲ្យកើតសុខទុក្ខមុនរឿងផ្សេង ៗ ៗ

ហេតុនេះមនុស្សគ្រប់រូបទើបត្រូវកាន់សាសនាទុកជាគោលសម្រាប់

គ្រប់គ្រងជីវិតរបស់ខ្លួនឲ្យប្រាសចាកទុក្ខ ឲ្យបានសុខស្រួលរាល់ថ្ងៃ ដូចជាកាន់ច្បាប់សម្រាប់ស្រុកទេសដែរ ។ ប៉ុន្តែ អ្នកណាកាន់សាសនាអ្វី អ្នកនោះត្រូវតែខំគិតជញ្ជឹងដោយរកហេតុផលក្នុងសាសនានោះ ឲ្យឃើញពិតប្រាកដដោយប្រាជ្ញារបស់ខ្លួន កុំចេះតែកាន់សាសនាដោយសារគេបង្ខំ, ដោយខ្លាចគេ ឬក៏ដោយអៀនខ្មាស់គេ ។

ក្នុងសៀវភៅនេះ ខ្ញុំអធិប្បាយចំពោះតែវិធីប្រតិបត្តិធម៌ក្នុងព្រះពុទ្ធ-សាសនាមួយប៉ុណ្ណោះ, សាសនាឯទៀតលើកទុក ។

សូមលោកអ្នកប្រាជ្ញពុទ្ធសាសនាជួយវិនិច្ឆ័យប្រស្នា ៥ ប្រការតទៅនេះផង :

១ ព្រះពុទ្ធអង្គជាអ្នកបង្កើតលោកឬទេ ?

២- ព្រះពុទ្ធអង្គជាអ្នកដាក់ទោសទណ្ឌកម្ម ដល់ពួកសាវ័កដែលល្មើសពុទ្ធបញ្ញត្តិឬទេ ?

៣ ព្រះពុទ្ធអង្គជាអ្នកទទួលទុក្ខទោសជួសពួកសាវ័កឬទេ ?

៤- ព្រះពុទ្ធអង្គជាអ្នកទទួលពាក្យអង្វរករបន់ស្រន់របស់ពួកសាវ័កឬទេ ?

៥- ព្រះពុទ្ធអង្គជាម្ចាស់កម្មផលមែនឬទេ ?

ប្រស្នាទាំង ៥ ប្រការនេះ សូមអស់លោកអ្នកសង្កេតមើលសេចក្តីក្នុងផ្ទៃរឿងនេះចុះ កាលបើមើលចប់ហើយ មុខជានឹងបានយល់ពាក្យឆ្លើយប្រស្នាទាំង ៥ ប្រការនោះដោយច្បាស់លាស់មិនខាន ។

# ពុទ្ធបរិស័ទ

ពាក្យ "ពុទ្ធបរិស័ទ" ចែកជា ២ បទគឺ ពុទ្ធ ១ បរិស័ទ ១ ពុទ្ធ: ជាព្រះនាមនៃព្រះសមណគោតម ដែលជាមហាក្សត្រអ្នកបង្កើតសាសនា (១) ។ បរិស័ទ ជាឈ្មោះពួកជនដែលកាន់សាសនាត្រូវគ្នា ដូចជាពួកពុទ្ធបរិស័ទ, ពួកគ្រិស្តបរិស័ទ, ពួកឥស្លាមបរិស័ទជាដើម ។ ពុទ្ធ: និង បរិស័ទ ភ្ជាប់គ្នាជា ពុទ្ធបរិស័ទ ប្រែថា "បរិស័ទរបស់ព្រះពុទ្ធ" ឬថា "ពួកជនអ្នកកាន់ពុទ្ធសាសនា គឺជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅនៃព្រះពុទ្ធ" ។ ពួកពុទ្ធបរិស័ទទាំងអស់នឹងផ្លាស់ឈ្មោះហៅថា "ពុទ្ធសាសនិកជន" ឬ "ពុទ្ធមាមក:" ឬ "ពុទ្ធសាវក" យ៉ាងនេះវិញ ក៏បាន គឺសំដៅយកពួកជនអ្នកកាន់ពុទ្ធសាសនាដូចគ្នា បើហៅឲ្យខ្លីថា "ពួកពុទ្ធសាសន៍" ។

មនុស្សដែលបាននាមថា ពុទ្ធបរិស័ទ នោះគេមិនបានកំណត់ថាជាជាតិអ្វីទេ មិនកំណត់ថា ប្រុស ឬ ស្រី ក្មេង ឬ ចាស់ទេ ឲ្យតែអ្នកណាប្រព្រឹត្តត្រឹមត្រូវតាមធម៌វិន័យរបស់ព្រះពុទ្ធហើយ អ្នកនោះក៏បាននាមថា "ពុទ្ធបរិស័ទ" ដូចគ្នាទាំងអស់ ។ ពុទ្ធបរិស័ទមាន ២ ពួក គឺគ្រហស្ថ ១ ពួក បព្វជិត ១ ពួក ។

---

១ មានសេចក្តីពិស្តារក្នុងច្បាប់ពុទ្ធប្រវត្តិ ឬគម្ពីរបឋមសម្ពោធិ ។

អ្នកដែលមានចិត្តចង់តាំងខ្លួនជាពុទ្ធបរិស័ទ ត្រូវតែសិក្សាឲ្យចេះដឹងនូវ :

# ករណីយកិច្ចរបស់ពុទ្ធបរិស័ទ

ខាងពួកគ្រហស្ថ (១) មុនដំបូងត្រូវតាំងចិត្តជឿកម្មផល និងជឿគុណព្រះរតនត្រ័យ ហើយបន្ទឹកពាក្យលាទោសរួចប្រកាសប្ដេជ្ញាខ្លួនថាជាអ្នកគោរពប់អាងកាន់ពុទ្ធសាសនា នៅចំពោះព្រះភក្ត្រព្រះពុទ្ធរូប ឬចំពោះព្រះភក្ត្រភិក្ខុ ១ រូប ២ រូបឡើងទៅ នៅទីកន្លែងណាក៏បាន ។ លុះធ្វើកិច្ចទាំង ២ យ៉ាងខាងដើមនេះស្រេចហើយ ត្រូវសមាទានសីល៥ ឬសីល ៨ និងប្រព្រឹត្តតាមធម៌វិន័យសម្រាប់គ្រហស្ថជាច្រើនប្រការទៀត ។ ពុទ្ធបរិស័ទខាងពួកគ្រហស្ថ បើប្រុសហៅ ''ឧបាសក'' បើស្រីហៅ ''ឧបាសិកា'' គឺអ្នកតាំងចិត្តយកព្រះរតនត្រ័យជាទីពឹងជាទីរលឹក ។

ករណីយកិច្ចខាងពួកបព្វជិត(២) មុនដំបូង អ្នកដែលចង់បួស ត្រូវចូលទៅរកលោកគ្រូអាចារ្យ ឬព្រះឧបជ្ឈាយ៍ សូមរៀនសូត្រធម៌វិន័យសម្រាប់អ្នកបួស, បានចេះដឹងល្មមគួរហើយ ក៏រកត្រៃចីវរបរិក្ខារសម្រាប់អ្នកបួស, លុះរកបានសព្វគ្រប់ហើយ ចូលទៅសូមបួសក្នុងសំណាក់លោកគ្រូអាចារ្យ, កាលបួសរួចហើយបើប្រុសហៅ " សាមណេរ " ឬ " ភិក្ខុ " បើស្រីហៅ ''សាមណេរី'' ឬ " ភិក្ខុនី " ។

---

១ ករណីយកិច្ចខាងគ្រហស្ថ មានសេចក្ដីពិស្ដារក្នុងច្បាប់ឧបោសថកថា ឬគិហិបដិបត្តិ ។

២ ករណីយកិច្ចខាងអ្នកបួសមានសេចក្ដីពិស្ដារក្នុងច្បាប់បុព្វសិក្ខាឬវិនយវណ្ណនាឬបព្វជ្ជាខន្ធក។

អ្នកដែលបាននាមបញ្ញត្តិថា ជា “ ពុទ្ធបរិស័ទ ” ហើយ គួរណាស់តែខំសិក្សារឿងរ៉ាវ នៃព្រះពុទ្ធជាម្ចាស់យ៉ាងល្អិតតទៅទៀតដើម្បីឲ្យបានយល់ច្បាស់លាស់អំពី ៖

## ដើមកំណើតនៃព្រះពុទ្ធជាអ្នកបង្កើតសាសនា

ព្រះពុទ្ធជាបរមគ្រូនៃយើង ជាមនុស្សអស្ចារ្យ ទ្រង់សម្ភពក្នុងសក្យ-ត្រកូល ព្រះជាតិជាក្សត្រ បានឡើងសោយរាជសម្បត្តិក្នុងព្រះជន្ម ១៦ វស្សា ទ្រង់ពិចារណាឃើញសេចក្ដីទុក្ខព្រួយរបស់ព្រះអង្គនិងមនុស្សសត្វផងទៃ ទើបលះបង់ចោលរាជសម្បត្តិចេញ ទ្រង់ព្រះផ្នួសក្នុងព្រះជន្ម ២៩ ឆ្នាំ គង់ក្នុងព្រៃខំត្រិះរិះរកធម៌ជាគ្រឿងរំលត់ទុក្ខព្រួយនោះ, ក្នុងព្រះជន្ម ៣៥ ឆ្នាំ មានព្រះនាមថ្មីថា “ ពុទ្ធៈ មានព្រះនាមតាម ព្រះគោត្រថា “ ព្រះពុទ្ធសមណគោតម ” ឬ “ ព្រះពុទ្ធសក្យមុនីគោតម ” ព្រះអង្គបរិនិព្វានក្នុងព្រះជន្ម ៨០ គត់ (១) ។

ពួកពុទ្ធបរិស័ទ កាលបើបានចេះដឹងរឿងរ៉ាវនៃព្រះពុទ្ធហើយ ត្រូវតែសិក្សាឲ្យយល់ច្បាស់លាស់អំពី ៖

## រូបរាងរបស់ពុទ្ធសាសនា

ពាក្យថា “ ពុទ្ធសាសនា ” ចែកជា ២ បទ គឺពុទ្ធៈ ១ សាសនា ១ ។ ពុទ្ធៈ ជាព្រះនាមនៃព្រះបរមសាស្ដាអ្នកផ្ដើម

១ រឿងរ៉ាវនៃព្រះពុទ្ធមានសេចក្ដីពិស្ដារក្នុងច្បាប់ពុទ្ធប្រវត្តិ ឬក្នុងគម្ពីរបឋមសម្ពោធិ ។

បង្កើតសាសនា ដូចថាមកហើយ ។ សាសនា ប្រែថា "ពាក្យប្រៀនប្រដៅ" រួមចូលគ្នាថា ពុទ្ធសាសនា ប្រែថា "ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ" ។

ពាក្យប្រៀនប្រដៅទាំងអស់ ដែលព្រះបរមសាស្ដាទ្រង់ត្រាស់ទេសនាទូន្មានពួកពុទ្ធបរិស័ទ តាំងពីបានត្រាស់ដឹងជាព្រះពុទ្ធរហូតដល់បរិនិព្វាន ក្នុងកំឡុង ៤៥ ឆ្នាំ សូម្បីព្រះអង្គសំដែងបែកខ្ញែកទៅជាប៉ុន្មានផ្នែកក៏ដោយ ក៏គង់តែហៅដោយសរុបថា "ពុទ្ធសាសនា" តែម្យ៉ាងប៉ុណ្ណោះ សឹងមានជាប់រហូតមកដល់សព្វថ្ងៃនេះ ពប់ថា "រូបកាយរបស់ពុទ្ធសាសនា" កើតមកបានអាយុ ២៤៩៨ ឆ្នាំ ហើយ ( គិតត្រឹមឆ្នាំដែលបោះពុម្ពសៀវភៅនេះ ( គ.ស. ១.៩៥៥ ) ។

ពុទ្ធបរិស័ទ កាលបើបានស្គាល់រូបកាយរបស់ពុទ្ធសាសនាហើយ ត្រូវតែត្រិះរិះដេញដោលរកនូវ ៖

## វត្ថុបំណងរបស់ពុទ្ធសាសនា

ព្រះពុទ្ធសាសនាទាំងមូល ទោះបីព្រះបរមសាស្ដាទ្រង់ត្រាស់ទេសនាទូន្មានពួកពុទ្ធបរិស័ទ ដោយព្រះវិនយបិដកក្តី ព្រះសុត្តន្តបិដកក្តី ព្រះអភិធម្មបិដកក្តី ក៏មានវត្ថុបំណងតែមួយ គឺទ្រង់ដឹកនាំពួកពុទ្ធបរិស័ទឲ្យប្រតិបត្តិឈមមុខទៅរកព្រះនិព្វាន ដែលជាទីរលត់ទុក្ខតែម្យ៉ាងប៉ុណ្ណោះ ។

ប៉ុន្តែ មានន័យថាអនេកប្រការ (១) ដែលព្រះអង្គដឹកនាំពួកពុទ្ធបរិស័ទឲ្យប្រតិបត្តិយកផលប្រយោជន៍នៅខាងលោកិយ ដែលជាអ្នកមិនទាន់បានដល់ព្រះនិព្វាន ដូចជាព្រះអង្គត្រាស់ប្រាប់ប្រយោជន៍ ៣ យ៉ាង គឺ ប្រយោជន៍ ក្នុងជាតិនេះ ១ ក្នុងជាតិខាងមុខ ១ និងប្រយោជន៍ប្រសើរបំផុតគឺព្រះនិព្វាន ១ ។

ពួកពុទ្ធបរិស័ទ កាលបើបានយល់ច្បាស់នូវគោលបំណងរបស់ពុទ្ធសាសនាហើយ ត្រូវតែខំពិចារណាឲ្យល្អិតជ្រាលជ្រៅស្រាវជ្រាវរកនូវ ៖

## គោលធម៌យ៉ាងសំខាន់បំផុតរបស់ពុទ្ធសាសនា

ព្រះពុទ្ធសាសនាទាំងមូល មានចតុរារិយសច្ច (របស់ពិតដ៏ប្រសើរ ៤ យ៉ាង) ជាកំពូល, ធម៌គ្រប់យ៉ាងសុទ្ធតែសង្គ្រោះរួមចុះក្នុងវង់ចតុរារិយសច្ចទាំងអស់ ។ សេចក្តីប្រតិបត្តិគ្រប់បែបដែលមានប្រាកដក្នុងគម្ពីរទាំងឡាយ ក៏តែងកើតមានឡើង ដើម្បីសេចក្តីចេះដឹងនូវចតុរារិយសច្ចដោយប្រាជ្ញា, ចតុរារិយសច្ច ជាកំពូលធម៌, ការចេះដឹងចតុរារិយសច្ច ជាកំពូលនៃព្រហ្មចរិយៈ, ការប្រតិបត្តិដើម្បីឲ្យត្រាស់ដឹងនូវចតុរារិយសច្ចដោយប្រាជ្ញា ជាកំពូលនៃការប្រតិបត្តិទាំងមូល ។

## ចតុរារិយសច្ច

ពាក្យថា " ចតុរារិយសច្ច " ប្រែថា " របស់ពិតដ៏ប្រសើរមាន ៤ យ៉ាង " គឺ

---

១ មានសេចក្តីពិស្តារក្នុងច្បាប់សិង្គាលោវាទសូត្រ ។

១ ទុក្ខអរិយសច្ច របស់ពិតដ៏ប្រសើរ គឺទុក្ខ ។

២ សមុទយអរិយសច្ច របស់ពិតដ៏ប្រសើរ គឺហេតុប្រជុំកើតឡើងនៃទុក្ខ ។

៣ និរោធអរិយសច្ច របស់ពិតដ៏ប្រសើរ គឺធម៌រលត់ទុក្ខ ។

៤ មគ្គអរិយសច្ច របស់ពិតដ៏ប្រសើរ គឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

## សេចក្ដីអធិប្បាយអំពីអរិយសច្ច ដោយសង្ខេប[១]

១ ទុក្ខអរិយសច្ច ពោលដោយខ្លី សំដៅយកខុបាទានក្ខន្ធទាំង ៥ គឺ សេចក្ដីប្រកាន់មាំថា រូប ១ វេទនា ១ សញ្ញា ១ សង្ខារ ១ វិញ្ញាណ ១ ជារបស់ខ្លួន ។

២ សមុទយអរិយសច្ច សំដៅយកតណ្ហា, តណ្ហា ប្រែថា "សេចក្ដីប្រាថ្នា" ។ តណ្ហានេះ ជាដើមហេតុធ្វើឲ្យមនុស្សសត្វកើតហើយស្លាប់ ។ ហើយកើតទៀត មិនចេះផុត, ធ្វើឲ្យមនុស្សជាបុថុជ្ជន គឺឲ្យជាអ្នកក្រាស់ដោយកិលេស ។ មនុស្សដែលនៅមានតណ្ហាសេចក្ដីប្រាថ្នា ដរាបណា ក៏មិនដល់នូវទីរលត់ទុក្ខ ដរាបនោះ ប្រៀបដូចជាដៅមានភ្លើងគឺហេតុ ដរាបណា ផលគឺការក្ដៅ ក៏នៅមាន ដរាបនោះ ។ តណ្ហាមាន ៣ គឺ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។

---

១ មានសេចក្ដីពិស្ដារក្នុងច្បាប់អរិយសច្ចកថា ខ្មែរនិងសៀម ។

៣ និរោធអរិយសច្ច សំដៅយកការរលត់តណ្ហាអស់គឺបាន ដល់ព្រះនិព្វាន ។

៤ មគ្គអរិយសច្ច សំដៅយកមគ្គមានអង្គ ៨ ( អដ្ឋង្គិកមគ្គ) ជាផ្លូវប្រតិបត្តិឲ្យបានដល់នូវរំលត់ទុក្ខគឺព្រះនិព្វាន ។

## ហេតុផលរបស់អរិយសច្ច

ទុក្ខ ជាផលរបស់ សមុទយៈ ។ ជាហេតុរបស់ ទុក្ខ ។ និរោធ ជាផលរបស់ មគ្គ ។ ជាហេតុរបស់ និរោធ ។

## កិច្ចដែលត្រូវធ្វើក្នុងអរិយសច្ច មាន ៤ (១)

១ ទុក្ខ ជាបរិញ្ញាតព្វកិច្ច គឺត្រូវកំណត់ដឹង ។

២ សមុទយៈ ជាបហាតព្វកិច្ច គឺត្រូវលះបង់ចេញ ។

៣ និរោធ ជាសច្ឆិកាតព្វកិច្ច គឺត្រូវធ្វើឲ្យជាក់ច្បាស់ ។

៤ មគ្គ ជាភាវេតព្វកិច្ច គឺត្រូវធ្វើឲ្យកើតមានឡើង ។

កិច្ចក្នុងអរិយសច្ចទាំង ៤ នេះ រួមឲ្យខ្លីមក នៅតែត្រឹម ២ យ៉ាង គឺ លះបង់សមុទយៈ ១ ចំរើនមគ្គ ១ ។

## បរិវដ្តក្នុងអរិយសច្ច

បរិវដ្ត ប្រែថា « ញាណជាគ្រឿងវិលទៅ » សំដៅយក ញាណទាំង ៣ គឺសច្ចញ្ញាណ ១ កិច្ចញ្ញាណ ១ កតញ្ញាណ ១ ។

---

១ កិច្ច ៤ នេះ គុណនឹងមគ្គ ៤ ទៅជា ១៦ ហៅថា សោឡសកិច្ច ។

១– ប្រាជ្ញាដឹងថា នេះទុក្ខ, នេះហេតុឲ្យកើតទុក្ខ, នេះសេចក្តីរលត់ទុក្ខ, នេះផ្លូវឲ្យដល់នូវសេចក្តីរលត់ទុក្ខ ហៅថា សច្ចញ្ញាណ ប្រែថា ប្រាជ្ញាដឹងរបស់ពិត ។

២– ប្រាជ្ញាដឹងថា ទុក្ខនេះគួរកំណត់ដឹង, សមុទយៈនេះគួរលះបង់, និរោធនេះគួរធ្វើឲ្យច្បាស់, មគ្គនេះគួរធ្វើឲ្យកើតមាន ហៅថា កិច្ចញ្ញាណ ប្រែថា ប្រាជ្ញាដឹងកិច្ចដែលគួរធ្វើ ។

៣– ប្រាជ្ញាដឹងថា ទុក្ខនេះអាត្មាកំណត់ដឹងហើយ, សមុទយៈនេះអាត្មាលះបង់ហើយ, និរោធនេះអាត្មាធ្វើឲ្យច្បាស់ហើយ, មគ្គនេះអាត្មាធ្វើឲ្យកើតមានហើយ ហៅថា កតញ្ញាណ ប្រែថា ប្រាជ្ញាដឹងកិច្ចដែលធ្វើស្រេចហើយ ។

ញាណទាំង ៣ នេះ ប្រព្រឹត្តទៅក្នុងអរិយសច្ចទាំង ៤ ត្រូវជាអាការៈ ១២ ( ៤ × ៣ = ១២ ) ។

## អត្ថក្នុងអរិយសច្ច ១៦

### ទុក្ខ មានអត្ថ ៤

១– បីឡនត្ថៈ ប្រែថា បៀតបៀន,

២– សង្ខតត្ថៈ " ត្រូវបច្ច័យប្រជុំតាក់តែង,

៣– សន្តាបត្ថៈ " ក្តៅក្រហាយ,

៤– វិបរិណាមត្ថៈ " ប្រែប្រួល ។

សមុទយៈ មានអត្ថ ៤

១ អាយុហនត្ថៈ ប្រែថា ឲ្យកើតកងទុក្ខ

២ និទានត្ថៈ " ជាហេតុនៃទុក្ខ,

៣ សំយោគត្ថៈ " ប្រកបសត្វទុកក្នុងសង្សារទុក្ខ,

៤ បលិពោធត្ថៈ " ឃុំឃាំងសត្វទុកក្នុងគុកគឺសង្សារទុក្ខ ។

និរោធ មានអត្ថ ៤

១ និស្សរណត្ថៈ ប្រែថា ជួយឲ្យចេញចាកឧបធិ (កិលេស),

២ វិវេកត្ថៈ(១) " ស្ងាត់ចាកកិលេស,

៣ អសង្ខតត្ថៈ " បច្ច័យតាក់តែងមិនបាន,

៤ អមតត្ថៈ " ជាអម្រឹតរស (មិនចេះស្លាប់) ។

មគ្គ មានអត្ថ ៤

១ និយ្យានត្ថៈ ប្រែថា បញ្ជូនសត្វចេញចាកវដ្តសង្សារ,

២ ហេតុត្ថៈ " ជាហេតុនៃព្រះនិព្វាន,

៣ ទស្សនត្ថៈ(២) " ឃើញព្រះនិព្វាន,

៤ អធិបតេយ្យត្ថៈ " ជាអធិបតីក្នុងវិមុត្តិញាណទស្សនៈ ។

ពួកពុទ្ធបរិស័ទ កាលបើបានយល់ច្បាស់ថា ចតុរារិយសច្ច ជា

---

១ ច្បាប់អរិយសច្ចកថា ថា អបលិពោធត្ថោ មានអត្ថថា រកកង្វល់រវល់មិនបាន ។

២ ក្នុងច្បាប់អរិយសច្ចកថា ថា ទិស្សនត្ថោ អធិប្បាយថា សំដែងចេញ ។

គោលធម៌យ៉ាងសំខាន់បំផុតរបស់ពុទ្ធសាសនាហើយ ត្រូវតែត្រិះរិះរើសរកផ្លូវប្រតិបត្តិឲ្យឃើញថាផ្លូវណាជា ៖

## គោលនៃការប្រតិបត្តិធម៌យ៉ាងប្រសើរ
## បំផុតក្នុងពុទ្ធសាសនា

កាលពីជំនាន់បូរាណ ដែលមិនទាន់មានព្រះពុទ្ធជាម្ចាស់ក្នុងលោក បណ្ដាមនុស្សទាំងអស់ដែលធ្លាប់ស្គាល់សុខទុក្ខមកហើយ គេតែងស្អប់ខ្ពើមទុក្ខណាស់ មិនចង់បានទុក្ខសោះ ស្រឡាញ់តែសុខ ចង់បានតែសុខម្យ៉ាងប៉ុណ្ណោះ, ម្ល៉ោះហើយក៏កើតគំនិតរិះគិតរកផ្លូវប្រតិបត្តិ ដើម្បីចៀសវាងឲ្យផុតពីទុក្ខ ធ្វើឲ្យកើតសុខដល់ខ្លួន ៗ ប៉ុន្តែ ប្រតិបត្តិមិនត្រូវត្រង់ផ្លូវរំលត់ទុក្ខ ក៏គ្រាន់តែបានស្រាកស្រាន្តស្ងប់ទុក្ខក្នុងកាលខ្លះ, លុះអស់អំណាចកម្លាំងធម៌នោះហើយ ក៏ត្រឡប់ជាកើតទុក្ខឡើងវិញដដែល ទទួលសោយទុក្ខអស់កាលវែងឆ្ងាយតៗទៅមុខទៀត មិនរួចផុតព្រោះតែមិនបានដឹងនូវអរិយសច្ច ៤ ដូចជាអាឡារតាបស និងឧទកតាបស ចំរើនឈានឲ្យបានផលទៅកើតនៅនាស្ថានព្រហ្ម ដោយសំគាល់ខុសថា ស្ថានព្រហ្ម ជាទីបំផុតទុក្ខ ជាទីរលត់ទុក្ខ ៗ ព្រះពុទ្ធជាម្ចាស់នៃយើង កាលព្រះអង្គកំពុងតែស្វែងរកធម៌ជាគ្រឿងរំលត់ទុក្ខ មុនបានត្រាស់ដឹងជាព្រះពុទ្ធ ទ្រង់ធ្លាប់បានចូលទៅនៅសិក្សាលទ្ធិធម៌ ក្នុងសំណាក់តាបសទាំង ២ រូបនោះដែរ ប៉ុន្តែ ទ្រង់ជ្រាបថា

ធម៌នេះមិនមែនជាផ្លូវប្រតិបត្តិឲ្យផុតទុក្ខទេ ទើបទ្រង់យាងចេញពីសំណាក់តាបសទាំង ២ រូបនេះ ទៅស្វែងរកផ្លូវប្រតិបត្តិដោយវិធីផ្សេងៗទៀត ។

កាលដែលព្រះបរមសាស្ដាបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធថ្មីៗ ផុតពី ៤៩ ថ្ងៃមក ព្រះអង្គទ្រង់ត្រាស់ទេសនាព្រះធម្មចក្កប្បវត្តនសូត្រ ( អរិយសច្ច ៤ ) និងអនត្តលក្ខណសូត្រ ( ព្រះត្រៃលក្សណ៍ ) មុនដំបូងទាំងអស់ ប្រោសភិក្ខុបញ្ចវគ្គីយ៍ ( ភិក្ខុ ៥ រូប ) មុនពុទ្ធបរិស័ទទាំងពួង នៅនាព្រៃឥសិបតនមិគទាយវ័នក្បែរក្រុងពារាណសី ។

សេចក្តីខាងដើមនៃព្រះធម្មចក្កប្បវត្តនសូត្រនោះ ទ្រង់ត្រាស់ប្រារព្ធអំពីផ្លូវប្រតិបត្តិ ៣ ប្រការថា ម្នាលភិក្ខុទាំងឡាយ! ផ្លូវប្រតិបត្តិ ១ ធូរថយពេក ហៅ " កាមសុខល្លិកានុយោគ " ប្រែថា " ការប្រកបខ្លួនឲ្យទទឹកជោកទៅដោយសេចក្តីសុខក្នុងកាម " , ផ្លូវប្រតិបត្តិ ១ ទៀតតឹងរឹងហួសពេក ហៅ " អត្តកិលមថានុយោគ " ប្រែថា " ការប្រកបខ្លួនទុកក្នុងសេចក្តីលំបាក " សំដៅយកការប្រតិបត្តិ ដែលពួកជនខ្លះខំព្យាយាមធ្វើទារុណខ្លួនដោយវិធីផ្សេងៗ មានអាំងភ្លើង, ហាលថ្ងៃជាដើម ដើម្បីឲ្យផុតពីទុក្ខព្រួយ និងដើម្បីឲ្យបានសម្រេចដូចសេចក្តីប្រាថ្នា ។ ផ្លូវធូរពេក និងផ្លូវតឹងពេក ទាំង ២ ប្រការនេះ តថាគតបានប្រតិបត្តិរួចមកហើយ ដឹងថាជាផ្លូវឥតផលប្រយោជន៍ ជាផ្លូវអាក្រក់លាមក ថោកទាប, អ្នកទាំងឡាយ មិនត្រូវប្រតិបត្តិតាមផ្លូវទាំង ២ យ៉ាងនេះទេ ។

ម្នាលភិក្ខុទាំងឡាយ នៅមានផ្លូវប្រតិបត្តិ ១ ទៀត ជាផ្លូវប្រតិបត្តិយ៉ាងកណ្ដាល មិនធូរពេក មិនតឹងពេក ជាផ្លូវប្រតិបត្តិឲ្យដល់នូវទីរលត់ទុក្ខពិតប្រាកដ ជាផ្លូវដ៏ប្រសើរ មានអង្គ ៨ ( អដ្ឋង្គិកមគ្គ ) ជាផ្លូវដែលតថាគតបានប្រតិបត្តិរួចមកហើយ, តថាគតបានត្រាស់ដឹងនូវអរិយសច្ច ៤ ( របស់ពិតដ៏ប្រសើរ ៤ យ៉ាង ) ដោយសារតែផ្លូវនេះឯង, អ្នកទាំងឡាយ ត្រូវតែប្រតិបត្តិតាមផ្លូវកណ្ដាលនេះចុះ ដែលជាផ្លូវមានឈ្មោះថា មជ្ឈិមាបដិបទា ប្រែថា " សេចក្ដីប្រតិបត្តិជាយ៉ាងកណ្ដាល " សំដៅយកការធ្វើដំណើរទៅតាមគន្លងផ្លូវយ៉ាងកណ្ដាល ជាផ្លូវទៅកាន់ទីរលត់ទុក្ខ ។

ផ្លូវកណ្ដាលដែលឈ្មោះថា មជ្ឈិមាបដិបទា នេះ មានអង្គ ៨ ( អដ្ឋង្គិកមគ្គ [១] ) គឺ

១– សម្មាទិដ្ឋិ សេចក្ដីយល់ឃើញត្រូវ,

២– សម្មាសង្កប្ប: សេចក្ដីត្រិះរិះត្រូវ,

៣– សម្មាវាចា វាចាត្រូវ,

៤– សម្មាកម្មន្ត: ការងារត្រូវ,

៥– សម្មាអាជីវ: ចិញ្ចឹមជីវិតត្រូវ,

៦– សម្មាវាយាម: ព្យាយាមត្រូវ,

---

១ មានសេចក្ដីពិស្ដារក្នុងច្បាប់អរិយសច្ចកថា ។

៧- សម្មាសតិ រលឹកត្រូវ,

៨- សម្មាសមាធិ តាំងចិត្តមាំត្រូវ ។

អង្គទាំង ៨ នេះ លុះតែមានព្រមជាមួយគ្នាគ្រប់ទាំង ៨ រួមចូលគ្នាជាកំឡាំងតែមួយ ទើបហៅថា មគ្គ ឬ អរិយមគ្គ ឬ មជ្ឈិមាបដិបទា, បើញែកចេញឲ្យដាច់ពីគ្នា តែអង្គមួយ ៗ វិញ មិនហៅថា មគ្គ ទេ គ្រាន់តែហៅត្រឹមចំណែកអង្គមួយ ៗ តាមឈ្មោះអង្គនោះ ៗ ប៉ុណ្ណោះ ។

មគ្គ មានឈ្មោះ ៤ យ៉ាង តាមកំឡាំងដែលអាចលះកិលេសបាន(១) គឺ

១ សោតាបត្តិមគ្គ ជាគូនឹង សោតាបត្តិផល

២ សកទាគាមិមគ្គ " សកទាគាមិផល

៣ អនាគាមិមគ្គ " អនាគាមិផល

៤ អរហត្តមគ្គ " អរហត្តផល

មគ្គ ៤ ផល ៤ នេះ ជាឈ្មោះរបស់ចិត្ត ។

អ្នកមានមគ្គចិត្តនិងផលចិត្តយ៉ាងនេះ ហៅថា " អ្នកបានសម្រេចមគ្គផល " ។

ការប្រតិបត្តិធម៌គ្រប់ជាន់ មានមជ្ឈិមាបដិបទាជាបង្គោល ។

---

១ មគ្គ ៤ លះកិលេសបានប្លែក ៗ គ្នា មានសេចក្ដីពិស្ដារក្នុងច្បាប់ពោធិបក្ខិយធម៌និងច្បាប់អរិយសច្ចកថា ។

មជ្ឈិមាបដិបទា ជាទីប្រជុំចុះនៃការប្រតិបត្តិធម៌ទាំងអស់ ក្នុងព្រះពុទ្ធសាសនាទាំងមូល ។ មជ្ឈិមាបដិបទាជាក្រសែនៃព្រះនិព្វាន, ជាផ្លូវដំណើរនៃចិត្ត មិនមែនជាផ្លូវសម្រាប់ដើរដោយជើងទេ ។

មជ្ឈិមាបដិបទា ជាធម៌សម្រាប់មនុស្សគ្រប់រូប មិនមែនជាធម៌ខ្ពស់ហួសផុតវិស័យរបស់មនុស្សឡើយ, មិនមែនជាធម៌ធ្វើឲ្យមនុស្សទន់ខ្សោយ ឬធ្វើឲ្យខ្ជិលច្រអូស, ឲ្យទាលទាញសេចក្តីទុក្ខដែលខ្លួនត្រូវអត់ធន់នោះទេ, ជាធម៌សម្រាប់មនុស្សអ្នកស្អប់ខ្ពើមទុក្ខហើយចង់បានសុខពិតប្រាកដ, ជាធម៌យ៉ាងកណ្តាល មានថ្នាក់ខ្ពស់ទាប តាមភាពរបស់មនុស្សបុថុជ្ជនគ្រប់រូប ក្នុងលោកនេះ មិនមែនជាធម៌សម្រាប់តែព្រះអរិយបុគ្គលមួយពួកប្រតិបត្តិប៉ុណ្ណោះទេ, ដ្បិតថា បើមនុស្សបុថុជ្ជន មិនប្រតិបត្តិតាមមជ្ឈិមាបដិបទានេះហើយ ធ្វើម្តេចនឹងក្លាយខ្លួនទៅជាព្រះអរិយបុគ្គល គឺអ្នកបានសម្រេចមគ្គ ៤ ផល ៤ កើត, ហេតុនេះ បានជាបាត់មជ្ឈិមាបដិបទាថា "ជាគោលនៃការប្រតិបត្តិធម៌យ៉ាងប្រសើរបំផុតក្នុងព្រះពុទ្ធសាសនា" ។

ពួកពុទ្ធបរិស័ទ កាលបើបានយល់នូវមជ្ឈិមាបដិបទា ថា "ជាគោលដ៏សំខាន់បំផុតនៃការប្រតិបត្តិធម៌" ហើយ ត្រូវតែពិចារណាដេញដោលរកឲ្យឃើញ នូវផលប្រយោជន៍នៃការប្រតិបត្តិធម៌ថា ផលដូចម្តេចដែលជា ៖

# ផលប្រយោជន៍យ៉ាងខ្ពស់បំផុតនៃការប្រតិបត្តិធម៌ក្នុងព្រះពុទ្ធសាសនា[១]

ក្បួនច្បាប់ក្នុងព្រះពុទ្ធសាសនា បានសំដែងបញ្ជាក់អំពីផលប្រយោជន៍នៃការប្រតិបត្តិធម៌ ដោយអនេកបរិយាយ ប៉ុន្តែ ផលទាំងអស់នោះបើបំព្រួញឲ្យតិចមក នៅមានតែត្រឹម ២ យ៉ាង គឺ ផលជាលោកិយ ១ ផលជាលោកុត្តរៈ ១ ។

## ផលជាលោកិយ

ក្នុងទីនេះ សូមបរិយាយអំពីផលជាលោកិយមុន ៖ អ្នកប្រតិបត្តិធម៌តាមក្រសែនៃមជ្ឈិមាបដិបទា ដូចបានរៀបរាប់ខាងដើមហើយនោះ រមែងបានប្រយោជន៍យ៉ាងវិសេស ក្នុងវេលាកំពុងតែប្រតិបត្តិធម៌ មិនបង្អង់ចាំពេលណាទើបបានផលទេ ( អកាលិកោ ) ជាធម៌ឲ្យផលពុំមានកាលខាន់ គឺថា មជ្ឈិមាបដិបទា ធ្វើអ្នកប្រតិបត្តិតាមឲ្យបាននៅជាមនុស្សមានហេតុផលជាគោលការ, ធ្វើឲ្យបាននៅជាអ្នកដាច់ស្រេចក្នុងចិត្ត, ធ្វើឲ្យបាននៅជាអ្នកឈ្នះខ្លួនឯង, ធ្វើឲ្យបាននៅជាអ្នកបង្គាប់បញ្ហាខ្លួនឯងកើត, ធ្វើឲ្យបាននៅជាអ្នកមានសេចក្តីប្រាជ្ញាត្រឹមត្រូវ, ធ្វើឲ្យបាននៅជាអ្នកទៀងទាត់ត្រង់ផ្លូវ, ធ្វើឲ្យបាននៅជា

---

១ ស្រង់ចាកច្បាប់ពុទ្ធសាសនាសៀម លេខ ម. ៤៣៥ ទំព័រ ៥១៨ . . . របស់ក្រសួងពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ។

អ្នកមានកាយកម្ម, វចីកម្ម និងការចិញ្ចឹមជីវិត ប្រាសចាកទុក្ខក្តៅក្រហាយគ្រប់ប្រការ; ធ្វើឲ្យបានទៅជាអ្នកមានព្យាយាមត្រូវ មានសេចក្តីក្លាហាន, មានសេចក្តីចេះដឹង និងឲ្យមានសេចក្តីទៀងទាត់ក្នុងចិត្ត ល្មមឲ្យជីវិតរបស់ខ្លួនមានរបៀបរៀបរយ គួរដល់ឋានៈរបស់ធម៌ដែលខ្លួនប្រតិបត្តិ ។

កាលមនុស្សបានប្រតិបត្តិធម៌ត្រឹមត្រូវតាមមជ្ឈិមាបដិបទា ដែលមាន សម្មាទិដ្ឋិ ជាប្រធាន ជាមេនាំមុខហើយ ក៏រមែងបានផលអាចឲ្យកើតអង្គមគ្គ ៧ ខាងចុង ត ៗ គ្នាតាមលំដាប់ក្ភាម ៗ មិនរង់ចាំកាលណាទេ ដូចជាអ្នកមាន :

១- សេចក្តីយល់ឃើញត្រូវ (សម្មាទិដ្ឋិ) ការចូលចិត្តត្រឹមត្រូវតាមហេតុផលហើយ ជាផ្លូវឲ្យកើត :

២- សេចក្តីត្រិះរិះត្រូវ (សម្មាសង្កប្បៈ) ។ សេចក្តីត្រិះរិះត្រូវធ្វើឲ្យកើត :

៣- វាចាត្រូវ (សម្មាវាចា)

៤- ការងារត្រូវ (សម្មាកម្មន្តៈ)

៥- ការចិញ្ចឹមជីវិតត្រូវ (សម្មាអាជីវៈ)

៦- ព្យាយាមត្រូវ (សម្មាវាយាមៈ)

៧- រលឹកត្រូវ (សម្មាសតិ)

៨– តាំងចិត្តមាំត្រូវ ( សម្មាសមាធិ ) ។

កាលបើអដ្ឋង្គិកមគ្គជាហេតុ កើតមានយ៉ាងនេះហើយ ការលះបង់កិលេសនោះ ៗ បានជាប់ស្រឡះជាផល ក៏កើតមានឡើងក្នុងខណៈនៃមគ្គនោះដែរ ក៏ប៉ុន្តែ ជាមគ្គនៅទន់ខ្សោយនៅស្តើងស្តួច; មិនទាន់រឹងប៉ុងខ្លាំងក្លា, មិនទាន់ពេញលេញ ទើងហៅថា អរិយមគ្គមិនទាន់បានទេ គ្រាន់តែអាចលះបង់កិលេស បំពួកខ្លះ បានតាមកំឡាំងនៃមគ្គជាលោកិយ ឲ្យបានផលជាលោកិយប៉ុណ្ណោះ ។

បណ្តាផលជាលោកិយទាំងអស់ សំដៅយកត្រង់ការអស់កិលេសបំពួកខ្លះនោះ(១) ថាជាផលប្រសើរបំផុត លើសផលជាលោកិយនានា មានផលឲ្យបានសោយសុខសម្បត្តិក្នុងស្ថានមនុស្សនិងស្ថានសួគ៌ជាដើម ។

## ផលជាលោកុត្តរៈ

មគ្គជាលោកិយដូចបាននិយាយរួចមកហើយនោះ ជាគោលនៃការគ្រប់គ្រងជីវិតរបស់អ្នកប្រតិបត្តិធម៌ឲ្យប្រព្រឹត្តទៅរៀបរយ ។ ឲ្យបានសុខសប្បាយកល់ៗថ្ងៃ ហៅថា អ្នកបានផលជាលោកិយ ។ ផលជាលោកិយនេះ កាលបើគេអប់រំអដ្ឋង្គិកមគ្គឲ្យចាស់ក្លាដល់កំរិតហើយ អាចក្លាយទៅជា **អរិយផល** ដែលកើតពី **អរិយមគ្គ** ដូចសេចក្តីអធិប្បាយដោយសង្ខេបទៅនេះ :

---

១ សេចក្តីសៅហ្មងអាក្រក់ដោយកាយ, វាចា, ចិត្ត ហៅថា កិលេស ។ នេះ មាន ៣ យ៉ាងគឺ យ៉ាងគ្រោកគ្រាកក៏មាន យ៉ាងកណ្តាលក៏មាន យ៉ាងល្អិតសុខុមក៏មាន ។

អ្នកប្រតិបត្តិធម៌តាមលំអាន នៃមជ្ឈិមាបដិបទាជាលោកិយ ហើយបានព្យាយាមអប់រំអដ្ឋមគ្គទាំង ៨ ឲ្យមានកំឡាំងពេញទីតាមវិធីនៃការប្រតិបត្តិធម៌ ឲ្យព្រមព្រៀងគ្នាជាកម្លាំងតែ ១ ហើយ ហៅថា អរិយមគ្គ ។ នេះ អាចកំចាត់បង់កិលេស ឬ សំយោជន៍ (១) យ៉ាងល្អិតបំផុតដែលត្រាំជាប់ស្អិតនៅក្នុងសន្តានចិត្ត ឲ្យរលត់ទៅតាមចំណែកនៃកម្លាំងអរិយមគ្គ ដែលខ្លួនបានអប់រំមកហើយ ។ ផលដែលកើតមានឡើងអំពីកិរិយាលះបង់កិលេសបាននេះ ហៅថា អរិយផល ។

អរិយមគ្គ ដែលចាស់ក្លាដល់កំរិត អាចកំចាត់បង់កិលេសក្នុងសន្តានចិត្តបានត្រឹមណា ក៏មានឈ្មោះហៅតាមជាន់នៃការលះបង់កិលេសរបស់ខ្លួនបានត្រឹមណោះថា សោតាបត្តិមគ្គ, សកទាគាមិមគ្គ, អនាគាមិមគ្គ, អរហត្តមគ្គ ។ អរិយផល ក៏បានជាគូនឹងអរិយមគ្គគ្រប់ៗមគ្គដែរ គឺសោតា-បត្តិផល, សកទាគាមិផល, អនាគាមិផល និង អរហត្តផល ។ ហេតុនោះទើបកើតបានជាមគ្គ ៤ ផល ៤ ហៅកាត់ឲ្យខ្លីថា មគ្គផល ។ អរិយមគ្គជាហេតុ អរិយផលជាផល, អរិយមគ្គដែលមានឈ្មោះផ្សេងគ្នាជា ៤ យ៉ាងនោះ ក៏ព្រោះកំចាត់បង់កិលេសបានច្រើនតិចជាងគ្នា(២) ។ ឧកាសបើកឲ្យអង្គមគ្គប្រជុំគ្នាជាអរិយមគ្គបានកាលណា ការកាត់ផ្តាច់សំយោជន៍ក៏កើត

---

១ កិលេសជាគ្រឿងប្រកបចិត្ត ហៅថា សំយោជនៈមាន ១០ យ៉ាង គឺសក្កាយទិដ្ឋិ ១, វិចិកិច្ឆា ១, សីលព្វតបរាមាស ១, កាមច្ឆន្ទ ១, ព្យាបាទ ១, រូបរាគ ១, អរូបរាគ ១, មានៈ ១, ឧទ្ធច្ចៈ ១, អវិជ្ជា ១ ។

២ អរិយមគ្គណា កំចាត់បង់កិលេសអ្វីខ្លះ មានសេចក្តីពិស្តារក្នុងច្បាប់អរិយសច្ចកថា ។

មានឡើងក្នុងកាលណោះមួយពេល ។ ឱកាសនេះមិនកំណត់កាលទេ (អកាលិកោ) កើតមានឡើងក្នុងខណៈដែលចិត្តមូលជាអារម្មណ៍តែមួយ ដោយឆាប់រហ័ស ដូចអ្នកខ្លះស្តាប់ទេសន៍បានសម្រេចមគ្គផលនៅទីនោះភ្លាមក៏មាន(ខិប្បាភិញ្ញា), ដោយសេចក្តីព្យាយាមដ៏ខ្លាំងក្លា ដូចព្រះយោគាវចរខំចំរើនភាវនារឿយ ៗ រាល់ថ្ងៃ ទាល់តែបានសម្រេចមគ្គផលក៏មាន ( ទន្ធាភិញ្ញា ) ។

អ្នកប្រតិបត្តិធម៌ ហើយបានសម្រេចលោកុត្តរផល ជាផលជាន់ខ្ពស់បំផុតយ៉ាងនេះហើយ ឈ្មោះថា ជាអ្នកបានដល់ព្រះនិព្វាន ជាស្ថានរលត់ទុក្ខទាំងអស់ ឈ្មោះថា ជាអ្នកប្រតិបត្តិធម៌ត្រឹមត្រូវតាមវត្ថុបំណងនៃព្រះពុទ្ធសាសនាពិតប្រាកដ ព្រោះព្រះពុទ្ធសាសនាទាំងមូលមានចំណុចជាទីបំផុតត្រង់ មគ្គ ៤ ផល ៤ និព្វាន ១ រួមជា៩ ដែលហៅថា ព្រះនពលោកុត្តរធម៌ (១) ។

## សេចក្តីបញ្ចប់

មនុស្សជាជាតិអ្វីក៏ដោយ ប្រុសឬស្រី ក្មេងឬចាស់ ដែលជាអ្នកកាន់ពុទ្ធសាសនា បាននាមបញ្ញត្តិថា ពុទ្ធបរិស័ទ ហើយត្រូវខំពិចារណាឲ្យយល់ច្បាស់ដោយគំនិតប្រាជ្ញារបស់ខ្លួនថា :

ព្រះពុទ្ធសាសនា ជាសាសនាទៀងទាត់ណាស់ គ្មានសាវ័កណា

១ ធម៌បម្លងសត្វឲ្យឆ្លងផុតចាកលោក ហៅថា លោកុត្តរធម៌ ។

អាចលុបលាង ឬ កែប្រែ ដូចជាច្បាប់សម្រាប់ប្រទេសមួយ ៗ បានទេ, ជាសាសនាមិនទទួលពាក្យអង្វរករបន់ស្រន់ របស់អ្នកណាសោះឡើយ; ជាសាសនាមិនទទួលរ៉ាប់រងទុក្ខទោសជួសអ្នកណាឡើយ, ជាសាសនាចង្អុលហេតុផលយ៉ាងដាច់ខាត ។

ព្រះពុទ្ធសាសនាប្រៀបដូចទូក ពួកពុទ្ធបរិស័ទប្រៀបដូចអ្នកជិះ ។ ទូកលឿនក្តី មិនលឿនក្តី ទៅត្រង់ឬវៀចវេរក្តី ក៏ស្រេចតែលើខ្លួនអ្នកជិះ ។ បើទូកធ្លុះធ្លាយ ត្រូវតែអ្នកជិះជួសជុលបិទជិតដោយខ្លួនឯង បើមិនបិទទេ ទូកក៏លិច ខ្លួនអ្នកជិះលើទូកក៏លង់ទឹកស្លាប់កណ្តាលទន្លេ ព្រោះទីនោះស្រែកហៅរកអ្នកណាឲ្យជួយស្រង់ខ្លួនពុំបានឡើយ ។

ពួកពុទ្ធបរិស័ទ មិនត្រូវតាំងចិត្តផ្អែកវេរទៅលើព្រះពុទ្ធអង្គ ដោយទឹកអាងថា “ព្រះពុទ្ធ នឹងមកជួយដឹកដៃ យកយោងខ្លួន ឲ្យរួចពីទុក្ខទោសបាន” ដូច្នេះឡើយ ត្រូវតែតាំងចិត្តជឿកម្ម និងជឿផលរបស់កម្ម យ៉ាងដាច់ខាតថា កម្មល្អឲ្យផលជាសុខ កម្មអាក្រក់ឲ្យផលជាទុក្ខ, អ្នកណាបានសុខឬបានទុក្ខ ក៏ព្រោះតែអ្នកនោះបានធ្វើកម្មល្អឬអាក្រក់រួចមកហើយ, គ្មានអ្នកណាអាចទទួលសុខទុក្ខជួសអ្នកណាបានទេ ប្រៀបដូចចោរលួចប្រាក់គេ ។ ចាប់បានដាក់គុក គ្មានអ្នកណាទទួលទោសគុកជួសចោរនោះបានឡើយ សូម្បីតែឪពុកបង្កើត ក៏ទទួលទោសគុកជួសកូនមិនបានដែរ ។ ម្យ៉ាងទៀត ដូចជម្ងឺ ឬសេចក្តីស្លាប់

និងទទួលជួសគ្នាមិនបានសោះឡើយ ។ សេចក្ដីបរិសុទ្ធនិងមិនបរិសុទ្ធ មានចំពោះតែប្រមនុស្សម្នាក់ ៗ គ្មានអ្នកណាបរិសុទ្ធជួសអ្នកណាបានទេ ( សុទ្ធិ អសុទ្ធិ បច្ចត្តំ ខុ. ធ. ), អ្នកដទៃធ្វើអ្នកដទៃឲ្យបរិសុទ្ធមិនបានទេ ( នាញ្ញោ អញ្ញំ វិសោធយេ ខុ.ធ ); សេចក្ដីនេះប្រៀបដូចអ្នករៀនចំណេះវិជ្ជាផងទាំងពួង អ្នកណារៀន អ្នកនោះចេះ នឹងរៀនជួសគ្នាឬនឹងចេះជួសគ្នាមិនកើត ។ ការរៀនជាកម្មគឺហេតុ ការចេះដឹងជាផល ។ ហេតុនិងផល តែងអាស្រ័យគ្នាជានិច្ច ដូចសុភាសិតបុរាណថា « ចេះពីរៀនមានពីរក » ។

ពុទ្ធបរិស័ទ បើបានជឿកម្មផលដូច្នេះហើយ ទើបបានប្រតិបត្តិធម៌ត្រឹមត្រូវតាមវត្ថុបំណងរបស់ព្រះពុទ្ធសាសនា ។ បើមិនជឿកម្មផលទេ ហើយចេះតែធ្វើបុណ្យឲ្យទានរក្សាសីលតាំងខ្វាក់តាំងថ្លង់ទៅ ព្រោះតែចិត្តចង់ឲ្យបានសុខនោះ លុះមិនបានសុខដូចបំណងហើយ ដ្បិតខ្លួនប្រតិបត្តិខុសគន្លងធម៌ ក៏ទៅជាខំបន់ស្រន់ព្រះសំពះទេវតាឲ្យជួយខ្លួន, កាលបើមិនឃើញព្រះ ឬ ទេវតាណាជួយ ក៏ត្រឡប់ជាខឹងស្អប់បន្ទោសព្រះ ឬ ទេវតា ថាមិនជួយខ្លួន ទៅវិញ ។

បណ្ដាយថាសភាវៈទាំងឡាយ[1] ដូចជាគេយកទឹកស្រោចភ្លើង ៗ តែងរលត់អស់ទៅ, នេះ ជាទំនៀមទម្លាប់យ៉ាងទៀងទាត់របស់ធម្មតា

---

១ របស់ដែលកើតមានឡើងឯងៗតាមធម្មតាលោកហៅថា យថាសភាវៈ ឬហៅថា វត្ថុធម្មជាតិ ។

គ្មានមនុស្សណាជាអ្នកសាងភ្លើង ឬ ទឹក ដែលជាវត្ថុធម្មជាតិនោះឡើយ មានតែមនុស្សជាអ្នកដឹងទំនៀមនេះថា « បើគេយកទឹកស្រោចភ្លើង ៗ មុខជារលត់ » អ្នកដែលដឹងយ៉ាងនេះ ចាត់ថា ជាមនុស្សដឹងមុនគេ ហើយប្រាប់គ្នាតៗមក ។ ព្រះពុទ្ធអង្គក៏ដូច្នោះដែរ គឺព្រះអង្គបានជ្រាបរបស់ពិត ( អរិយសច្ច ) មុនគេ ។ ព្រះអង្គមិនបានកសាងអង្គមគ្គទាំង ៨ ឡើងទេ ។ ព្រះអង្គគ្រាន់តែជាអ្នកបានស្វែងរកមគ្គឃើញមុនគេ ហើយប្រកាសប្រាប់អ្នកដែលចង់បានសុខឱ្យធ្វើដំណើរទៅតាមអង្គមគ្គទាំង ៨ នោះប៉ុណ្ណោះ ( អក្ខាតារោ តថាគតា=ព្រះតថាគតទាំងឡាយ គ្រាន់តែជាអ្នកប្រាប់ផ្លូវ ខុ.ធ. ) ។ .

អង្គមគ្គទាំង ៨ ប្រៀបដូចជាផ្លូវថ្នល់ ១ ប្រកបដោយអង្គគុណ ៨ យ៉ាង គឺ មានក្តារបិទប្រកាសប្រាប់ដំណើរការសព្វគ្រប់ឱ្យដឹងផែនទីភូមិសាស្ត្រច្បាស់លាស់ កុំឱ្យវង្វេងផ្លូវបាន ( សម្មាទិដ្ឋិ ), . មិនវៀចវេរខុសផ្លូវ សឹងត្រង់ទៅកាន់ទិសតាមប្រាថ្នា ( សម្មាសង្កប្បៈ ), មានគូស្នាមក្លោះល្អប្រពៃ ( សម្មាវាចា ). មានម្លប់រុក្ខាត្រជាក់ត្រជុំ ( សម្មាកម្មន្តៈ ), មានទីកន្លែងសម្រាប់ជ្រកសំណាក់អាស្រ័យយ៉ាងសុខស្រួល ( សម្មាអាជីវៈ ) , មានទីកន្លែងសម្រាប់ស្វះស្វែងរកអាហារចំណីបានដោយងាយ ៗ មិនក្រ មិនលំបាក ( សម្មាវាយាមៈ ), មានការគ្រប់គ្រងថែរក្សាអ្នកដំណើរឱ្យបានសុខសប្បាយ មិនឱ្យមាន

អ្នកយកណ្ដាលផ្លូវ (សម្មាសតិ), មានសេចក្ដីសុខស្ងប់ស្ងាត់ត្រជាក់ត្រជុំ ដល់អ្នកដំណើរ (សម្មាសមាធិ) ។ អរិយមគ្គក៏មានអង្គនាំល្មមសមគួរ ឲ្យបានសម្រេចសេចក្ដីប្រាថ្នារបស់អ្នកប្រតិបត្តិដូចជាផ្លូវនោះដែរ ។

អង្គមគ្គទាំង ៨ នឹងដើរជួសគ្នាមិនបានទេ ព្រោះជាចំណែកចិត្ត មិនមែនជាចំណែកវត្ថុដូចការលត់ភ្លើង ដែលអាចជួយស្រោចជួសគ្នាបានទេ ។ ភ្លើងប្រៀបដូចសេចក្ដីទុក្ខក៏មែនហើយ ប៉ុន្តែ ភ្លើងជាចំណែកវត្ថុ ការលត់ជាចំណែកកាយ ទើបអាចជួយលត់ជួសគ្នាបាន ។ ទុក្ខក្នុងទីនេះ ជាចំណែកចិត្ត ដែលមនុស្សគ្រប់រូបដឹងឃើញដោយខ្លួនឯង (សន្ទិដ្ឋិកោ) ទើបធ្វើជួសគ្នាមិនបាន ប្រៀបដូចជាអ្នករៀន មិនអាចរៀនសូត្របំណេះ វិជ្ជាជួសគ្នាបានដូច្នោះដែរ ។

ព្រះពុទ្ធអង្គគ្រាន់តែជាអ្នកជ្រាបរបស់ពិតដ៏ប្រសើរ (អរិយសច្ច ៤) មុនគេ ហើយទ្រង់បានចង្អុលប្រាប់គេថា នេះហៅថា ទុក្ខ (ទុក្ខអរិយ-សច្ច) នេះជាហេតុឲ្យកើតទុក្ខ (ទុក្ខសមុទយសច្ច) នេះជាសេចក្ដីរលត់ទុក្ខ (ទុក្ខនិរោធអរិយសច្ច) នេះជាផ្លូវដែលនឹងធ្វើអ្នកដំណើរឲ្យដល់នូវសេចក្ដីរលត់ទុក្ខ (ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច) ជាផ្លូវដែលធ្វើឲ្យមារនិងសេនាមារតាមមិនទាន់. ជាផ្លូវដែលអ្នកទាំងឡាយ ត្រូវព្យាយាមដើរទៅដោយខ្លួនឯង, ព្រះតថាគតទាំងឡាយគ្រាន់តែជាអ្នកប្រាប់ផ្លូវប៉ុណ្ណោះទេ (អក្ខាតារោ តថាគតា) ។ មួយទៀត ព្រះតថាគតទាំងឡាយ មិនដែល

ទទួលពាក្យអង្វរករបន់ស្រន់របស់អ្នកណាឡើយ ( សុទ្ធិ អសុទ្ធិ បច្ចត្តំ " សេចក្ដីបរិសុទ្ធិ និងមិនបរិសុទ្ធិ មានចំពោះខ្លួន " នាញ្ញោ អញ្ញំ វិសោធយេ " អ្នកដទៃធ្វើអ្នកដទៃឲ្យបរិសុទ្ធមិនបានទេ " ខុ.ធ. ) ។

សេចក្ដីដែលបានអធិប្បាយអំពីករណីយកិច្ចរបស់ពុទ្ធបរិស័ទតាំងពីដើមរហូតដល់ចប់ នេះជាពាក្យឆ្លើយដោះស្រាយប្រស្នា ៥ ប្រការខាងដើមនោះថា :

១– ព្រះពុទ្ធអង្គមិនមែនជាអ្នកបង្កើតលោកទេ ។

២– ព្រះពុទ្ធអង្គមិនមែនជាអ្នកដាក់ទោសទណ្ឌកម្ម ដល់ពួកសាវ័កដែលល្មើសពុទ្ធបញ្ញត្តិទេ ។

៣– ព្រះពុទ្ធអង្គមិនមែនជាអ្នកទទួលទោសជួសពួកសាវ័កទេ ។

៤– ព្រះពុទ្ធអង្គមិនមែនជាអ្នកទទួលអង្វរករពាក្យបន់ស្រន់ របស់ពួកសាវ័កទេ ។

៥– ព្រះពុទ្ធអង្គមិនមែនជាម្ចាស់កម្មផលទេ ។

## មេរៀន

ការប្រតិបត្តិធម៌ គឺជា ៖

១– ការផ្លាស់ចិត្តអាក្រក់ចេញឲ្យក្លាយទៅជាចិត្តល្អវិញ,

២– ការធ្វើជីវិតឲ្យបានសុខស្រួល,

៣– ការបំបាត់សេចក្តីល្ងង់ខ្លៅ,

៤– ការចេញចាកទុក្ខ ឈានទៅរកសុខ, សឹងមានជាទីដៅ ។

៥– ពុទ្ធបរិស័ទត្រូវប្រតិបត្តិតាមសាសនា ទើបហៅថា "ជាអ្នកកាន់សាសនាពិត", ទាំងត្រូវចាំពុទ្ធប្រវត្តិដោយល្អិតល្អ ហើយត្រូវផ្ចិតនិស្ស័យព្រះមកដាក់ខ្លួន ។

# ករណីយកិច្ចរបស់ពុទ្ធបរិស័ទ

សង្ខេបប៉ុណ្ណោះ

—០—

# ការគប់មិត្ត

តាំងពីព្រេងនាយ មកដល់សព្វថ្ងៃនេះ ជីវិតមនុស្ស ត្រូវការមិត្ត ជាងវត្ថុទាំងអស់ ។ នេះគឺជាចំណោទសំខាន់ ពោលរួចហើយ បង្ហាញន័យ ថា៖

បុគ្គលដទៃ ក្រៅពីមាតាបិតា ស្វាមីភរិយា បុត្រធីតា និង ញាតិសន្តាន របស់ខ្លួនចេញ គ្មានបុគ្គលណា ជាទីស្រឡាញ់ស្និទ្ធស្នាលទុកចិត្ត ជួយផ្ដល់ប្រយោជន៍ទៅវិញទៅមក ជាងមិត្តសម្លាញ់ខ្លួនទេ មានតែមិត្តនេះហើយ ដែលអាចជួយគាំទ្រដំណើរជីវិតយើង ឲ្យបានប្រព្រឹត្តទៅស្រួល ប្រកបដោយជោគជ័យ ក្នុងលោកនេះ ។

មនុស្សគ្មានមិត្ត ទុកដូចជាមនុស្សជាកពិការគ្រប់យ៉ាង គឺ មានតែភ្នែកក្ដី ប៉ុន្តែមើលអ្វីៗមិនឃើញ, មានតែត្រចៀកស្ដាប់ឮ តែគ្មានស្ដាប់ការអ្វីឲ្យបានសព្វគ្រប់, មានដៃមាំមួន តែធ្វើការងារមិនបានល្បីឈ្មោះ និងមានជើងល្អជា តែធ្វើដំណើរទៅឆ្ងាយមិនរួច សូម្បីសួស្ដី រត់មកចំខ្លួនហើយ បែរជាត្រឡប់ទៅរកអ្នកដទៃវិញ ។

ចំណុចយ៉ាងសំខាន់នេះហើយ ដែលបណ្ដាលឲ្យជីវិតសត្វ ក្នុងលោកទាំងមូលសព្វថ្ងៃស្រេកឃ្លានមិត្ត ជាងចំណីអាហារទាំងពួង ហើយជាពិសេស មានដល់ទៅសុខចិត្តស៊ូបន្ថយចំណីអាហារពេលវេលាខ្លួន ឲ្យថយតិចចុះ ទុកនៅត្រឹមតែទទួលទានរស់ ដើម្បីសំចៃឲ្យសល់លុយកាក់

ប្រាក់កាស ដើម្បីយកទៅចងមិត្តនឹងអ្នកប្រទេសនានាផងក៏មាន ។

ដូច្នេះ រដ្ឋក្តី មនុស្សម្នាក់ៗក្តី ត្រូវតែមានមិត្តជាចាំបាច់ ខានមិនបាន ប៉ុន្តែត្រូវស្គាល់មិត្តឲ្យច្បាស់ តាមសណ្តាប់ធ្នាប់ ច្បាប់ការគប់មិត្ត. បើមិនបានច្រើន ក៏ឲ្យល្មមនឹងធ្វើការនិទស្សន៍ពិចារណាខ្លះ ។ ជាមុនសិនដែរ ទើបការគប់រក នឹងអាចប្រព្រឹត្តទៅបាន ដោយប្រពៃ ។ ក្នុងករណីនេះ អ្នកប្រាជ្ញបុរាណកាល លោកធ្លាប់បានធ្វើការត្រិះរិះពិចារណាយ៉ាងល្អិតល្អន់ ព្រមទាំងធ្លាប់ជួបប្រទះនូវអស់ទាំងសព្វហេតុការណ៍ ជាពិតប្រាកដណាស់ហើយ ទើបមានគតិជាច្រើន ដែលលោកបានចារឹកទុកសម្រាប់កូនចៅជាន់ក្រោយតៗមក ។

ដូចតទៅនេះ ចូរពិចារណាឲ្យវែងឆ្ងាយចំពោះ " ច្បាប់បណ្តាំផ្ទុក " ដែលលោកអ្នកប្រាជ្ញពីបុរាណចងទុកមក ថា៖

មិត្តមួយសោតណ៌ ទៅមកកាន់គ្នា បង្កើតឲ្យសុខ
មិត្តមួយឲ្យទោស បង្កើតជាទុក្ខ មិត្តមួយឲ្យទុក
ឲ្យបង់ទ្រព្យ ។

ចាស់ព្រឹទ្ធាចារ្យ បានចង្អុលបង្ហាញថា កើម្រាក់ មិត្តភក្តិ បក្សពួក មានច្រើនស្ពាន ច្រើនបែបណាស់ គឺ អ្នកខ្លះ មានចិត្តសប្បុរស ខ្លះក៏អសប្បុរស ខ្លះស្លូត ខ្លះកាចជាដើម; តែទោះបីច្រើនម្តេចម្តាក៏ដោយ គង់រួមឲ្យខ្លីមក នៅត្រឹមតែពីរពួក គឺ

មិត្តណា ដែលសេពគប់ទៅមកកាន់គ្នា កើតសេចក្ដីសុខ សេចក្ដីចម្រើន ទាំងផ្លូវលោកផ្លូវធម៌ ជាមិត្តប្រកបដោយសុជីវធម៌ មានការគួរសម ចេះយោគយល់គ្នា ជួយយកអាសាគ្នា ស្មោះត្រង់នឹងគ្នា មិនក្បត់ចិត្តគ្នា ប្រព្រឹត្តធ្វើតែអំពើជាប្រយោជន៍ដល់គ្នានឹងគ្នា, មិត្តនោះ ហៅថា "កល្យាណមិត្ត" ។

មិត្តណា នាំឲ្យកើតទុក្ខទោស ឬ នាំឲ្យមានគ្រោះថ្នាក់ បង់ទ្រព្យសម្បត្តិ រេចរិល អាប់អន់ទុនថយ សាបសូន្យចាកសេចក្ដីចម្រើន សេចក្ដីសុខ ឬ ប្រយោជន៍គ្រប់យ៉ាង ជាមិត្តគ្មានសុជីវធម៌នៅក្នុងខ្លួន រាប់អានស្គាល់អ្នកណា យកអ្នកណាធ្វើមិត្ត មានគំនិតអាក្រក់ គិតតែបឺតជញ្ជក់ យកប្រយោជន៍ពីអ្នកនោះ និងយកអ្នកនោះធ្វើខ្ញុំកញ្ជះខ្លួន, មិត្តនោះ ហៅថា "បាបមិត្ត" ។

១- កល្យាណមិត្ត= មិត្តល្អសប្បុរស គឺមិត្តដែលមានកុសលធម៌នៅក្នុងសន្ដាន ជាអ្នកលះបាបសន្សំបុណ្យ លះគុណវិបត្តិ សន្សំគុណ-សម្បត្តិ, ជាមិត្តគួរសេពគប់រាប់រក គួរយកជាសម្ពន្ធមេត្រី ជាសាច់ឈាម ជាទំនុកទុកចិត្តឥតសង្ស័យ ។ ដូចថា :

## មិត្តដែលគួរផ្ដេកផ្ដួលស្និទ្ធស្នាលរាប់បញ្ចូលជាកល្យាណមិត្ត មាន ៤ យ៉ាង គឺ

ក- មិត្តអ្នកធ្វើឧបការគុណ អ្នកជួយឈឺឆ្អាល ។

ខ- មិត្តអ្នករួមសុខរួមទុក្ខជាមួយ ។

គ- មិត្តអ្នកបង្ហាញប្រយោជន៍ ប្រាប់ផ្លូវចម្រុងចម្រើន ។

ឃ- មិត្តអ្នកជួយអនុគ្រោះស្រោចស្រង់ ជួយយឹតជួយយោង ជួយ សណ្ដោងអន្ទង ។

ន័យមួយបែបទៀតថា មិត្តល្អគួរសេពគប់ លោកទុកជាកល្យាណមិត្ត តែងប្រកបដោយអង្គ ៧ យ៉ាង គឺ

ក- តែងឲ្យរបស់ដែលកម្រក្រៃលែង ដែលមិនងាយនរណាឲ្យគ្នាកើត គឺចែករំលែកឲ្យមិត្តបាននូវរបស់កម្រ ។

ខ តែងតែធ្វើនូវករណីយ ដែលលំបាក គឺជួយឈឺឆ្អាល ធ្វើឲ្យកើតនូវកិច្ចការដ៏ធ្ងន់ ។

គ- តែងតែអត់ធ្មត់នឹងហេតុការណ៍ ដែលកម្រនរណាប្តូរស៊ូទ្រាំបាន គឺមានខន្តិធម៌ យ៉ាងចំណាប់ចំនួនល្អល្អះ ។

ឃ- តែងតែបង្ហើបបង្ហាញ ដោយច្បាស់លាស់ នូវរបស់កំបិទកំបាំង របស់ខ្លួនដល់មិត្ត ។

ង- តែងតែជួយលាក់លៀម បំបិទបំបាំងនូវអាថ៌កំបាំងរបស់មិត្ត ។

ច- កាលបើមិត្តមានគ្រោះកាច អន្តរាយ ថុសធ្លាយ ដោយហេតុអ្វីមួយ, ស៊ូប្តូរក្រាញនៅជាមួយមិត្ត មិនបោះបង់ចោលមិត្ត ។

ឆ- បើមិត្តទៅជាក្រតោកយ៉ាក ខ្វះខាត ប៉ប៉ះប៉ប៉ុន, មិនប្រមាថ

មើលឆ្ងាយ មើលជោគមិត្ត ដល់តិចតួចឡើយ ។

មិត្តដែលមានកល្យាណធម៌ ដូចបានពណ៌នាមកនេះ ហៅថា កល្យាណមិត្ត; បើនរជនណា បានសេពគប់មិត្តបែបនេះ, នរជននោះ តែងបានសេចក្ដីសុខសួស្ដីសិរីមង្គលជានិរន្តរ៍; សមដូចពុកណាភាសិត ថា "មិត្តមួយសោតណា ទៅមកកាន់គ្នា បង្កើតឲ្យសុខ" ដូច្នេះ ។ តែថា មិត្តរបៀបនេះ កម្រនឹងរកបានដោយងាយនោះណាស់ ត្រូវគ្នានឹងភាសិតថា "មិត្តល្អត្រូវសេពគប់" តែ "មិត្តល្អក្ររកបាន" គឺមិត្តភាពរកទិញតាមផ្សារពុំបានឡើយ ហើយអ្នកប្រាជ្ញខ្លះ បានពោលបញ្ជាក់សង្កត់លើទ្រឹស្ដីនៃការគប់មិត្តថា "មនុស្សដែលមានមេត្តាករុណា ជាមាតាដែលនាំមកនូវមិត្តភាព" ។ បើរកមិត្តជាកល្យាណ ដូចប្រាប់លក្ខណៈមកខាងលើនេះបានហើយ អ្នកចូរសេពគប់ចុះ មិនខុសឃ្លាងផ្លូវល្អ ផ្លូវសុខចម្រើនឡើយ ។ ប៉ុន្តែ កុំប្រឡូយកធ្វើជានាយហៅហ្វាយ ឬ ជាទាសកម្មកររបស់ខ្លួន ព្រោះបើដូច្នោះ នឹងខានបានធ្វើជាមិត្តសម្លាញ់នឹងគ្នាទៅហើយ ។

មិនត្រឹមតែប៉ុណ្ណោះសោត ការសេពគប់កល្យាណមិត្ត តែងបានអានិសង្សខ្ពង់ខ្ពស់ជាងនេះទៅទៀត ដូចជាព្រះរាធត្ថេរ ដែលបានសេពគប់នឹងព្រះសារីបុត្រ ជាកំពូលកល្យាណមិត្ត, មិនយូរប៉ុន្មាន ព្រះរាធត្ថេរ បានសម្រេចព្រះអរហត្ត កំចាត់កិលេស ឥតសេសសល់ឡើយ ។

២– បាបមិត្ត= មិត្តអាក្រក់ មិត្តជួរជាតិ មិត្តមានបាបធម៌នៅក្នុងខ្លួនសន្តាន; មិត្តនេះ បុរសបុគ្គលមិនគប្បីសេពគប់ឡើយ; ព្រោះថា បាបមិត្ត តែងតែនាំបុរសបុគ្គលឲ្យលិចលង់ ឲ្យធ្លាក់ចុះក្នុងផ្លូវលាមក អាក្រក់គ្រប់ជំពូក ។ បណ្ឌិតផ្តាំទុក ថា៖

## មិត្តមិនគួរសេពគប់ មិនគួរយកខ្លួនបៀត
## មាន ៤ យ៉ាង គឺ

១–មិត្តគិតតែប្រយោជន៍ខ្លួន, មិត្តដែលកោនកាញ់ចង់បានប្រយោជន៍តែម្នាក់ឯង ដែលចង់បានញ័រទទត់ ដូចគេទទាក់ ឬថា ញ័រទក្រេក គិតតែពីការក្រសារជ្រាវយកពីមុខគេឯង; សមដូចច្បាប់ពាក្យចាស់ថា

បានហើយចង់បានទៀត ធ្មៀតហើយធ្មៀតពុំគិតឈ្នេង
មើលយល់តែមុខឯង មិនឃើញគេឯទៀតផង ។

មិត្តនេះ តែងធ្វើមុខក្រញូវ កញ្ចុបកញ្ចូវ សម្លឹងសម្លក់អ្នកដទៃ ដែលគេបានលាភលើសខ្លួន ចួនទៅជាខ្វារខ្វាចដើម្បីខ្លួនឯងក៏មាន សមដូចសុភាសិត " ហៃអស់មហាជន " ថា

" ឃើញគេបានទ្រព្យល្អ ស្មើរខ្វារគេខ្វាចគេលើស " ។

២– មិត្តល្អតែវាចា ផ្អែមល្ហែមតែសំដី មិត្តនេះ មានសំដីសំដៅរៀបរយល្អ និយាយពាក្យ បាទ ចាស ជានិច្ច មិនដែលគ្គងពាក្យពេចន៍ម្តងណាឡើយ ធ្វើមនុស្សចេះប្រចុប ចេះអែបអប ចេះផ្សំ ។

មិត្តដែលចាស់ទុំបុរមបុរាណសន្មតថា "មនុស្សធ្មិនក្រៅនៅក្នុង" ចាត់ជាមនុស្សមិនបានការ យកជាគ្នាមិនកើត ។

តាមច្បាប់ពជទេតិថា "កុំទុកចិត្តអភិប្រាយ" គឺកុំទុកចិត្តមនុស្ស ដែលប៉ិនតែខាងប្រាជ្ញព្រោក ដែលនិយាយឲ្យផុតតែពីមាត់ ដែលប្រើនតែសំដី ដូចសំដីស្រូវ ជារបស់ឥតប្រយោជន៍សោះ, ជាមនុស្សធ្មិនក្បាលស៊ីក្បាល ធ្មិនកន្ទុយស៊ីកន្ទុយ ។ មិត្តបែបនេះ មិនចេះឃកអាសានរណាទេ, មិនចេះជួយទុក្ខធុរៈនរណាទេ; បើទុកជាសន្តានពឹងពាក់ផ្តេកផ្តួល ឱបដៃ ឱបជើង សូមឲ្យជួយដោះស្រាយរឿងទុក្ខលំបាកអ្វីមួយ ក៏ពុំសម្រេចការណ៍ ព្រោះថា មិត្តរបៀបនេះ បានតែមាត់ ពាក្យចេះតែថា កើត! បាន! មិនជាអ្វីទេ! កុំព្រួយ! ចាំមើលបន្តិចទៅ! យើះ ! ទៅភ័យអី !

របៀបមិត្តនេះជាមិត្តមានសំដីក្រៅផ្អែម មានចិត្តខាងក្នុងល្វីងជូរចត់ មានចំនងត្រូវគ្នានឹងសុភាសិត "ច្បាប់ពាក្យចាស់" ថា៖

ចូលព្រៃសត្វសាហាវ ស្រែកអំពាវនាវគ្នាមកជុំ
ដល់បានស្គរទឹកឃ្មុំ ពួនសម្ងំស៊ីម្នាក់ឯង ។

៣. មិត្តនិយាយតាមបណ្តោយ និយាយតម្រូវអធ្យាស្រ័យ តម្រូវចំណុច, មិនទទឹង មិនប្រឆាំង មិនជំទាស់ ។ មិត្តនេះ បើមានកិច្ចការអ្វី គួរពិគ្រោះប្រឹក្សាជាមួយ ចេះតែអឺអើ ចេះតែពិហាអើ, ទោះ

ត្រូវក៏ដោយ ខុសក៏ដោយ, មិនហ៊ានទទឹងទាស់ឡើយ, ជាមិត្តផ្សំ យកអាមិស សម្ដីរក្ញៀក ៗ រកប្រយោជន៍ មិត្តលះពាក្យសត្យជា ពាក្យអ្នកប្រាជ្ញ បែរជាទៅកាន់យកពាក្យចាក់បណ្ដោយ ជាពាក្យ ជម្រុញឲ្យគេដើរផ្លូវអាក្រក់ ជាសំដីពាលរកខ្លឹមសារគ្មាន ៗ

៤- មិត្តស្រឡាញ់តែផ្លូវវិនាស គឺមិត្តដែលចូលចិត្តប្រព្រឹត្តអបាយមុខ តាំង ៨ ប្រការគឺ

ក- ជាអ្នកប្រព្រឹត្តល្បែងស្រី= ជាប់ចិត្តនឹងស្រីអាក្រក់ (ស្រីពេស្យាផ្កាមាស) មួយហើយមួយទៀតមិនចេះស្កប់ ទាល់តែហិនហោចខ្លួន ៗ

ខ- ជាអ្នកប្រព្រឹត្តល្បែងសុរា= អ្នកស្រវឹងខ្លួប ផឹកស៊ីៗទាល់តែរលាយខ្លួន ៗ

គ- ជាអ្នកប្រព្រឹត្តល្បែងស៊ីទំ = អ្នកដើរប្រមូលពួកម៉ាក ទៅ នំចំណីស៊ីលេងសប្បាយ. ស៊ីទាល់តែអន្តរាយខ្លួន ៗ

ឃ- ជាអ្នកប្រព្រឹត្តល្បែងស៊ីសង= អ្នកលេងល្បែងភ្នាល់ ល្បែងស៊ីសងគ្រប់ប្រភេទ លេងទាល់តែរុះរោយអស់ទ្រព្យសម្បត្តិ ៗ

ង- ជាអ្នកយកបាបមិត្តជាគ្នា= ជាអ្នកស្រឡាញ់មនុស្សខូចកាច យកតែមនុស្សខូចកាចជាពួកម៉ាក, ទាល់តែវានាំទៅធ្លាក់រណ្ដៅលាមក ៗ

ច- ជាអ្នកខ្ជិលប្រអូស= ក៏ជិលផង, ខ្ជិលស្ទើររលួយខ្លួន, ខ្ជិលទាល់តែហូតទូតទោប ៗ

ង- ជាអ្នកដើរលេងយប់= ដើរពីភូមិមួយទៅភូមិមួយ ដើរពីទីស្ងាត់មួយទៅទីស្ងាត់មួយ ដើរទាល់តែអន្តរាយខ្លួន ឬអន្តរាយដល់ប្រពន្ធ ទ្រព្យរបស់មានវិញ្ញាណឥតវិញ្ញាណឯផ្ទះ ។

ជ- ជាអ្នកដើរមើលមហោស្រព= ដើរស្ដាប់ច្រៀង មើលរបាំ មើលល្បែងផ្សេងៗ ដែលនាំឲ្យខូចសុខភាព ឲ្យខាតទ្រព្យរបស់ ឲ្យខូចអាជីវប្បវត្តិ ។

មិត្ត ៤ ពួក ដែលរៀបរាប់មកនេះ ជាមិត្តមិនត្រូវសេពគប់ មិនត្រូវរាប់អាន, លោករាប់បញ្ចូលក្នុងបាបមិត្ត ព្រោះជាមិត្តនាំឲ្យកើតទោសទុក្ខ, នាំឲ្យខូចខាតទ្រព្យសម្បត្តិ ដូចសុភាសិត ថា៖

មិត្តមួយឲ្យទោស បង្កើតជាទុក្ខ
មិត្តមួយឲ្យទុក្ខ ឲ្យបង់ទ្រព្យ ។

បុគ្គលណា ដែលប្រកបដោយលក្ខណៈអាក្រក់ មិត្តខ្វះសុជីវធម៌ លោកហាមមិនឲ្យសេពគប់រាប់គេឡើយ ។ ប៉ុន្តែ កុំយកវាជាសត្រូវ ព្រោះនាំឲ្យមានទុក្ខបសគ្គ ក្នុងដំណើរជីវិត, គ្រាន់តែស្គាល់ធម្មតា ក្នុងភេទៈជាមនុស្សដូចគ្នាបានហើយ កុំសេពគប់ស្និទ្ធស្នាលទៅទៀត ។ បើអ្នករកមិត្តល្អមិនបានទេ សុខចិត្តនៅម្នាក់ឯងទៅល្អជាង ព្រោះមានសុភាសិតផ្ដាំថា " មិត្តអាក្រក់មិនត្រូវសេពគប់ " ហើយផ្ដាំបន្ថែមទៀត ថា

« សូវនៅម្នាក់ឯងល្អជាង គួរបៀសវាងបាបមិត្ត » ។

ក្នុងការគប់មិត្តនេះ បើបង្រួមសេចក្តីឲ្យខ្លីបន្តិចមកទៀត ទំនងស្រប ទៅតាមសេចក្តីមួយវគ្គ ក្នុងស្រីហិតោបទេស ត្រង់វគ្គនៃការគប់មិត្ត នោះ មានសេចក្តី ថា

មនុស្ស គប្បីស្រឡាញ់មនុស្សដូចគ្នា គប្បីជួយយកអាសាគ្នា ក្នុង គ្រាដែលមានអាសន្នអន្ទ្រក គប្បីចែកសុខគ្នាឲ្យស្មើ កុំគប្បីក្រសោបសុខ ដើម្បីខ្លួន ហើយទម្លាក់សេចក្តីទុក្ខទៅលើអ្នកដទៃឡើយ ។ អ្នកណា ប្រកាន់ថា ជននេះជាពួកយើង ជននោះជាពួកគេ អ្នកនោះឈ្មោះថាជា មនុស្សឃើញកាលខ្លី ។ ឯអ្នកដែលមានការសិក្សាច្រើន មានចិត្ត គំនិតល្អ តែងនិយាយថា មនុស្សនៅលើផែនពសុធានេះ សុទ្ធតែជា ផៅពង្សនឹងគ្នាទាំងអស់ ។

មនុស្សធម៌នេះ ប្រពៃពិតហើយ ក៏ប៉ុន្តែ មានមនុស្សខ្លះ នៅ មុខអ្នក វាសំពះលុតក្រាបជិតបាតជើងអ្នក វានិយាយដោយសំដីទន់ផ្អែម ល្ហែមល្អួកល្អិន, នៅក្រោយអ្នក វាបេះសាច់ឆ្អឹងជំនីរអ្នកស៊ី(១), បើវា មានចន្លោះល្អ វាលូកដៃចូលទៅមួលបេះយកថ្លើមប្រមាត់អ្នកមួយរំពេច(២) ឥតបើកោតញញើតឡើយ ។ ទុជ៌នបែបនេះ ទោះបីនិយាយពាក្យពីរោះ គួរជាទីពេញចិត្ត ក៏ដោយ អ្នកមិនត្រូវយកពាក្យនោះជាហេតុ ដើម្បីធ្វើ សេចក្តីស្និទ្ធស្នាលទេ ព្រោះសំដីនោះប្រៀបដូចជាទឹកឃ្មុំដែលជាប់នៅចុង

១-២ មនុស្សពាលនៅកំបាំងភ្នែកវាហ៊ានប្រមាថមើលងាយ ។

អណ្តាត ហើយចិត្តពេញដោយពិសពុល ដ៏ក្តៅក្រហាយពេលកល ។ ខណៈណាទៅស្និទ្ធស្នាលនឹងសត្រូវ នឹងកិរិយា ដែលមិនមានចិត្តប្រតិព័ទ្ធនឹងខ្លួន ដោយគាំងថា ខ្លួនមានទ្រព្យសម្បត្តិច្រើន, នរនោះ ឈ្មោះថា មានជីវិតចូលទៅដល់ទីបំផុតនៃខត្តហើយ ( ជីវិតដែលចូលទៅដល់សេចក្តីស្លាប់ហើយ ) ។

ដូច្នេះ ការចែករំលែកមនុស្សជាមិត្តនិងសត្រូវ ជាការមួយចាំបាច់បំផុត ខានមិនបាន ។ អ្នកណា មិនលះបង់អ្នក ក្នុងគ្រាមានទុក្ខ ក្នុងគ្រាអន្តរាយ ក្នុងគ្រាទុរ្ភិក្ស ក្នុងគ្រាកស្តុចលាចល ក្នុងទ្វារព្រះរាជា និងក្នុងព្រៃស្មសាន, អ្នកនោះហើយ ជាមិត្តដ៏ល្អរបស់អ្នក ។ ចូរអ្នកយកអ្នកនោះជាមិត្តចុះ ។ (ស្រីហិតោបទេស)

ខ្ញុំពណ៌នា អំពីការគប់មិត្តសម្លាញ់នេះ ដោយមានបំណង ចង់នាំមនុស្សឲ្យដើរត្រង់ផ្លូវ រកសុខចម្រើន កុំឲ្យវង្វេងក្នុងផ្លូវខុស មានបាបគ្រោះ ព្រោះគេដឹកនាំ ។

ឯមិត្តនាំឲ្យសុខ ហៅថា កល្យាណមិត្ត និងមិត្តឲ្យទុក្ខ ហៅថា បាបមិត្ត ដែលបានពោលសង្ខេបមកនេះ សូមសាធុជនជ្រើសរើសសេពគប់ពប់គេមិត្ត ដែលនាំផ្លូវទៅកាន់សេចក្តីសុខនោះចុះ ។

ភ្នំពេញ ថ្ងៃ ៩ កើត ខែផល្គុន ឆ្នាំរោង ឆស័ក ត្រូវនឹង

ថ្ងៃ ១១ មីនា ព.ស. ២៥០៧ គ.ស. ១៩៦៤

ព្រួច-កុម

# ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគង់មង់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប.ព.

## ហេតុដូចម្ដេចក៏សុំឲ្យទេព្ដាជួយ ?

( វិចារណកថា )

លោក ជេង-ជ្រីវ រៀបរៀង

មនុស្សក្នុងលោក មិនថាជាតិណាជាជាតិណាឡើយ តែកាលណាមានភ័យ មានអាសន្ន មានគ្រោះកាច មានទុក្ខព្រួយ ឬចង់សម្រេចបំណងអ្វីច្រើន តែងអំពាវនាវ សុំឲ្យទេព្ដាជួយជាធម្មតា ។ ហេតុអ្វីក៏ចេះតែមានការបួងសួង — សំបូងសង្រួង — បន់ស្រន់ — អំពាវនាវ — ទទូចអង្វរយ៉ាងនេះ ? តាមការពិចារណា និងការត្រិះរិះឃើញថាការណ៍នេះបណ្ដាលមកពីទម្លាប់ ។ ចុះកូនក្មេងរកឲ្យទេព្ដាជួយដែរ និងថាមកពីទម្លាប់ដូចម្ដេចកើត ។ សូមជ្រាបថា គឺជាទម្លាប់កេរ្ដិ៍មរតក មានក្នុងឈាម តពីដូនតាមក មិនមែនទម្លាប់នៃជនម្នាក់ ៗ ក្នុងបច្ចុប្បន្នឡើយ ចំពោះការសុំឲ្យទេព្ដាជួយនេះ ។

សួរថា : ការសុំឲ្យទេវតាជួយ មានដើមកំណើតពីណា ?

ឆ្លើយថា : ការសុំឲ្យទេវតាជួយ បើតាមការពិចារណាដ៏ជ្រាលជ្រៅ បើតាមការសិក្សា ហើយពិនិត្យរកហេតុផល មានដើមកំណើតពីសាសនា ។

សួរថា : ក្នុងលោក សាសនាណាខ្លះពឹងផ្អែកទៅលើទេវតា ?

ឆ្លើយថា : ក្រៅពីព្រះពុទ្ធសាសនា សាសនាទាំងអស់រមែងពឹងផ្អែកទៅលើទេវតា ទុកទេវតាជាធំបំផុត ។

សួរថា : ព្រះពុទ្ធសាសនា ហេតុអ្វីក៏ខុសពីគេ មិនពឹងផ្អែកទៅលើទេវតា ?

ឆ្លើយថា : ព្រះពុទ្ធសាសនា ជាសាសនាប្រកាន់និយមតែមួយក្នុងលោក ព្រោះមេសាសនានេះ ជាមនុស្សសុទ្ធសាធ ។ មនុស្សដ៏អស្ចារ្យនេះ និយមយក " កម្ម " ( ការធ្វើ ) ទុកជាមូលដ្ឋានធំនៃសាសនា ។ ចំណែកសាសនាដទៃ ជាអាទិ៍ គឺសាសនាព្រាហ្មណ៍ គ្រិស្តសាសនា និងសាសនាឥស្លាម មិនមែននិយមយក " កម្ម " ទុកជាមូលដ្ឋានធំ នៃសាសនាឡើយ គឺនិយមយកព្រះអាទិទេពទុកជាមូលដ្ឋានធំនៃសាសនា ។ គឺថា បើខ្លួនធ្វើអំពើអកុសលហើយ ហើយដឹងខ្លួនខុស ទៅសូមលន់តួទោសនឹងព្រះអាទិទេព នោះខ្លួនត្រូវជ្រះស្រឡះចាកផលអកុសល រួចបានជាមនុស្សល្អត្រឹមត្រូវដូច

ដើមវិញពិតប្រាកដ បានសេចក្ដីថា អំពើអាក្រក់អាចលុបលាងបាន ឲ្យតែខ្លួនព្រមទទួលសារភាព យកព្រះអាទិទេព ជាទីពឹង ។ ក៏ឯព្រះពុទ្ធសាសនាវិញ មានសភាពផ្ទុយពីនេះស្រឡះ គឺថាបើខ្លួនធ្វើ "កម្ម" អាក្រក់ ត្រូវតែទទួលផលនៃ "កម្ម" នោះ គ្មានព្រះណាមកជួយបានឡើយ ព្រះពុទ្ធគ្រាន់តែជាអ្នកចែកផ្លូវ ជាអ្នកប្រាប់ផ្លូវ ប៉ុណ្ណោះ ទុំបមាដូចជាចង្កៀងអគ្គិសនីក្នុងរាត្រីកាល សម្រាប់គ្រាន់តែឲ្យយល់ច្បាស់នូវទីដែលគួរទៅ និងទីដែលមិនគួរទៅ បើខ្លួនគោរព ឬ មិនគោរព តាមការណ៍នេះស្រេចនៅលើខ្លួនជាអ្នកធ្វើ ។

សួរថា : បើដូច្នេះ ហេតុដូចម្ដេចក៏មានអ្នកព្រះពុទ្ធសាសនារកទេព្ដាឲ្យជួយដែរ ក្នុងពេលមានអាសន្ន ?

ឆ្លើយថា: អ្នកព្រះពុទ្ធសាសនា រកទេព្ដាឲ្យជួយ ដោយហេតុពីរប្រការគឺ ម្យ៉ាងដោយពួកនេះយល់ជម្រៅគោលពុទ្ធសាសនាមិនបានច្បាស់លាស់ ម្យ៉ាងដោយពួកនេះមានឈាមតពូជពីដូនតា ជាអ្នកកាន់ពាហិរសាសនា មកពីសម័យដើមយូរយារណាស់ហើយ មានសាសនាព្រាហ្មណ៍ជាដើម ដែលនិយមយកព្រះអាទិទេពបីព្រះអង្គ គឺ ព្រះព្រហ្ម ព្រះឥសូរ និងព្រះនារាយណ៍ ទុកជាមូលដ្ឋាននៃសាសនា ។

សូមបញ្ជាក់ថា : នៅពេលដែលព្រះសិទ្ធត្ថតាបស គង់លើវេនទន្លេ- មល្លក្ខ ខាងក្រោយទុក្ករកិរិយាអស់ ៦ ព្រះវស្សា វេលាព្រលប់ក្រោម

ដើមមហាពោធិព្រឹក្ស ថ្ងៃ ១៥ កើត ខែវិសាខ . . . . . . ដើម្បីការត្រាស់ដឹង ក្រុងមារាធិរាជបានមករំខានព្រះអង្គ ដោយមធ្យោ-បាយផ្សេង ៗ ពេលនោះព្រះសិទ្ធត្ថតាបស មិនបានអំពាវនាវសុំឲ្យទេវតាជួយឡើយ ព្រះអង្គអំពាវនាវចំពោះតែបារមី ៣០ ប៉ុណ្ណោះ មារាធិរាជក៏ត្រូវអន្តរាយឯង ៗ ការណ៍នេះ សឲ្យឃើញថា ក្រុមគ្រួសារព្រះពុទ្ធមិនត្រូវការពឹងផ្អែកលើទេវតាឡើយ គឺត្រូវពឹងផ្អែកតែទៅលើ « កម្ម » របស់ខ្លួនតែម្យ៉ាង ៗ អើ ! បើមេត្តាករុណាចំពោះទេវតា គឺប្រាកដជាមានមែន ព្រោះព្រះពុទ្ធសាសនា ប្រដៅឲ្យមានធម៌មេត្តាករុណាជាធំ ៗ ដូច្នេះហើយ បានជានៅពេលបំពេញកុសលម្តង ១ ព្រះពុទ្ធទ្រង់ប្រដៅអ្នកពុទ្ធសាសនា ឲ្យឧទ្ទិសផលកុសលកម្ម ដល់ទេវតាផង ព្រោះនៅស្រុកភូមិទេវតា គ្មានកន្លែងធ្វើបុណ្យទេ ៗ ចុះបើទេវតាទទួលសេចក្តីសុខតែពីយើងដែលផ្សាយទៅឲ្យ តើទេវតាមានសមត្ថ-ភាពឯណា នឹងមកជួយយើងបាន ?

ចំពោះការណ៍នេះ មានចំណោទមួយកើតឡើងថា : បើទេវតាគ្មានសមត្ថភាពនឹងមកជួយមនុស្សបាន ហេតុអ្វី កាលភិក្ខុចក្ខុបាលវង្វេងក្នុងព្រៃ ព្រោះតែសាមណេរជាក្មួយរត់ចោលដោយបណ្តាលស្នេហា បានទេវតានិមន្តមកដល់ក្រុងសាវត្ថីបានម៉្លេះ ? តាមក្នុងរឿងថា ទេវតាជាអ្នកដឹកនាំលោកមក ដ្បិតលោកងងឹតភ្នែកទាំងពីរ ៗ

មែនពិត ចក្ខុបាលភិក្ខុបានត្រូវទេវតាជួនដំណើរមកមែន តែលោក ឥតបានអំពាវនាវសុំឲ្យទេវតាជួយឡើយ គឺទេវតាជួយខ្លួនឯងទេតើ ដោយ ភ័យខ្លួន ខ្លាចមានទោស អត់ទ្រាំនៅស្ងៀមមិនបាន ក៏មកជួយលោក ព្រោះលោកជាអ្នកមានសីលបរិសុទ្ធ គឺតេជះសីលនេះហើយ ដែលទៅ ដេញទេវតាឲ្យមកជួយ ។

តទៅនេះ សូមវែកញែកនូវហេតុដែលបណ្ដាលឲ្យមនុស្សស្ទើរគ្រប់ រូប កាលណាមានទុក្ខព្រួយ តែងអំពាវនាវរកទេវតាឲ្យជួយ ។ ទម្លាប់ នេះ បើតាមការសង្កេត មានមកច្រើនរយសតវត្សហើយ ។ ក្នុង លង្វែកពុទ្ធសាសនា មនុស្សតែងតែរកអ្វីជាទីពំនឹងចិត្តរបស់ខ្លួន ម៉្លោះ ហើយ តែងយកវត្ថុផ្សេង ៗ មានទឹក ដី ភ្លើង ខ្យល់ ភ្នំ ជាដើម ទុកជា សរណៈនៃអាត្មា ។ បន្ទាប់មក មានមនុស្សខ្លះឈ្លាសវៃប៉ិនប្រសប់ខាង ពាក្យសំដីខាងវោហារ គឺតាំងខ្លួនដោយមធ្យោបាយផ្សេងៗ ជាមេធំជាដើង ព្រះ ក្នុងតំបន់នីមួយ ៗ ហើយប្រកាសយកនេះយកនោះ ទុកជាសរណៈ អាចទុកជាអ្នកខ្លាំងពូកែ អាចផ្ដល់សុខទុក្ខដល់ខ្លួន ដល់មនុស្សទាំងឡាយ ដូច្នេះហើយ ទើបមនុស្សនិយមហៅនេះហៅនោះ ដែលតាមការណ៍ពិត ជារបស់ធម្មតាសោះ ថាជា " ព្រះ " មានជាអាទិ៍ គឺព្រះអគ្គី ព្រះគង្គា ព្រះពាយ ព្រះពៃស្រព ។ មិនតែប៉ុណ្ណោះ ដូចជាសាសនាព្រាហ្មណ៍ នេះ ដែលជាសាសនាចាស់ជាងគេបំផុតក្នុងលោក បានប្រដៅមនុស្ស

ឲ្យគោរពសត្វគោ ប្រដៅឲ្យទៅមុជទឹកលាងបាប ហើយទឹកសក្តិសិទ្ធិ ដែលអាចជម្រះបាបបាន បានតែទឹកក្នុងទន្លេគង្គា ក្នុងប្រទេសឥណ្ឌា ។ ក្នុងមួយឆ្នាំ ៗ ដល់ដូវលាងបាបម្តង ៗ មានមនុស្សពពាក់ពពូនចុះទៅក្នុងទន្លេ ជួនកាលដោយមានមនុស្សច្រើនពេក មានជាន់គ្នាស្លាប់ក៏សឹងមាន ។ ខ្ញុំសូមបើកវង់ក្រចកបន្តិច : យើងអាចទុកមនុស្សអស់នេះ ជាអ្នកមានការពិចារណាខ្លះឬទេ? បើទឹកសក្តិសិទ្ធិមែន ម្តេចក៏អ្នកមកលាងបាបត្រូវស្លាប់ទៅវិញ ? ព្រោះតែចង់រស់ចង់សុខ ទើបបានមករកទឹកនេះ ។ គួរតែមេសាសនាព្រាហ្មណ៍ សើរើពិនិត្យគិតឡើងវិញនូវរឿងនេះ ការជឿអ្វីតាំងពេច នឹងជាគ្រោះភ័យដល់អាត្មា ។

ឥឡូវ ខ្ញុំបែរមកបន្តការដោះស្រាយរឿងទេព្តាទៀត ។ ខ្ញុំមិនពោលទេអំពីអ្នកពាហិរសាសនា ដែលមានការអាសន្ន តែងអំពាវនាវរកទេព្តាឲ្យជួយ ព្រោះគេជាអ្នកគោរពទេព្តាទៅហើយ ខ្ញុំសូមលើកយកអ្នកពុទ្ធសាសនា មកធ្វើការដោះស្រាយ ។

អ្នកពុទ្ធសាសនាទាំងឡាយ គួរតែសើរើគំនិតថ្មី ស្តីពីការអំពាវនាវរកទេព្តាឲ្យជួយ នៅពេលមានទុក្ខព្រួយ ។ ហេតុអ្វីបានជាថាយ៉ាងនេះ? ថាព្រោះព្រះពុទ្ធសាសនា គ្មានកន្លែងត្រង់ណា ដែលសំដែងថាកាលបើមានទុក្ខព្រួយ ត្រូវអំពាវនាវរកទេព្តាឲ្យជួយឡើយ ។ ព្រះពុទ្ធសាសនាបញ្ជាក់ថា បើមានទុក្ខព្រួយ គួរតែអំពាវនាវរក " កម្ម "

របស់ខ្លួន មានតែផលកម្មនេះហើយ ទើបអាចជួយខ្លួនបាន ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោក ។ បើអ្នកពុទ្ធសាសនា បានជាមានជាប់ឈាមខាងបន់ទេវតា ខាងអំពាវនាវរកទេវតាឲ្យជួយ តពីដូនតាមក ក្នុងពេលនេះ គួរតែធ្វើការអប់រំជម្រះឈាមមិនបរិសុទ្ធនេះចេញ ។ ការធ្វើបែបនេះឈ្មោះថាយើងញ៉ាំងពុទ្ធសាសនា ជាសរណៈស្មើដោយជីវិតរបស់យើង ឲ្យក្តឹថាឲ្យរុងរឿង ឲ្យមានស្មើចិញ្ចាចចិញ្ចៀនជាកិរិយាភាព ហើយមិនបាននាមដ៏ប្រសើរ ថាជាអ្នកពុទ្ធសាសនិក យល់ច្បាស់នូវជម្រៅដ៏ពិតប្រាកដ នូវគោលមូលដ្ឋានធំ នៃសាសនាព្រះសក្យមុនី ដែលយើងតែងតែគោរពល់ថ្ងៃនោះ ។ ព្រះពុទ្ធបរមគ្រូ ទ្រង់សំដែងថា " កម្មំ សត្តេ វិភជតិ " ប្រែសេចក្តីថា " កម្ម ( ការងារ ) បែងចែង សត្វទាំងឡាយ " គឺថាមានតែ " កម្ម " ទេ ដែលអាចប្រែងមនុស្សឲ្យក្លាយទៅជានេះ ទៅជានោះបាន ដូចជាងដែកអាចប្រែងដែក ឲ្យទៅជាវត្ថុសមតាមសេចក្តីត្រូវការបាន ។ យើងឃើញស្រាប់ហើយ សព្វថ្ងៃនេះទេវតាឯណាជួយមនុស្សកើត មានតែមនុស្សជួយខ្លួនឯង ដោយនិយមយក " កម្ម " ជាប្រមាណ ទើបបានកើត ។ ព្រោះទេវតា តាមការណ៍ពិតជាលទ្ធផលនៃកុសលកម្មរបស់មនុស្សទេ បាយទឹក ត្រីសាច់ សំពត់អាវ ផ្ទះសំបែង ។ល។ មិនដែលកើតពីទេវតាឡើយ គឺកើតឡើងតែពីមនុស្សធ្វើទាំងអស់ គួរដែរឬ កាលណាមានទុក្ខព្រួយ បែរទៅអំពាវនាវរកទេវតាឲ្យជួយវិញ ។

មួយកន្លែងទៀត ព្រះពុទ្ធបរមគ្រូ ទ្រង់ត្រាស់យ៉ាងច្បាស់ថា ៖

អត្តា ហិ អត្តនោ នាថោ
កោ ហិ នាថោ បរោ សិយា
អត្តា ហិ សុទន្តេន
នាថំ លភតិ ទុល្លភំ

ប្រែថា : ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃ នឹងជាទីពឹងដូចម្ដេចកើត បើយើងមានខ្លួនទូន្មានល្អហើយ ឈ្មោះថាបាននូវទីពឹង ដែលអ្នកដទៃរកបានដោយលំបាក ។ បណ្ដាគាថាទាំងបួនបទនេះ ខ្ញុំយកតែពីរបទខាងចុងមកធ្វើអត្ថាធិប្បាយ ។ ពាក្យថា " បើយើងមានខ្លួនទូន្មានប្រពៃហើយ ឈ្មោះថាបាននូវទីពឹង ដែលអ្នកដទៃរកបានដោយលំបាក " បានសេចក្ដីថា បើយើងយល់ត្រូវហើយ គឺថាដឹងផ្លូវល្អ ផ្លូវចំរើនដែលគួរដើរតាម នឹងផ្លូវអាក្រក់ ផ្លូវប្រាសចាកអត្ថប្រយោជន៍ ដែលមិនគួរដើរតាមហើយ ឈ្មោះថាយើងមានទីពំនាក់ដ៏កម្រ ដែលអាចផ្ដល់សេចក្ដីត្រូវការមកយើង បានគ្រប់ពេលវេលា ឧបមាដូចអ្នកលង់ទឹករមែងត្រូវការទូកជាទីពឹង ដូចសត្វហើរកណ្ដាលទីវាលកន្តារៈ រមែងត្រូវការដើមឈើជាទីពឹង ដូចបក្សីហើរឆ្លងសមុទ្រ រមែងត្រូវការកោះជាទីពឹង ។

សួរថា : យ៉ាងដូចម្ដេច ហៅថា " យល់ត្រូវ " ?

ឆ្លើយថា: "យល់ត្រូវ" នោះគឺយល់ថា ព្រះពុទ្ធសាសនា ប្រាកដជា

និយមយក “ កម្មផល ” ទុកជាគោលមូលដ្ឋាន ជាសាសនាប្រកាន់និយមតែមួយគត់លោក នេះហៅថា “ យល់ត្រូវ ” ។ បើយើងតាំងខ្លួនជា ស្រឡាញ់កប់អានព្រះពុទ្ធ តែយើងមិនគោរពព្រះឱវាទរបស់ព្រះអង្គ តើការស្រឡាញ់កប់អាននោះនឹងមានលទ្ធផលម្ដេចកើត ? បើយើងប្រកាសថា អ្នកនេះអ្នកនោះជាមាតាបិតារបស់យើង តែយើងមិនស្ដាប់ពាក្យប្រៀនប្រដៅដ៏ល្អរបស់លោក តើសេចក្ដីប្រកាសនេះ មានន័យដូចម្ដេច ? បើយើងពោលថា អ្នកនេះឬអ្នកនោះជាទីពឹង ជាមគ្គុទ្ទេសក៍របស់យើង តែបើយើងមិនព្រមអនុវត្តយ៉ាងម៉ត់ចត់នូវបទបញ្ជារបស់អ្នកនោះ តើការពោលនេះ នឹងមានខ្លឹមសារឬទេ ?

សូមបញ្ជាក់បន្ថែមថា “ កម្ម ,, ជាគោលមូលដ្ឋាននៃព្រះពុទ្ធសាសនា ។ ចុះបើអ្នកពុទ្ធសាសនា កាលណាមានទុក្ខព្រួយ កាលណាមានភ័យ មិនរក “ កម្ម ,, បែរទៅរក “ ទេព្តា ,, វិញ តើនឹងអាចទុកអ្នកទាំងនេះ ថាជាអ្នកពុទ្ធសាសនាត្រឹមត្រូវដូចម្ដេចបាន? បើតាមសច្ចៈយុត្តិធម៌ នឹងអាចរាប់បញ្ចូលអ្នកទាំងអស់នេះ ទៅក្នុងស្បាងក្រុមអ្នកក្បត់នឹងពុទ្ធសាសនា ក៏សឹងបានទៅវិញ ។ តែក្នុងលោកនេះតែងមានអ្នកយល់ខុស យល់កន្តប្រច្រឡំពុំខាន មិនដែលថាមិនមានការកន្តប្រច្រឡំនោះទេ ។

ដូច្នេះហើយ គួរតែអស់លោកអ្នកយល់កន្តប្រច្រឡំក្នុងរឿងព្រះពុទ្ធ-

សាសនាកែប្រែចិត្តគំនិតដោយការចំរៀនទម្លាប់ចិត្តបែរមករកផ្លូវត្រូវ ផ្លូវពិតផ្លូវមែនឡើងវិញ ព្រោះការគោរពទេព្ដា ជាសាសនាក្រៅដទៃ មិនមែនកប់ចូលក្នុងព្រះពុទ្ធសាសនាឡើយ ។ ព្រះពុទ្ធសាសនាប្រដៅឲ្យគោរព "កម្ម" ព្រោះ "កម្ម" នេះ មានមហិទ្ធិរិទ្ធិអាចញុំាងអ្វី ៗ ឲ្យសម្រេចបានទាំងអស់ ៖ វឌ្ឍនភាព ការរុងរឿង និង សន្តិភាព សុទ្ធសឹងជាលទ្ធផលនៃ "កម្ម" ។ អន្តរាយគ្រប់បែបយ៉ាង មានអសន្តិសុខ សង្គ្រាម ការធ្លាក់ទៅអបាយភូមិ សុទ្ធសឹងជាលទ្ធផលនៃ "កម្ម" នេះដែរ ។ មិនតែប៉ុណ្ណោះ តាមសង្កេតឃើញតប់ មានវិហារពុទ្ធសាសនាខ្លះ មានកុដិភិក្ខុសង្ឃខ្លះ ទុកជាអាស្រមនៃទេវរូបក៏មាន ។ ការប្រព្រឹត្តបែបនេះនៃអ្នកពុទ្ធសាសនា ជាអំពើធ្ងន់ក្រៃលែង ជាសេចក្ដីប្រមាថដ៏ឥតសមហេតុផល ។ ព្រះពុទ្ធសាសនាដែលគួរតែពុទ្ធបរិស័ទសើរើពិនិត្យកែសម្រួលឲ្យសមនឹងត្រឹមត្រូវតាមព្រះពុទ្ធឱវាទ ទើបប្រសើរ ។

# ពិចារណាដើម្បីយល់តក្កវិជ្ជា

(ត)

លោក ហ៊ុន តិមសៀ រៀបរៀង

អ្នកប្រាជ្ញអក្សរសាស្ត្របានអះអាងថា : " ភាសាគឺជាបាតុភូតជាក់ស្តែងនៃសតិអារម្មណ៍ " ពីព្រោះសតិអារម្មនិងភាសារបស់មនុស្ស វាលូតលាស់ទៅជាមួយគ្នា ៗ ក្នុងដំណើរនៃការចលនាវិវត្តន៍របស់គំនិត ភាសាវាមានសារៈសំខាន់ណាស់ ក្នុងការបញ្ចេញគំនិតឲ្យឃើញជាក់ស្តែងមកក្រៅ ៗ យើងទាំងអស់គ្នាល្បងគិតនៅក្នុងខួរយើងរាល់គ្នាមើលហើយ, យើងអាចយល់បានភ្លាមថា : ក្នុងសតិអារម្មណ៍ ដែលយើងកំពុងគិតនោះក៏មានខ្លួនភាសាយកទៅពិចារណាដែរ ដែលយើងហៅថា : កម្មវត្ថុរឿង ៗ

ខ្ញុំគិតថា : កសិកម្មនៅក្នុងប្រទេសយើង បើមិនឆាប់ក៏យូរ មុខតែបានរីកចំរើន ៗ ខ្ញុំគិតក្នុងខួរក៏ដូចជាខ្ញុំនិយាយ ឬសរសេរដែរ ៗ ដូច្នេះ យើងទាំងអស់គ្នាយល់បានថា : សតិអារម្មណ៍យើង វាទៅដល់ណា ភាសាយើងក៏អាចទៅដល់នោះ បានដែរ ៗ ហេតុនេះហើយបានជាជីវភាពរបស់យើងទាំងអស់ ផ្នែកខាងស្មារតី ទោះបីជ្រាលជ្រៅយ៉ាងណា ក៏សំដីនិយាយឬភាសា វាអាចបកស្រាយបានទាំងអស់ ៗ

ភាសា គឺជាសំដីនិយាយដែលអាចកត់ត្រាបាន ៗ សំដីនិយាយ

មួយម៉ាត់ ៗ គឺជាសញ្ញាសំកប់សំគាល់ទស្សនៈ ខាងផ្នែកតក្កវិជ្ជា គេហៅថា : “ ទស្សនៈ ” ចំណែកខាងភាសា ហៅថា : “ ពាក្យ ” ៗ

ឧទាហរណ៍ : ផ្កាម្លិះ ៗ ផ្កាម្លិះគឺជាទស្សនៈមួយ នៃប្រភេទផ្កាមួយយ៉ាង ៗ ផ្កាម្លិះគឺជា “ ពាក្យហៅ ” ផ្កាសំដៅរូបភាពខាងក្រៅ ចំណែកឯទស្សនៈ គឺជាអត្ថរសខាងក្នុង ៗ ពីព្រោះហេតុនេះហើយ បានជាយើងយល់ថា : ទស្សនៈនិងភាសាហាក់មានការទាក់ទងគ្នាជិតដិតណាស់ ហើយវាវិវត្តទៅតាមគ្នាថែមទៀតផង ៗ ប៉ុន្តែមិនមែនពីព្រោះតែដូច្នេះ ហើយទៅថាច្រឡំបល់ រវាង ទស្សនៈនិងភាសា បានទេ ៗ ការពិតទស្សនៈនិងភាសាខុសប្លែកគ្នាឆ្ងាយណាស់ ៗ ទស្សនៈ គឺជាការដឹង ឬការយល់ចំពោះវត្ថុមួយ; ចំណែកឯភាសាគ្រាន់តែជាការយល់ព្រម សុខចិត្តប្រើតាមទាំងអស់គ្នា ដែលទៅជាទម្លាប់ប៉ុណ្ណោះទេ ៗ

ឧទាហរណ៍ ដូចជា: ទស្សនៈ “មនុស្ស” គឺគេនិយាយដល់មនុស្ស បើប្រសិនចាស់ពីដើម ប្រើពាក្យថា “កុយ” សម្រាប់ហៅថាមនុស្ស ក៏យើងមិនដឹងធ្វើម្តេចដែរ យើងត្រូវតែហៅតាម “ កុយ ” ជំនួសពាក្យថាមនុស្សដែរ ប៉ុន្តែចំណែកទស្សនៈវិញ គឺមិនប្រែប្រួលទេ គឺនៅតែមនុស្សដដែល ទោះហៅ “ កុយ ” ឬហៅ មនុស្ស ក៏ដោយ ៗ

ដូចរឿង : លោកគ្រូធំនាំសិស្សពីលើភ្នំចុះមកទីក្រុង ( សិស្សទាំងនោះ មិនដែលចុះមកម្តងសោះតាំងពីកើតមក ) មកដល់ខាងក្រោម

ឃើញស្រីល្អ សិស្សសួរលោកគ្រូថា : ស្អីហ្នឹងច្រើនម្ល៉េះ ? ។ គ្រូឆ្លើយថា : ខ្ញា ។ គំនិតលោកគ្រូចង់ឆ្លើយថាដូច្នេះ ពីព្រោះចង់ឲ្យសិស្សខ្លាច ។ ដល់ត្រឡប់ឡើងទៅលើវិញ លោកគ្រូសួរសិស្សថា : កាលចុះទៅក្រោម ឯងទាំងអស់គ្នាចូលចិត្តអ្វី? ។ សិស្សឆ្លើយថា: ខ្ញុំចូលចិត្តខ្ញាណាស់ ។ ហេតុនេះបានជាយើងយល់ថា : ពាក្យសំដីគ្រាន់តែជារូបភាពផ្លាស់ប្តូរបាន តែមិនអាចដូចទស្សនៈបានទេ ហើយជាងនេះទៅទៀត ពាក្យសំដីច្រើនបែប អាចឲ្យខុសនាមបានតែទស្សនៈមួយប៉ុណ្ណោះទេ ឧទាហរណ៍ដូចជា : ទស្សនៈ " ក្តៅពេញ " ។ គេអាចហៅថា : កង់ធានក៏បាន គឺក្តៅពេញហ្នឹងហើយ គេអាចហៅថា " ក្តៅពេញ ,, ក៏បាន ។ ចាស់ពីដើមមានប្រើពាក្យច្រើនណាស់ ដូចជា គីគា, ផ្ទះសម្បែង . . . ។ល។ ផ្ទុយទៅវិញ ក្នុងករណីខ្លះ ក៏មានពាក្យមួយម៉ាត់ ហើយឲ្យខុសនាមទស្សនៈបានច្រើនដូច្នេះដែរ ពីព្រោះពាក្យយើងមួយម៉ាត់មានន័យច្រើនយ៉ាង ។

ដល់មកត្រង់នេះទើបយើងទាំងអស់គ្នាយល់ថា : ការនិយាយពាក្យសំដីខុសគ្នាបន្តិចបន្តួច : អ្នកខ្លះហៅ " ខ្ទរ ,, អ្នកខ្លះហៅ " ខ្ទោ ,, ( ចំពោះពាក្យសំដីនិយាយ ) ពុំមិនខុសត្រូវអ្វីប៉ុន្មានទេ ឲ្យតែគេសរសេរអក្សរត្រូវ មានទស្សនៈត្រូវ ទុកជាការហើយ កុំប្រកាន់ច្រើនពេក ព្រោះបើប្រកាន់ឃើញថាប្រែត្រូវហើយ មានទស្សនៈត្រូវគ្នាគឺទុកជាបានការ ។

## គ_ លក្ខណៈឯកឯង និង លក្ខណៈទូទៅ

និយាយដល់លក្ខណៈឯកឯង និង លក្ខណៈទូទៅ មានមិត្តអ្នកអានភាគច្រើនច្ងល់ថា: តើគេចង់និយាយអំពីរឿងអ្វី ។ ការពិត នៅក្នុងរឿងតក្កវិជ្ជាមានគំនិតបែបនេះ ដែលគេហៅថា " ពាក្យសម្រាប់ប្រើនៅក្នុងតក្កវិជ្ជា " ។

លក្ខណៈឯកឯងគឺយ៉ាងណា ?

ទស្សនទិយមនីមួយ ៗ ( Concepts ) ក៏មានលក្ខណៈពីរយ៉ាង ។ លក្ខណៈទី ១ យើងហៅថា " លក្ខណៈឯកឯង " លក្ខណៈទី ២ ហៅថា " លក្ខណៈទូទៅ " ។ លក្ខណៈឯកឯង គឺតែនោះជាអ្វី ? ជាតែយ៉ាងដូចម្តេច ? ។

លក្ខណៈទូទៅគឺយ៉ាងណា ?

គឺជាតែនោះ មានលក្ខណៈដូចគ្នានឹងតែដទៃច្រើនទៀត ។

ឧទាហរណ៍: សត្វឆ្កែ ។ លក្ខណៈឯកឯង គឺជាសត្វឆ្កែតែមួយយ៉ាង មិនមែនជាសត្វណាដទៃទៀត ។ ចំណែកឯលក្ខណៈទូទៅ គឺសត្វឆ្កែក៏មានជើងបួន មានចង្កូម. . . ដូចជាសត្វជាច្រើនឯទៀត ។

ឧទាហរណ៍មួយទៀត : ដូចជាមនុស្ស ។ លក្ខណៈឯកឯងរបស់វាគឺជាសត្វចេះគិតពារណាចេះបង្កើត ឧបករណ៍ដើម្បីប្រើប្រាស់ ។ល។ លក្ខណៈទូទៅរបស់វា គឺមនុស្សចេះដើរ ចេះដេក ចេះស៊ី ដូចជា

សត្វដទៃ ៗ ដូចជាផ្លែចេក, ផ្លែស្វាយ, ផ្លែល្ហុង, ផ្លែប៉េងប៉ោះ ។ល។ លក្ខណៈទូទៅ គឺផលតាំងអស់នេះសុទ្ធតែជា "ផ្លែ", ដូចគ្នា ប៉ុន្តែ លក្ខណៈឯកឯងគឺផ្លែល្ហុងខុសពីផ្លែស្វាយ ផ្លែប៉េងប៉ោះក៏ផ្សេងពីផ្លែចេក គឺថាវាមិនដូចគ្នាទេ ។

និយាយសង្ខេបមកយើងយល់ថា : វត្ថុ សម្ភារៈ នីមួយ ៗ ដែល មនុស្សយើងយល់ថាមានលក្ខណៈពីរយ៉ាងគឺ : លក្ខណៈឯកឯងនិង លក្ខណៈទូទៅ ដូចយើងបានអធិប្បាយខាងលើ ។

## ឃ-ការទាក់ទងរវាងលក្ខណៈទូទៅនិងលក្ខណៈឯកឯង

លក្ខណៈទូទៅ និង លក្ខណៈឯកឯង ក៏មានការទាក់ទងគ្នាជិតជិតណាស់ គឺវាទាក់ទងគ្នាតាមមាត្រដ្ឋាន (échelle) ផ្សេង ៗ ឧទា: មនុស្ស ១០ នាក់ស្ទូងស្រូវ កង ១០ ថ្ងៃហើយបានស្រែមួយ, ចុះបើមនុស្សតែ ៥ នាក់វិញ តើស្ទូងកងប៉ុន្មានថ្ងៃបានហើយ ? មនុស្សស្ទូងកាន់តែច្រើន ពេលវេលាហើយ កាន់តែខ្លី, មនុស្សស្ទូងកាន់តែតិច ពេលវេលាហើយ កាន់តែវែង ។ ឥឡូវយើងត្រឡប់មកបញ្ហាយើងវិញ ដើម្បីឲ្យយល់អំពីការទាក់ទងរវាងលក្ខណៈទូទៅនិងលក្ខណៈឯកឯង យើងសូមលើកឧទាហរណ៍ : ទស្សនិយម " សត្វលោក " ។ សត្វលោករួម មាន មនុស្ស, ឆ្កែ, ឆ្មា, ជ្រូក, មាន់ . . . ។ល។ ហេតុអ្វី

ក៏សត្វលោករួមមានច្រើនម៉្លេះ ? ពីព្រោះលក្ខណៈទូទៅរាប់ធំទូលាយពេក ។ ហេតុអ្វីក៏លក្ខណៈទូទៅរាប់ធំទូលាយពេកដូច្នេះ ?

ពីព្រោះលក្ខណៈឯកឯងរាប់រួមមានតិចពេក ។ សត្វលោក គឺជាសត្វឲ្យតែមានជីវិតចេះមានចលនានៅលើផែនដី គេហៅថា: សត្វលោក ហើយដើរក៏បាន, លូនក៏បាន, លោតក៏បាន, ស៊ីបាយក៏បាន, ស៊ីស្មៅក៏បាន, ស៊ីសាច់ក៏បាន, កើតជាកូនក៏បាន, កើតជាពងក៏បាន . . .

ប៉ុន្តែ ផ្ទុយទៅវិញ បើយើងថែមលក្ខណៈមួយដូចជា « មានដោះ » ទៅលើលក្ខណៈទូទៅខាងនោះ គឺថា « សត្វលោកមានដោះ » ដូច្នេះ ចំនួនលក្ខណៈទូទៅរាប់រួញតូចមកវិញ គឺថា មានតែមនុស្ស, ឆ្កែ, ជ្រូក... ទេ ចំណែកពស់ ឬ មាន់ . . . មិនអាចរាប់បញ្ចូលផងបានឡើយ ។ ផ្ទុយទៅវិញ មើលលក្ខណៈឯកឯងរាប់កាន់តែច្រើនឡើង ដូចជាយើងបន្ថែមលក្ខណៈត្រង់ „ ចេះពិចារណា „ ។ គឺថា : ទស្សនទិយម « សត្វលោក » តែសត្វលោកមានដោះ និង ចេះពិចារណា » គឺមានតែមនុស្សមួយគត់ប៉ុណ្ណោះ ។

## ង. ទស្សនៈពូជ និង ទស្សនៈបំពូក

ក្នុងពេលពិចារណាប្រធាន គំនិតរបស់មនុស្ស មានទទួលទស្សនៈមួយគឺប្រធាននោះឯង ។ ប៉ុន្តែនៅក្នុងចក្រវាឡ វត្ថុនេះរាប់មានការ

ទាក់ទងនឹងវត្ថុនោះ សម្ភារៈនេះក៏មានការទាក់ទងនឹងវត្ថុនោះ ៗ ការចេះដឹងរបស់មនុស្សក្នុងមួយថ្ងៃ ៗ ក៏ចេះតែរីកធំឡើង ព្រោះហេតុនេះហើយ បានជា ចំពោះទស្សនៈមួយមនុស្សមានការពិចារណាឲ្យធំទូលាយ ហើយយល់ទៅដល់វត្ថុផ្សេងដទៃទៀត ដែលមានសភាពប្រហាក់ប្រហែលគ្នា ៗ បានសេចក្តីថា : ការពិចារណារបស់មនុស្សចំពោះវត្ថុនីមួយៗ ក៏អាចនាំឲ្យយើងយល់បានវត្ថុទូទៅ ប៉ុន្តែផ្ទុយទៅវិញ បើយើងពិចារណា យល់វត្ថុទូទៅបានហើយ យើងក៏អាចយល់បាននូវវត្ថុរៀង ៗ នីមួយ ៗ បានដែរ ៗ និយាយយ៉ាងនេះ គឺយើងចង់និយាយអំពីការលូតលាស់នៃការពិចារណារបស់មនុស្ស ។ ក្នុងការចលនាពិចារណាលូតលាស់របស់មនុស្ស មានទស្សនៈខ្លះក៏ទូទៅ និងមានទស្សនៈខ្លះក៏មិនទូទៅទេ ៗ និយាយពាក្យថា : ទស្សនៈទូទៅ និងទស្សនៈមិនទូទៅ យើងនិយាយតែអំពីទស្សនៈ ដែលមានលក្ខណៈទូទៅណាដែលក៏ដូចគ្នា ៗ បើលក្ខណៈទូទៅនោះមិនដូចគ្នា គឺយើងមិននិយាយដល់ទស្សនៈទូទៅឡើយ យើងហៅថា " ទស្សនៈតូច ", ទស្សនៈមិនទូទៅ យើងហៅថា " ទស្សនៈចំពូក " ៗ

ឧទាហរណ៍ :– " ទីក្រុង " – " រាជធានី ", – " ភ្នំពេញ " " ភ្នំពេញ ", – " រាជធានី ", – " ទីក្រុង ", ទាំង ៣ នេះ គឺជាទស្សនៈ ដែលមានលក្ខណៈទូទៅ គឺពាក្យថា "ទីក្រុង", ពីព្រោះទីក្រុង ក៏អាចរួមលក្ខណៈទាំងភ្នំពេញ ទាំងរាជធានី បាន ៗ

ទីក្រុងក៏ទូលាយជាងរាជធានី ពីព្រោះទីក្រុងទាំងអស់មិនមែនសុទ្ធតែរាជធានីនោះទេ ។ ស្វាយរៀង, ព្រៃវែង, ក្រចេះ ក៏ជាទីក្រុងដែរ ។ រាជធានីទាំងអស់គឺជាទីក្រុង ភ្នំពេញគឺជាទីក្រុង ។ ដូច្នេះ យើងយល់ថា : ទស្សនៈ " ទីក្រុង ,, ក៏ទូលាយជាង " ធានី ,, ព្រោះហេតុនេះ យើងត្រូវហៅថា" ទស្សនៈពូជ ", ចំណែកឯ" ធានី ,, ក៏ចង្អៀតជាង " ទីក្រុង ,, យើងហៅថា : " ទស្សនៈចំពូក ,, ។

ឥឡូវយើងនិយាយដល់ " រាជធានី " និង " ភ្នំពេញ ,, ម្តង ។ ទស្សនៈ "រាជធានី" ក៏ទូលាយជាងទស្សនៈ "ភ្នំពេញ" ។ ហ្លួងប្រាបាងជារាជធានី, ឡុងដ៍ជារាជធានី, បាងកកជារាជធានី, ភ្នំពេញជារាជធានី, ប៉ុន្តែបើត្រឹមតែភ្នំពេញ គឺបានន័យតែមួយប៉ុណ្ណោះ ។ ដូច្នេះនិយាយសង្ខេបមក យើងយល់ថា " ទស្សនៈពូជ ,, ក៏ទូលាយជាងទស្សនៈចំពូក ។ ទស្សនៈពូជ ដូចគ្នានឹងលក្ខណៈទូទៅ ទស្សនៈចំពូក ដូចគ្នានឹង លក្ខណៈឯកឯង ។

(នៅមានត)

អ្នកធ្វើ តែងតែមានខុស, មានតែអ្នក
ឱបដៃចាំតែថាទេ ដែលមិនចេះខុស ។

ល.ហ.អ.

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

( ត )

*ព្រះមហា ចាំង-ខាត់ រៀបរៀង*

---

–រូប បុំ. អន្យរូប កិរិយាក្លែងខ្លួន, ប្រដាប់សម្រាប់ក្លែងខ្លួន, គុ. ដែលមានរូបមួយទៀត ដែលបន្លំ; អន្យរូបិន ដូចគ្នា ។ –លោក្យ គុ. ដែលជាអន្យលោក ។ –វណ៌តា ស្ត្រី. ភាពនៃ...មានពណ៌ ឬ វណ្ណមួយទៀត ។ –ស្ត្រីគ ស្ត្រី អន្យស្ត្រីគ អ្នកលួចប្រពន្ធអ្នកដទៃ ។ អន្យាទ្ឫឝ៑ គុ. ដែលយល់ឃើញផ្សេង, ប្លែក; –ទ្ឫឝ ដូចគ្នា ។ អន្យេទ្យុស ក្រ.វិ ថ្ងៃតទៅ, ថ្ងៃមួយ ។

អន្យឞ្ដ្យ បុំ សត្រូវ ។

អន្យតា ស្ត្រី. ភាពផ្សេងគ្នា ។

អន្យត្រ ក្រ.វិ. ទៀតតែ, លើកលែងតែ, មួយទៀត ។ –មនស៑ គុ. ដែលមានចិត្តមួយទៀត ។

អន្យថា ក្រ.វិ ដោយប្រការផ្សេង ផ្សេងពី, ដោយខុស, ពុំនោះទេ ។ អន្យថ-

ភូ ផ្លាស់ប្តូរ, អន្យថ-ក្រ ធ្វើដោយខុស កែប្រែ បន្ទុស ។

-ពុទ្ធិ ស្ត្រី. អនយពុទ្ធិ គំនិតខុស, យោបល់ខុស ។

-ភាវ បុំ អន្យភាព កិរិយាផ្លាស់ប្តូរ ។ -វាទិត្វ នបុំ.

ភាវនៃកិរិយាថ្លែងដោយប្រការដទៃទៀត ។ -វ្រត្តិ ស្ត្រី.

អន្យព្រឹត្តិ គុ. ដែលប្រព្រឹត្តិទៅផ្សេង ។ -វ្រត្តិចេ-

តសិ គុ. ដែលមានចិត្តប្រព្រឹត្តទៅផ្សេង ។ -សំភា-

វិន គុ. ដែលមានក្តីសង្ស័យ ។

អន្យទា ក្រ.វិ. ក្នុងខណៈដទៃ, ថ្ងៃមួយ ។

អន្យទីយ គុ. អន្យទីយ ដែលជារបស់អ្នកដទៃ ។

អន្យាយ បុំ. វិធីមិនទៀងទាត់ ។ -តសិ ដោយមិនទៀងទាត់ ។

-វ្រត្តិ ស្ត្រី. កិរិយាប្រព្រឹត្តមិនទៀងទាត់, គុ. ដែល

ប្រព្រឹត្តមិនទៀងទាត់ ។ អន្យាយិន គុ. ដូចគ្នា ។

អន្យាយ្យ គុ. ដែលមិនស្មើគ្នា ។

អនូយ គុ. ដែលមិនបន្ថយ, គ្រប់គ្រាន់ ។ –អនូនាធិក គុ. ដែលមិនតិចមិនច្រើន ។

អន្យោន្យ គុ. ទៅវិញទៅមក ។ –ក្ឫត្យ នបុ. អន្យោន្យក្ឫត្យ, សេវា ទៅវិញទៅមក ។ –គត គុ. ដែលដល់គ្នាទៅវិញទៅមក។ –ធម្មិ គុ. ដែលមានធម៌ទៅវិញទៅមក ។ –ប្រេមន៍ នបុ. អន្យោន្យប្រេម ប្រេមទៅវិញទៅមក ។ –ភាវ បុ. អន្យោន្យភាព, កិរិយាប្ដូរទៅវិញទៅមក ។

អន្វក ក្រ.វិ. ពីខាងក្រោយ, ដោយខាងក្រោយ ។

អន្វក្ប គុ. ដែលដើរតាមក្រោយ ។ អន្វក្បមិ ដោយប្រកិត ។

អន្វធិវតិ ក្រ.វិ. ដោយបណ្ដោយតាមជនសួងអធិវតី ។

អន្វញ្ច ធាតុ ដើរតាមក្រោយ, ហែហម ។

អន្វបជា ធាតុ បាត់ទៅតាមគ្នា ។

អន្វភិសិច ធាតុ ប្រោសព្រំដោយ ។

អន្វយ បុ. អន្វយ៍, កិរិយាតគ្នា, កូនចៅ, គ្រួសារ ។ ចំណង ។

សម្ពន្ធពាក្យ ។ _វន្តិ គុ. ដែលសម្ពន្ធគ្នា, ដែលកើត

មកតគ្នា ។ _អន្វយោគត គុ. ដែលត្រូវមានមតិក ។

អន្វិបិ គុ. ដែលមានសេចក្តីតាមលំដាប់ ។ ដែលត្រឹមត្រូវតាមន័យ ។

_តស៑ ដោយន័យរបស់សព្ទ ។ -សំជ្ញ គុ. ដែល

នឹងច្បាស់តាមន័យរបស់សព្ទ ។

អន្វិក្ខ ធាតុ សាបព្រោះទូទៅ ។

អន្វិក្រម៑ ធាតុ ចុះតាមលំដាប់ ។

អន្វិរុហ៑ ធាតុ ទៅដល់, ឡើងកាន់តាមគ្នា ។

អន្វិសា ធាតុ ស្អិត, ជាប់ទៅ ។

អន្វិភយ បុ. អន្វភយ, ពូជ, កូនចៅ ។

អន្វិភជ៑ ធាតុ ធ្វើឲ្យឈឺចាប់ ។

អន្វិវេ (ត៑) ធាតុ កូល, សន្សំ, ផ្ទាក់ក្នុង ។

អន្វេក្ស (ក្ស៑) ធាតុ សំឡឹងមើល, ពិចារណា ។

(នៅមានត)

# ព្រះរាជនិពន្ធរាមកេរ្តិ៍

ភាគ ១២

(ក)

លោក ឆឹក-ណាម

ស្រាវជ្រាវ និង រៀបរៀង

កាលណោះ ព្រះបាទក្រុងពាលីរ៉ៃក្រៃក្រទ័យគង់នៅទីសីហបញ្ជរ នោះ លុះបានឮទូរគីយុទ្ធក្របីស្តីពាក្យថាដូច្នោះហើយ ពុំលង់ឡើយ ក៏ក្រេវក្រោធប្រឡោតខ្លាំងណាស់ ក៏ស្ទុះយ៉ាងរហ័សចាប់យកព្រះខ័នជ័យ ដ៏មុតថា យាត្រាចុះតាមប្រាសាទកែវមណី សម្តែងរិទ្ធិចូលដាញជ័យ ហោង ។

កាលណោះ កំហែងទូរគីរិទ្ធិក្លា ក៏ហោតចូលទៅតតាំងច្បាំងទប់ ទល់មួយរំពេចខ្ចី យុទ្ធក្របីក៏សម្តែងរិទ្ធិច្បាំងគ្នាទៅវិញទៅមក ទាំងពីរ នាក់សុទ្ធតែពូកែមានរិទ្ធិចំណាប់ អ្នកមួយកាប់ អ្នកមួយការ គេចវៃ វិលវល់ មិនគិតដល់ជីវិតទាំងសងខាងឡើយ ។ ហើយកាលណោះ ពាលីមានរិទ្ធិក្លាហាន បានតរិទ្ធិនឹងទូរគី តាំងតែពីវេលាព្រឹក លុះដល់ វេលាថ្ងៃសៀលល្ងាច ទើបគិតថា ការសេះ មានរិទ្ធិក្លាហានមហិមា ជាជាងអាទសកណ្ឋអសុរ ឥឡូវនេះ អញនឹងកាប់សម្លាប់វាកណ្តាលវាល ឃើញមិនបាន ហើយចុះ មានតែអញនេះនឹងគិតល្បងល្បួងបញ្ឆោត

រកចូលទៅច្បាំងគ្នាក្នុងគុហាថ្មវិញ ប្រហែលឃើញជាក់ទាល់ទ័ននឹងគេច ការ ក៏អញនេះនឹងឆាយកាប់សម្លាប់ឲ្យស្លាប់ហោង ។ គិតហើយពាលី ក៏មានពាក្យទៅថា ម្នាលទូរគីទ្វីក្លាហាន ប្រុកណាយើងទាំងពីរនាក់នេះ ច្បាំងគ្នាមក មិនឃើញចាញ់ឈ្នះគ្នា អ្នកក៏មានរិទ្ធិ យើងក៏មានរិទ្ធិ ល្មម យើងទាំងពីរនេះជំនួនគ្នាបាន ប្រមាណកម្លាំងរិទ្ធិប្រហែលគ្នា បើមិនទូរគី ឯង ក៏អញ គង់នឹងចាញ់ឈ្នះគ្នាដល់មរណាមួយៗ ពុំលែងឡើយ ដែល នឹងរួចរស់ជីវិតនោះគ្មានទេ កុំសង្ស័យ... ឥឡូវនេះ ថ្ងៃក៏អស្តង្គតផុត សែនស្មើ ចូលកត្រីដល់ពេលងងឹតហើយ ឈប់ចុះ ឯងចូរត្រឡប់វិល ទៅផ្ដាំអស់ហ្វូងបរិវារឯងចុះ ខាងអញនោះ ក៏នឹងវិលទៅផ្ដាំអស់ពួកបរិវារ ពល ទូវស្រីស្នំក្រមការអញហោង, ព្រឹកឡើង សឹមយើងទាំងពីរនាក់ មកច្បាំងគ្នាទៀត ក្នុងទីគុហាកែវសូរ្យកាន្ត ឲ្យបានកំបាំងភ្នែកមនុស្ស និងគ្រុធារវិជ្ជាធរកិន្នរនាគ អារក្សទេព្រក្សទាំងឡាយ ថាបើអ្នកណាអន្តរាយ ក្ស័យជីវិត ក៏មិនសូវខ្មាសគេផង ទាំងពលបរិវារទាំងពួងហោង ។

## សូមជំរាបអ្នកអាន

ដោយហេតុរឿងភមរក្តើវែងពន់ពេក មានរហូតទៅ ១១៧ ភាគ ដែលយើងចុះផ្សាយមក អស់បីឆ្នាំហើយ បានត្រឹមតែ ១២ ភាគនោះ, អ្នកស្រាវជ្រាវបានសុំយករឿងនេះទៅចុះផ្សាយ ក្នុងសារពត៌មានប្រចាំថ្ងៃវិញ ។

ដូច្នេះ យើងសុំបញ្ឈប់តែត្រឹមនេះ ហើយយើងសូមអភ័យទោសចំពោះសំណាក់អ្នកអាន·

# ឯកសារ សាស្ត្រាស្លឹករឹត និង ក្រាំង

*ដែលមាននៅវិជ្ជាស្ថាននៃពុទ្ធសាសនបណ្ឌិត្យ*

លោក ញ៉ុក-ថែម រៀបរៀង

( គ )

**បំណងជើង:** " សាស្ត្រា ផាវគុន " (១)

**អ្នកនិពន្ធ:** *សែតាន់ នាមខូចហុកគៀន ក្រោយមកគ្រូឲ្យឈ្មោះ អ៊ិន វត់ ( ឬ អ៊ិន-វត ) ។*

**កាលបរិច្ឆេទ:** *ថ្ងៃសៅរ៍ ខែចេត្រ ឆ្នាំគោនព្វស័ក ព.ស. ២៤៤០ ។*

**របៀបនិពន្ធ:** *ពាក្យកាព្យ ៧ និង ពាក្យ ៨ ។*

---

• រឿងនេះ កវីមិនបានចាប់ផ្ដើមអត្ថបទរបស់ខ្លួន ដោយពោលសរសើរ ឬនមស្ការព្រះរតនត្រៃ ដូចកវីដទៃៗទេ តែបែរជាផ្ដើមអត្ថបទដោយថ្លែងសេចក្ដីស្នេហាផ្ទាល់ខ្លួនទៅវិញ ។ តបន្ទាប់មកទើបកវីនេះថ្លែងបទនមស្ការព្រះរតនត្រៃ រំលឹកគុណមាតាបិតាគ្រូអាចារ្យជាដើម បញ្ជាក់កាលបរិច្ឆេទ និងជីវប្រវត្តិខ្លះរបស់ខ្លួន និងបុព្វហេតុខ្លះ ដែលនិពន្ធរឿងចិនមកជាខ្មែរ ។

គួរឲ្យឆ្ងល់ណាស់ចំពោះរឿងរ៉ាវនេះ ដែលជារឿងព្រេងចិនឥតទាក់ទិននឹងស្រុកខ្មែរសោះ ប៉ុន្តែកវីបានភ្ជាប់រឿងស្នេហាមួយ រវាងក្សត្រស្រុកចិនតិងក្សត្រស្រុកខ្មែរ គ្រាតែកើតចម្បាំងរាំងដល់យ៉ាងឃោរឃៅ ដោយចង់បានស្ត្រីមានឆោមធើត ១ ឈ្មោះនាង ផាវ គុន ប៉ុណ្ណោះ ។ ប្រសិនបើគេពិនិត្យមើលឈ្មោះ តួអង្គក្ដី ឈ្មោះស្រុកក្ដី ឈ្មោះភ្នំ ស្ទឹង បឹងបួរក្ដី ឈ្មោះតួអង្គយក្សក្ដី ឥសីក្ដី ទេពតាក្ដី សុទ្ធតែជាឈ្មោះចិនទាំងអស់ ឥតមានឈ្មោះខ្មែរសោះ វៀរលែងតែការរៀបរាប់ពីទេសភាព ធម្មជាតិនានា ដូចព្រៃ បក្សី ម្រឹគ និងមច្ឆាជាដើម ទើបមានបែបជាខ្មែរ ។

ប្រភពរឿង: រឿងព្រេងរបស់ចិន ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ៩ ខ្សែចប់ ។

ខ្សែទី ១ មានសន្លឹក ៦៨, ទី ២ មានសន្លឹក ៥៣,
ទី ៣ មានសន្លឹក ៤០, ទី ៤ មានសន្លឹក ៤៨,
ទី ៥ មានសន្លឹក ៥០, ទី ៦ មានសន្លឹក ៤៤,
ទី ៧ មានសន្លឹក ៤៨, ទី ៨ មានសន្លឹក ៥១,
ទី ៩ មានសន្លឹក ៥៤ បូករួម ៤៥៦ សន្លឹក ។

ឯកសារនេះ គួរចាត់ទុកជាមហាកាព្យមួយ ចំពោះំណាព្យ កាព្យ ៧ ៨ ដែលពុទ្ធសាសនបណ្ឌិត្យបានចារចម្លង កាលពី ព.ស. ២៤៨៦ ចុះលេខសាស្ត្រា ១៣៨១ ។

អត្ថបទផ្ដើម: ។ ៧ ។ តាំងពីរៀមយល់និមិលមាស និលោមនិលាស
ដោយដើតឆាយ រៀមរែងគិតដល់សល់សែនឆ្ងាយ រូបស្ងួន
សែនស្ដាយផ្ទើរលោកអើយ ។ ដូចកាលសេកសោមពជបណ្ឌិត
ឃើញអង្គជួបជិតពជបក្សី សារិកាកែវសត្វបាត់ស្មារតី ចាប់ចិត្ត
បេតីស្និទ្ធស្នេហា ។ . . .

ព្រះបាទសម្ដេចទេពក្ដម គ្រប់គ្រងរៀបចំពជសម្បត្តិ
គ្រងកម្ពុជាប្រសើរក្ដាត់ សម្បូរសម្បត្តិមាសកែវកង ។

ប្រទេសយើពុនចិនតាមផ្លាំ ក្ខ្យាក្មាសៀមលាវហោង
ចាំងម៉ាទិលទិងយួនជន មូលដកអឹងកង់គ្រប់ភាសា ៗ
ផ្សញ្ញៃប្រែលលក់ក្នុងភាព ក្រុងកម្ពុជាពងរដ្ឋា
ប្រាកដប្រកបដោយប្រការ ពឹងបុណ្យក្សត្រាប្រកបសុខ ៗ
ថ្ងៃសៅរ៍ខែចេត្រឆ្នាំរកា ខ្ញុំណែនទុកដូចខែខបុក
ឆើបាយពុំបានដេកពុំលក់ ព្រួយចិត្តគិតស្រុករលឹកស្រី ៗ
រឹងរឹតចំបែងវែងបេក្ខា ពុំបានធ្វើការរកចីអី
នៅផ្ទះហ៊ាគាតថែវរស្តី ឲ្យលើករឿងចិនឈ្មោះដាវគុន ៗ
តាមអ៊ុំប្រាប់ប្រាយស្រាយជាខ្មែរ ឆ្នាំមមែខែផល្គុណមុន
រឿងនេះពិរោះពន់ពេកស៊ុន ជាជាងរឿងមុនឈ្មោះតិកឆេង ៗ

. . . . . ៗលៗ

**អត្ថបទបញ្ចប់:** ពាក្យនេះខ្ញុំលើកតាមរឿងចិន បើមិនសូវប៉ុនរៀន លើកល ជាក់ជាប្រាកដខ្ញុំប៉ុនរក៏ មិនលកមិនលមិនលេងឡើយ ៗ បើអស់អ្នកផងយកទៅមើល កុំថាខ្ញុំព្រើលបងប្អូនអើយ ពាក្យនេះមិនសូវចួនកំពើយ បើបានះហើយជួយតម្រង់ផង ៗ មួយទៀតក្រែងប្រៀតជ្រួសអក្សរ គួមិនសូវល្អរៀនលើកម្តង កុំសើចកុំដៀលខ្ញុំឡើយហោង ថែមពាក្យឲ្យផងកុំមោសា ៗ ដ្បិតរឿង

ជាវគ្គនអម្បូរចិន បើមិនស្រួលប៉ុនថែមពេកហារ មិនផ្អិនកុំឲ្យថែម
ទៀយណា លើសពាក្យកុំថាលេងផ្តេសផ្តាស ៗ ពាក្យណាបើ
មើលមិនស្រួលចំ កុំឲ្យបន្ទុំថាចាក់ប្រាស រឿងចិនមានឈ្មោះគេ
ច្រើនណាស់ ចូរអានឲ្យច្បាស់តាមសេចក្តី ៗ លើកចប់ ១០ កើត
ថ្ងៃចន្ទសុទ្ធ ខែអស្សុជចំហុតពេលម៉ោង ៣ សៀលស៊ុំយោជ្រ
ទុំយ ជួបចប់សេចក្តីបរិបូណ៌ហោង ៗ

×××

បំណងជើង: " សាស្ត្រា លិនថោង(១) "

អ្នកនិពន្ធ: រកពុំទាន់ឃើញ ៗ

កាលបរិច្ឆេទ: គ្មានបញ្ជាក់ក្នុងអត្ថបទ ៗ

របៀបនិពន្ធ: កាព្យ ពាក្យ ៧

ប្រភពរឿង: រឿងព្រេងខ្មែរ

---

១ រឿងនេះ ប្រហែលកើតឡើងដោយឥទ្ធិពលនៃរឿងកាមកេរ្តិ៍ដែរ? ព្រោះវិបត្តិផ្សេងៗ ដែលកើតដល់គ្រួ ឬ សង្គម ច្រើនតែចេញពីប្រភពស្នេហា ៗ នាំឲ្យកើតចម្បាំងយ៉ាងឃោរឃៅ ប៉ុន្តែក៏បានទុកដាក់ជារឿងកតញ្ញូកតវេទីរបស់បុត្រ ចំពោះមាតាបិតា ហើយទុកដាក់ជារឿងជាតក១ ដោយបញ្ជាក់ថា លិនថោង ជាតួអង្គព្រះពោធិសត្វ ។ ការពិតតួអង្គនេះ គ្មានបានកសាងអ្វីទេ ថែមទាំងពោរពេញទៅដោយតណ្ហា ស្នេហ រាគៈ មានគំនុំគុំគួនព្យាបាទ បោកបញ្ឆោត សម្លាប់យក្ខយក់ឥតខ្លាចពៀរវេរ ។

លក្ខណៈឯកសារៈ ច្បាប់សាស្ត្រាស្លឹករឹត ។ ឯកសារនេះមាន ៣ ខ្សែ មិនទាន់ចប់ទេ ។ ខ្សែទី ១ មានសន្លឹក ៣៥, ទី ២ មាន សន្លឹក ៣៥, ទី ៣ មានសន្លឹក ៣៨ ។ លេខសាស្ត្រា.. ។

អត្ថបទផ្ដើមៈ នេះនឹងពណ៌នាពោលថ្លាថ្លែង ជាបទពាក្យល្បែងតែងកាព្យ ច្រាំពីពាក្យពិតគិតឬនឃ្លា តាមអដ្ឋកថាលោកនិពាន ។ ខ្ញុំលុតលើកករអញ្ជលីផ្គង់ បង្គំដល់អង្គព្រះទ្រង់ញាណ ក្រាប ក្រោមកង់ចក្កលាយលក្ខណ៍មានសារពេជ្ឈាញាណព្រះជិនស្រីៗ

. . . . . . . ។ល។

អត្ថបទបញ្ចប់ៈ នាងស្ដាប់ពាក្យយក្ខយង់នោះ បន្ទូលទ្រគោះទៅវិងស្ងួន មិនបាច់អ្នកសួរខ្ញុំច្រើនជង ខ្ញុំគ្មានចំនងអ្វីនឹងប្រាប់ ។ ខ្ញុំនិង នេះឯងខ្ញុំថាជា ផ្លូវនេះណាអ្នកដឹងស្រាប់ បើអ្នកស្គាល់ ហើយចូរអ្នកចាប់ ប្រាប់មកឲ្យដឹងផ្លូវនៃ ។ កាលយក្ខសើច ចំអកទៅថា ហៃនាងធីតាសួនថ្មើមថ្លៃ ផ្លូវនាងឯងទុកក្ដី ស្បៃ តើធ្វើម្ដេចនៃនឹងចាប់បាន ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ង្វ-តា ង

ប្រែ-រៀបរៀង

( ត )

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ   អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន   ទាំងមានសន្តានស្នេហាជាតិ

យូរ—អ៊ុន

ស៊ុនគាំ ថា ខ្ញុំមានឧបាយ ១ មិនឲ្យព្រះចៅឡៅពីធ្វើអន្តរាយដល់លោកបានឡើយ ។ បេង៍តាត់មានអំណរចំណាស់ សួរថា ឧបាយរបស់អ្នកនោះ គិតប្រការម្តេច? ស៊ុនគាំ ថា បងប្អូនខ្ញុំ ២ នាក់នេះ បានគិតគ្នាទុកជាយូរណាស់មកហើយថា នឹងចូលទៅនៅខាងចូកី បើលោកនឹងចង់រួចអំពីសេចក្តីស្លាប់ ត្រូវធ្វើសំបុត្រ ១ ច្បាប់ទៅលាព្រះចៅឡៅពី អធិប្បាយអំពីគុណនិងទោសឲ្យឃើញហើយ សូមលោករត់ចេញទៅនៅនឹងចូកី ។ បានលោកហើយ ក៏គង់នឹងជប់លៀង ឲ្យបានធ្វើជានាម៉ឺនធំ សូមយើង ២ នាក់បងប្អូននឹងរត់ទៅតាមក្រោយ ។ បេង៍តាត់យល់ឃើញត្រូវ ក៏តែងសំបុត្រ ១ ច្បាប់សេចក្តីថា ទូលបង្គំបេង៍តាត់ មានសេចក្តីខុស ពីព្រោះមិនបានលើកទ័ពទៅជួយស្រុកកេងជីវ ។ ក៏ខូច ស្លាប់ទាំងគួនអ៊ូទៅទៀត ។ បើទ្រង់

អស់ទោសទុកអាយុជីវិតទូលបង្គំ នឹងបានទៅធ្វើជាការកែខ្លួនគេទៅ តែឥឡូវទូលបង្គំជាខ្ញុំដឹង ថា ទ្រង់មិនប្រោសប្រណីឲ្យរួចពីសេចក្ដីស្លាប់ ហើយនឹងទ្រាំនៅក៏ពុំបាន ហេតុនេះ ទូលបង្គំសូមក្រាបបង្គំលាទៅនៅខាងព្រះចៅបូកហើយ ដែលទូលបង្គំទៅតាំងនេះ នឹងបានប្រែចិត្តទៅគិតប្រទូសរ៉ាយទ្រង់វិញក៏ទេ ទៅដើម្បីតែប្រាថ្នានឹងឲ្យរួចចាកសេចក្ដីស្លាប់ប៉ុណ្ណោះ លុះធ្វើរួចហើយ ក៏ឲ្យបម្រើនាំ ទៅថ្វាយព្រះចៅឡូពី ឯចំណែកខ្លួនក៏នាំទាហាន ៩០ នាក់រត់ចូលទៅនៅនឹងបូក តាំងពីពេលអធ្រាត្រក្នុងថ្ងៃនោះ ។

ព្រះចៅឡូពី បានទទួលសំបុត្រ ទតឃើញសេចក្ដីសព្វគ្រប់ ក៏ទ្រង់ព្រះក្រោធខ្លាំងណាស់ត្រាស់ថា : អាសត្រូវវាគិតក្បត់នឹងអញហើយ ថែមទាំងឲ្យសំបុត្រមកឲ្យកបញ្ឈឺចិត្តឯងទៀត អញនឹងលើកទ័ពទៅតាមចាប់ខ្លួនវាឲ្យបាន ។ ខុងបេង ទូលទាស់ឃាត់ថា ទ្រង់កុំអាលឲ្យលើកទ័ពទៅ ឲ្យព្រួយលំបាកពលទាហានឡើយ សុំឲ្យមានសំបុត្រទៅដល់ឡៀហង ឲ្យលើកទ័ពតាមទៅចាប់បេងតាត់វិញស្រួលជាង បើឡៀហងចាប់បេងតាត់បាន ក៏នាំខ្លួនមកយើង បើចាប់មិនបានក៏គង់តែឡៀហងនឹងមករកយើង ៗ ក៏នឹងចាប់ខ្លួនសម្លាប់ចេញ បានដោយងាយណាស់ ។ ព្រះចៅឡូពីយល់ឃើញត្រូវ ក៏ចាត់បំរើឲ្យនាំព្រះតម្រាស់ទៅដល់ឡៀហង ក្នុងសេចក្ដីព្រះតម្រាស់នោះថា បេងតាត់ប្រែចិត្តក្បត់រត់ទៅ

ចូលចូភី ឲ្យឡៅហាងលើកកងទ័ពទៅចាប់ខ្លួននាំមកថ្វាយឲ្យខាងតែបាន ។

ខណៈនោះ ព្រះចៅចូភី ចេញនិយាយរាជការផែនដី បណ្ដានាម៉ឺនមុខមន្ត្រីធំរាជការ គឺគង់គាល់ត្រៀបត្រា មានបំរើចូលទៅទូលថា បេងតាត់នាយទាហានឡៅពី ចូលមកសុំធ្វើរាជការថ្វាយ ។ ចូភីក៏ឲ្យហៅខ្លួនចូលទៅ ហើយត្រាស់សួរថា ឯងចូលមកនេះ អញយល់ឃើញថា មិនមែនចូលមកដោយត្រង់សុចរិតទេ គឺមកជាកលឧបាយបញ្ឆោតយើង ។ បេងតាត់ទូលថា ទូលបង្គំជាមនុស្សមានទោស ព្រោះមិនបានលើកទ័ពទៅជួយគួនអ៊ូឯស្រុកកេងជីវ ។ ក៏ខូច គួនអ៊ូក៏ស្លាប់ ព្រះចៅឡៅពីនឹងសម្លាប់ទូលបង្គំចេញ បានជាទូលបង្គំមានសេចក្ដីភ័យខ្លាច ពុំអាចនឹងនៅបានដោះប្រាណរត់ចូលមកជ្រកក្រោមម្លប់ព្រះបរមពោធិសម្ភារជាទីត្រជាក់ដើម្បីនឹងបានផុតផុរៈពីសេចក្ដីស្លាប់ នឹងបានមកប្រែក្រឡាប់ជាឧបាយ ដោយចិត្តទុច្ចរិតដល់ល្អងធូលីក៏ទេ គឺជាសេចក្ដីពិតត្រង់ប្រាកដណាស់ ប៉ុន្តែចូភីក៏មិនអស់មន្ទិលសង្ស័យ មិនមានសេចក្ដីជឿ ។

ឯឡៅហាង បានឃើញព្រះតម្រាប់ព្រះឡៅភី ក៏ស្រូតលើកទ័ពចំនួន ៥ ម៉ឺន ទៅតាមបេងតាត់ ដល់ស្រុកយ៉ាំងយ៉ុង ទើបឲ្យទាហានទៅស្រែកហៅបេងតាត់ឲ្យចេញមកពីក្នុង មកតស៊ូគ្នា ។ ខណៈនោះ មានមនុស្សនាំសេចក្ដីទៅទូលព្រះចៅចូភី នៅចំពោះមុខបេងតាត់ថា ឡៅហាង បានលើកទ័ពជិតតាមបេងតាត់ មកដល់ស្រុកយ៉ាំង

យ៉ុង ៗ ចូភីក៏ត្រាស់ទីងប៉េងតាត់ថា បើអ្នកឯងមកស្វាមីភក្ដិត្រង់ទីងយើងដោយសុចរិតពិតមែន ចូរលើកទាហានចេញទៅតច្បាំងទីងឡៅហាងយកក្បាលឡៅហាងមកឲ្យយើងចុះ យើងទីងបានឃើញសេចក្ដីពិតត្រង់របស់អ្នកឯង ៗ

ប៉េងតាត់ទូលថា : ឡៅហាងនោះក៏មានទោសខុសដូចទូលបង្គំដែរ មិនត្រូវទៅច្បាំងទីងគ្នាទេ បើប្រសិនទូលបង្គំចេញទៅប្រាប់ឲ្យដឹងខ្លួនជាមានទោសហើយ ក៏គង់ទីងសរសើរទ្រង់ថា បេះលើកតម្កើងពួកទាហាន ដែលមានថ្វីដៃ ៗ ឡៅហាងក៏អស់សង្ស័យ គង់ទីងចូលមកនៅជាខ្ញុំទ្រង់ទៀត ៗ

ចូភីឮដូច្នោះ ក៏មានអំណរណាស់ ត្រាស់តាំងប៉េងតាត់ជានាយទាហានធំឲ្យឈរធ្វើទៅហ្វាយស្រុកអ៊ូនសៀផង ៗ គ្រានោះ ហៃហោសៀង និង ស៊ុឡុង នាយទាហានចូភី ដែលចូភីប្រើឲ្យនៅស្រុកយ៉ាំងយ៉ុង ដើម្បីទៅបញ្ចុះបញ្ចូលមនុស្សក្នុងស្រុកសៀងយ៉ុង; លុះឃើញប៉េងតាត់ទៅនៅស្រុកយ៉ាំងយ៉ុង, ហៃហោសៀង និង ស៊ីឡុង ក៏ចេញទៅទទួលគំនាប់ដោយបដិសណ្ឋារៈ ហើយក៏នាំចូលទៅស្រុកនោះ ថ្លែងពណ៌នាប្រាប់ប៉េងតាត់ថា ឡៅហាងលើកទ័ពមកតាំងបន្ទាយនៅជិតស្រុកយ៉ាំងយ៉ុង ចម្ងាយផ្លូវប្រហែល ៥០០ ស៊ិន ( ២០ គ.ម ) ប៉េងតាត់ក៏សរសេរសំបុត្រ ១ ច្បាប់ ឲ្យបម្រើកាន់ទៅបញ្ចុះបញ្ចូលឡៅហាង ៗ

ឃើញសំបុត្រហើយក៏ ខឹងណាស់ថា អាក្បត់ហ៊ានធ្វើឲ្យអញខុសជាមួយផង ក៏ជាមនុស្សមិនត្រង់នឹងម្ចាស់ ស៊ីបាយក្រហម ថែមទាំងឲ្យយើងបានសេចក្ដីខុសទៀត ថាហើយក៏ហែកសំបុត្រនោះចោលទៅ ហើយបង្គាប់ឲ្យចាប់ខ្លួនបំរើដែលកាន់សំបុត្រនោះទៅសម្លាប់បង់ ។

បេងគាត់ បានដឹងដូច្នោះ ខឹងណាស់ ប្រឹក្សានឹងហៃហៅសៀងស៊ីឡុងថា ពេលព្រឹកស្អែក ចូរឲ្យអ្នកទាំង ២ លើកទាហានទៅបង្កប់នៅសងខាងផ្លូវ ឯខ្លួនខ្ញុំនឹងលើកទាហានចេញទៅច្បាំងនឹងឡៅហង់ហើយនឹងធ្វើជាថយមកតាមផ្លូវនោះ បើឡៅហង់ដេញតាមផ្លូវនោះមក អ្នកទាំង ២ ចូរលើកទាហាន ចេញវាយប្រសព្វគ្នាចាប់យកខ្លួនឡៅហង់ឲ្យបាន ហៃហៅសៀង និងស៊ីឡុងយល់ឃើញត្រូវ ក៏លើកទាហានទៅពួនបង្កប់សងខាងផ្លូវដែលគិតទុកនោះ ។

លុះវេលាព្រឹកឡើង ឡៅហង់ លើកទាហានចេញពីបន្ទាយ ឲ្យទាហានចូលទៅស្រែកដេរបេងគាត់ ហៅឲ្យចេញមកតស៊ូគ្នា បេងគាត់ក៏ជិះសេះកាន់លំពែងចេញមុខទាហាន ឡៅហង់ក្រឡេកឃើញ ក៏ចង្អុលមុខហើយស្រែកថា អាចោរចិត្តក្បត់ម្ចាស់ ផ្លាស់ស៊ីបាយក្រហម ហេតុម្ដេចបានជាមកលួងលោមអញឲ្យអាក្រក់តាមឯងទៀត ។ បេងគាត់ស្រែកថា ឯងជាមនុស្សពោស នឹងដល់នូវសេចក្ដីស្លាប់ឆាប់ហើយ ម្ដេចក៏មិនទាន់ដឹងថា សេចក្ដីស្លាប់នោះនឹងមានមកដល់ឡើយដូច្នោះ អាចោរ

ដកទង់ ម្តេចក៏នៅលើកតម្កើងជាខ្ទង់ឯងល្អវិញ ។ ឡៅហ៊ាងខឹង ណាស់ បំរុងលោសេះកាំដាវចូលទៅប្រយុទ្ធគ្នានឹងបេងតាត់បាន ៣ ក្បួន បេងតាត់ក៏ធ្វើជាថយរត់ទៅក្រោយ ឡៅហ៊ាងក៏ដេញបណ្តោយតាមទៅ បានចម្ងាយប្រហែល ២០០ សិន ( ៨.គ.ម ) នោះ ហៃហៅសៀង និងស៊ុឡុង ដែលពួនបង្កប់ ក៏លើកទាហានចេញទៅវាយប្រសព្វទាំង សងខាង បេងតាត់ក៏ស្ទាក់កាត់ពីមុខចូលមកទៀត ឡៅហ៊ាងឃើញ កងទ័ពវាយផ្ទប់ទាំង ៣ ផ្លូវ ទឹងបំពារទៅមិនរួច ក៏នាំទាហានពារ ចំលាយរត់ទៅតាមផ្លូវ ត្រង់លើស្រុកសុងយ៉ុង បេងតាត់និងហៃ-ហៅសៀង, ស៊ុឡុង ក៏លើកទាហានដេញតាមទៅ ។

ស៊ុឡុងនិយាយថា ឥឡូវកងទ័ពឡៅហ៊ាងខូចខ្ចីអស់ហើយ បើ អ្នកទាំង ២ លើកតាមទៅទៀត ក៏គង់នឹងបានជ័យជំនះមិនខាន ឯ ស្រុកសុងយ៉ុង ដែលឡៅហ៊ាងរត់តម្រង់ទៅនោះ ជាទីមាំមួនណាស់ ក្រែងតែស្រុកហាំងឡុង ជាទីកន្លែងមិនសូវមាំមួន ខ្ញុំនឹងសុំលើកទាហាន ទៅចាំរក្សាទីនោះ បេងតាត់និងហៃហៅសៀង ក៏យល់ឃើញត្រូវ ស៊ុឡុង ក៏លើកទាហានតម្រង់ស្ទួតទៅនៅដល់ស្រុកហាំងឡុង ឯឡៅហ៊ាងនោះ លុះរត់ទៅដល់ស្រុកសុងយ៉ុងក្នុងវេលាកណ្តាលយប់ស្ងាត់ ក៏ចូលទៅ គោះទ្វារឲ្យអ្នកយាមបើកទទួល ។

ខណៈនោះ ស៊ុនគាំ ដែលនៅរក្សាស្រុកសុងយ៉ុង ក៏ចូល

ទៅចំណុះខាងចូគីអស់ហើយ លុះដឹងថា ឡៀវហានទៅហៅឲ្យបើក ទ្វារ ក៏ម្នីម្នាដេញទាហានឲ្យឡើងរក្សាស៊ុនចន្ទាយ ហើយឲ្យពួក ទាហានបាញ់ធ្នូចម្រុះទៅត្រូវទាហានឡៀវហានស្លាប់ច្រើនណាស់ ស៊ុនតាំ ក៏ឡើងទៅលើស៊ុន ពីខាងមុខហើយស្រែកថា យើងស្ម័គ្រទៅចំណុះ ជាខ្ញុំព្រះចៅចូគីហើយ ឡៀវហានឮដូច្នោះ ក៏រឹតតែខឹងណាស់គិតនឹង ឲ្យទាហានទម្លាយយកស្រុកសុងយ៉ុងឲ្យបានវិញនោះស្រាប់តែកងទ័ពហៃ-ហៅសៀន លើកទៅដល់វាយខ្នប់ពីក្រោយ ឡៀវហានក៏នាំទាហាន រត់បណ្តាយតម្រង់ទៅស្រុកហាន់ឡេង ក្រឡេកទៅឃើញទង់ដោតនៅ លើស៊ុន មានអក្សរក្នុងទង់នោះថា ស្រុកនេះ ជាចំណុះព្រះចៅចូគី ។

ស៊ុនធី ដែលនៅរក្សាស្រុកនោះ ឡើងឈរពីលើស៊ុនគ្រវីទង់ ជ័យ សញ្ញាហៅទាហានឲ្យទៅជម្រាបស៊ុឡុង ។ ក៏លើកកងទ័ពចេញ ទៅតាមវាយកងទ័ពឡៀវហាន ។ តទល់ពុំបាន ក៏នាំទាហានរត់ទៅ ស៊ុឡុង ក៏បរពលដេញសំដៅពីក្រោយកាប់សម្លាប់ទាហានឡៀវហានស្លាប់ ច្រើនណាស់ ឡៀវហានក៏នាំទាហាន ដែលសល់ខ្លះ រត់ទៅដល់ស្រុក សែឈួន ហើយចូលទៅគាល់ព្រះចៅឡៀវពី ក្រាបទូលហើយក៏យំទូល រាប់រៀប តាមដំណើរការណ៍ ដែលបានលើកទ័ពទៅតាមចាប់បេងតាត់ តាំងពីដើមដល់ចុងអស់សេចក្តី ។

ព្រះចៅឡៀវពីទ្រង់ខ្ញាល់ខ្លាំងណាស់ ស្រែកដេរថា អាកូនចោល

ម្សៀត កើតមកឲ្យបង់ជាតិ នៅផ្ទុំមុខផ្តែបែរមកកេអញធ្វើអ្វី ខ្យ៉ាហាង ទូលថា កាលពីគ្រាគួនអុី ទូលព្រះបង្គំឲ្យមានសំបុត្រមកសុំកងទ័ព ទៅជួយស្រុកកេងដីរនោះ ទូលព្រះបង្គំបានឲ្យបម្រុងពលទាហានត្រៀម ទុកជាស្រេចហើយ ប្រុងនឹងលើកទៅជួយជាប្រាកដ តែបេងតាត់ ឃាត់ហាម មិនព្រមឲ្យលើកទៅ បានជាផុសផ្លាយដោយហេតុនោះ ។

ព្រះចៅខ្សុំពីត្រាស់ថា អញខាតកម្លាំងបង់ចិត្ត ដែលអាណិត ស្រឡាញ់ឯង ប្រឹ ស្នែងចិញ្ចឹមឯងមក ហាក់ដូចគេយកដុំឈើឬដុំដីមក រក្សា វាគ្មានដឹងការខុសត្រូវបន្តិចសោះ គួរអ៊ុកវាទៅផ្ញើស្តាប់ពាក្យសំដីអា បេងតាត់នោះ វាជាសត្រូវក្បត់ បានជាវាមិនព្រមឲ្យលើកកងទ័ពទៅជួយ គួនអុីជាប្អូនអញ ឲ្យតាញស្លាប់អសារ ត្រាស់ហើយក៏បង្គាប់ឲ្យយកខ្ទួន ខ្យ៉ាហាងទៅប្រហារជីវិត កាលព្រះចៅខ្សុំពីឲ្យសម្លាប់ខ្យ៉ាហាងនោះ លុះ ក្រោយក៏ទ្រង់នឹករព្ទកឃើញសំដីដែលខ្យ៉ាហាងទូលរាប់រៀបថា បេងតាត់ មានសំបុត្រមកបញ្ចុះបញ្ចូលខ្យ៉ាហាងៗ ហែកសំបុត្រចោល ហើយសម្លាប់ អ្នកកាន់សំបុត្រនោះចេញ ក៏ឃើញថាចិត្តខ្យ៉ាហាងនោះមិញ ជាមនុស្ស ត្រង់សុចរិត នឹងព្រះអង្គប្រាកដណាស់ ទ្រង់នឹកឃើញច្បាស់ ក៏គិត អាណិតស្តាយពន់ប្រមាណមានព្រះទ័យអាល័យស្តាយទៅដល់គួនអុីទៀត ក៏រឹតតែបង្អៀតព្រះទ័យសព្វគ្រប់ ព្រះរោគកបណ្តាលឈឺខ្លាំងខ្ទប់សព្វំសា ការដែលគិតនឹងលើកពលយោធាទៅច្បាំង ក៏បង្អង់ខានវិញ ។

ចប់ខ្សែ ៦៣ សូមរង់ចាំអានខ្សែទី ៦៤ ទៀត

# ជីវប្រវត្តិរបស់ខ្ញុំ

## ឈ្មោះ អៀង-សាយ

(គ)

មានរឿងបែបនេះ ១ ទៀត ខ្ញុំមានប្រកាសតែងតាំងតែត្រឹម ត្រូវបង្ហាត់ការតិចនិក ( ម៉ូនីទ័រ ទេ ឡង់សែញេម៉ង់ តិចនិច ) តែដោយបង្រៀននៅវិទ្យាល័យ គេសំគាល់ថាជាសាស្ត្រាចារ្យ ( ប្រូហ្វេស័រ ) ដោយខ្ញុំជាគ្រូថ្នាក់ផុតលេខ ចូលទៅថ្នាក់ពិសេសទៀត គេសំគាល់ថាខ្ញុំ មានឋានន្តរសក្តិខ្ពស់ជាងគេនៅសាលានេះ រៀងកាលពិធីបុណ្យទានសមាសដែលគេប្រារព្ធធ្វើក្នុងវាំង, នៅកំពង់ផែឬកាលមេរុ គ្រប់ក្រសួងទាំងអស់ ត្រូវចាត់ម្នាក់ ឬពីរ បីនាក់ឲ្យទៅរួមក្នុងពិធីនោះ ដោយដាក់ឈ្មោះក្នុងបញ្ជីបញ្ជូនទៅឲ្យគេមុន គេតែងតែតម្រូវមកឈ្មោះខ្ញុំឲ្យទៅរួមក្នុងពិធីនោះ ចំពោះព្រះករុណាជាអម្ចាស់ ចំពោះព្រះកត្រ្តសម្តេចព្រះមហាក្សត្រិយានី ឬចំពោះព្រះកត្រ្តសម្តេចព្រះប្រមុខរដ្ឋ ។

កាលនោះឋានន្តរសក្តិខ្ញុំ គេដាក់ថា សក្តិ៧ហូពាន់ ខ្ញុំត្រូវមានសំពត់ផាមួង ៧ ពណ៌ខុសគ្នា ស្លៀកចង្កេះរើសយកពណ៌តាមថ្ងៃ ពាក់អាវកុតសកត្រង់ មានសក្តិនៅលើស្មា និង នៅចុងដៃអាវ ហើយត្រូវមានខ្សែក្រវាត់រុំពីលើអាវត្រង់ចង្កេះទៀត ដោយខ្ញុំមានមេដាយប្រាំ-ប្រាំមួយពាក់ព្យួរពេញ ១ ចំហៀងទ្រូងខាងឆ្វេង ។ មានពេល ១ ខ្ញុំ

ចូលទៅក្នុងទេកវិទិច្ច័យមុនពេលម៉ោងបន្តិច មានលោកម្នាក់ងាកមក ឃើញខ្ញុំខំសម្លឹងបែបពិនិត្យ ហើយខ្សិបសួរលោកម្នាក់ដែលឈរនៅ ជិតនោះ ខ្ញុំមិនឮទេ តែខ្ញុំដឹងមកពេលក្រោយ ដោយលោកដែល ឈរជិតនោះប្រាប់ខ្ញុំថា គេសួរថា ខ្ញុំនេះធ្វើជាស្អីគឹកសម្បើមម្ល៉េះ គេប្រាប់ ថា ខ្ញុំធ្វើជា ប្រូហ្វេស័រ ។ លោកដែលសម្លឹងមើលខ្ញុំនោះងាកទៅខាង ណេះ ងាកទៅខាងណោះ សសៀរមកដល់ជិតខ្ញុំ សួរខ្ញុំដោយញញឹម ថា លោកជាន់ណាឯបេះ? មុនខ្ញុំឬក្រោយខ្ញុំ? ។ ខ្ញុំឮពាក្យនេះ ខ្ញុំយល់ថា លោកដែលសួរខ្ញុំនេះ លោកនឹកថា ខ្ញុំមានមេដាយសក្តិ យសយ៉ាងនេះ ហើយធ្វើជាប្រូហ្វេស័រ ច្បាស់ជាមានឌិប្លូម ឬ បាស្ស៊ូ បេតិតដូចនេះ ម្ដេចក៏មិនប្រហាក់ប្រហែលមុខសោះ ពីព្រោះកាលនោះ គ្មានលិសេ្យ គ្មានកូឡែ្យសឯណា ក្រៅពីកូឡែ្យសស៊ីសុវត្ថិទេ មុននឹង បានឌិប្លូម បាស្ស៊ូត្រូវរៀនតាំងពីថ្នាក់ទី ៦ ឡើងមកដល់ថ្នាក់ទី ៣ ទី ២ ទី ១ ដែលក្នុងរវាងប្រាំឆ្នាំ ទោះបីរៀននៅថ្នាក់ណា ក៏គង់ តែស្គាល់មុខគ្នាដែរ ដោយគ្មានប្រហាក់ប្រហែលខ្ញុំសោះ ទើបបានជា គេសួរថា ខ្ញុំរៀនជាន់ណាពីឆ្នាំណា មុនគេឬក្រោយគេ បានសេចក្ដី ថា ត្រែងខ្ញុំរៀនមុនប្រឡងជាប់ចេញមុនមក គេចូលមករៀនក្រោយ ឬថា គេរៀនមុនខ្ញុំ គេចេញមុនបាត់មក ទើបបានខ្ញុំចូលទៅរៀន ក្រោយ ។ គេឆ្ងល់ទើបគេសួរថា “ លោកមុនខ្ញុំ ឬក្រោយខ្ញុំ ”

ខ្ញុំតបយ៉ាងខ្លីថា រឿងវែងណាស់ លោកសួរខ្ញុំពេកឆ្លើយមិនបានទេ ចាំមានពេលវែង សឹមខ្ញុំជំរាបពីរឿងនៅឯណាពីឆ្នាំណា ។

ខ្ញុំជាសមាជិកចាស់ម្នាក់នៃសមាគមអ្នកនិពន្ធខ្មែរ បានជាប់ឈ្មោះជាសមាជិកក្រុមអភិបាលប៉ុន្មានឆ្នាំដែរ ហើយមានបានជាប់ឈ្មោះជាប្រធាននៃគណៈកម្មការសិល្បៈផង ដែលទាំងបានធ្វើជាមេប្រយោគក្នុងការប្រឡងអក្សរសាស្ត្រឥន្ទ្រទេវីលើកទី ១ ទៀត ។

កាលខ្ញុំនៅក្នុងឋានៈ ជាប្រធាននៃគណៈកម្មការសិល្បៈ ខ្ញុំបានគូរប្រចំណោទ ដាក់ចំណងជើងជាពាក្យកាព្យ និងបានសរសេរអត្ថបទ ដែលពន្យល់អំពីការសរសេរ ការតែងសំបុត្រតាមបុរស ព្រមទាំងបរិហារការស្មាត់កំបាំងល្បែងលេងកល់ថ្មីនៃក្នុងខ្លះ និងសរសេរអត្ថបទរៀបរាប់ពីល្បែង ដែលគេលេងក្នុងឱកាសចូលឆ្នាំថ្មីពីដើម ដាក់ក្នុងទស្សនាវដ្តីអក្សរសាស្ត្រ គ្រាន់តែឈ្មោះទស្សនាវដ្តីនេះ ក៏ខ្ញុំដាក់ស្នើសូមឲ្យយកឈ្មោះនេះដែរ ។

នៅភាគខាងដើមខ្ញុំមាននិយាយអំពីគំនិត ដែលខ្ញុំគិតអប់រំកូនយ៉ាងនោះ ខ្ញុំយល់ថា ត្រូវបញ្ជាក់អំពីលទ្ធផលឲ្យឃើញថា បំណាច់នឹងអួតថាខ្លួនចេះអប់រំកូន តើកូនទាំងអស់នោះបានទៅជាស្អីទៅ?

១- ឈ្មោះ អៀង-សាគុប៊ុន មានប្តីហើយខ្ញុំមិនឲ្យធ្វើការទេ ឲ្យរៀនខាងពេទ្យទៀត បានសញ្ញាបត្រខាងមន្ត្រីសុខាភិបាល

ហើយបានបន្តវិជ្ជា  យកប៉ាទន្តជាវេជ្ជបណ្ឌិតទៀត  គ្រូពេទ្យនេះ ខ្ញុំ ឲ្យមានប្រពន្ធ  តាំងពីកាលប្រឡងបានឌីប្លូម  មានប្រពន្ធកូនហើយក៏នៅតែរៀន ។

២– អៀង គុនសាគី រៀនបានឌីប្លូម-ព្រឺវេនៅស្រុកខ្មែរ ទៅរៀនយកបាស្ស៊ូ និង លិស្សង់ឯស្រុកបារាំង  បានបាស្ស៊ូហើយជិតនឹងដល់បានប្រឡងយកលិស្សង់ មានរឿងពីធ្វើនយោបាយគេបញ្ឈប់លែងឲ្យរៀន មកធ្វើជាសាស្ត្រាចារ្យ មានប្រពន្ធកូនហើយ ឥឡូវនៅធ្វើការឯប្រទេសបារាំងជាអ្នកទាក់ទងអគ្គការយូណេស្កូ  ហើយនឹងក្រសួងអប់រំជាតិ នៃព្រះរាជ-រដ្ឋាភិបាលយើង ។

៣– អៀង-ស៊ីសាគឹម កូនស្រី រៀនបានវិញ្ញាបនប័ត្របឋមសិក្សា ប្រឡងជាប់ចូលរៀននៅអនុវិទ្យាល័យនារី ( អនុវិទ្យាល័យព្រះនរោត្តម ) តែមិនទាន់បានប្រឡងឌីប្លូម ដោយមិនចង់ឲ្យរៀនយូរ ចង់ឲ្យបានធ្វើការឆាប់ ដ្បិតរកជាស្រីចេះប៉ុណ្ណឹងបានហើយ  ឲ្យមករៀនធ្វើគ្រូបង្រៀនវិញ ឥឡូវធ្វើការនៅមណ្ឌលអប់រំគរុវិជ្ជា ឯកំពង់កន្ទួត មានប្ដីធ្វើគ្រូ ធ្វើការនៅជាមួយគ្នា ។

៤– អៀង-ស៊ឹមសាគូ ប្រឡងបានព្រឺវេ ហើយទៅរៀនខាងវិជ្ជាបសុពេទ្យ ជាប់បានឌីប្លូមខាងវិជ្ជានេះ  សព្វថ្ងៃធ្វើការជាអភិបាលការពារជម្ងឺនិងចិញ្ចឹមសត្វ នៅមណ្ឌលស៊ឹងមានជ័យ មានប្រពន្ធធ្វើគ្រូបង្រៀន ។

ប្រវត្តិរបស់ខ្ញុំ មិនមែនសុទ្ធតែមានរឿងល្អទេ រឿងអាក្រក់ក៏មានច្រើនណាស់ដែរ តែគ្មានប្រយោជន៍ទាំងអស់ទេ មានតែពីរ ដែលខ្ញុំយល់ថា មានប្រយោជន៍ ដោយចង់ឲ្យគេជឿហើយជៀសវាងកុំធ្វើតាមខ្ញុំ សូមសុំគ្រឡប់ទៅមើលសេចក្តីខាងដើមមួយភាគ ដែលខ្ញុំនិយាយអំពីអុចធូប ៣ សរសៃថ្វាយព្រះពុទ្ធរូប ហើយនិយាយប្រកាសចំពោះព្រះពុទ្ធរូបយ៉ាងណានោះ ខ្ញុំនិយាយយ៉ាងនេះ ដូចជាខ្ញុំស្បថចំពោះព្រះភក្ត្រព្រះហើយ ខ្ញុំក្បួចពាក្យដែលខ្ញុំប្រកាស ដូចជាខ្ញុំក្បួចពាក្យសំបថរបស់ខ្ញុំ ។ យល់ហើយជឿជាក់ថា ពាក្យសំបថដែលយើងស្បថយ៉ាងណា ហើយយើងមិនបានកាន់ខ្ជាប់ មិនបានប្រតិបត្តិតាមពាក្យយើងនោះ គឺទៀងតែពីមានហេតុ មានផលមិនបាត់សាបសូន្យទេ ( សូមគ្រឡប់ទៅបើកមើលត្រង់ទំព័រដែលនិយាយរឿងនេះមួយទំព័រ រួចវិលមកអានបន្តទៅទៀត ) ។

ដោយខ្ញុំប្រហែសមិនបានយកប្រាក់ ២ រៀល ទៅប្រគេនលោកគ្រូខ្ញុំ ដោយអៀនខ្មាសលោក មួយទៀតលោកមិនជ្រាបពីរឿងលួចលាក់ប្រាក់លោកទុកនោះផង ម៉្លោះហើយក៏បំភ្លេចចោលតែម្តងទៅ ។

លុះដល់មកធ្វើការរកប្រាក់បានដល់ហ្នឹង ហើយគ្មានប្រាក់ទុក នៅតែក្រ នៅតែមានការខ្វះខាត ទើបនឹកឃើញដល់ពាក្យ ដែលប្រកាសដូចជាបានស្បថចំពោះព្រះពុទ្ធរូប ខ្ញុំយល់ហើយជឿជាក់ថា ប្រាកដជាបាបកម្ម ដែលខ្ញុំមិនបានសងប្រាក់ ២ រៀលនោះហើយ ទើបនាំឲ្យខ្ញុំនៅ

តែក្រ នៅតែមានការខ្វះខាតដូច្នេះ ខ្ញុំបង់យកប្រាក់ពីរពាន់ ជំនួសប្រាក់ពីររៀលទៅសងលោកគ្រូខ្ញុំ ដើម្បីឱ្យរួចកម្មពៀរ ឱ្យអស់បាបកម្ម ដោយបង់មានបង់បានដូចគេ កុំឱ្យនៅតក្រលំបាកនិងការខ្វះមុខខ្វះក្រោយដូច្នេះ តែលោកគ្រូខ្ញុំ លោកផ្លាស់ភេទទៅជាយក្ស មានប្រពន្ធកូននៅឯស្រុកបាកាន ខេត្តពោធិសាត់ លោកអនិច្ចកម្មបាត់ទៅហើយ ព្រមទាំងប្រពន្ធកូនលោក ក៏មិនដឹងជានៅឯណា ។

ជំនឿរបស់ខ្ញុំត្រង់នេះ បើមានលោកអ្នកណាមិនជឿដូចខ្ញុំ ដោយយល់ហេតុផលផ្សេងទៅវិញ ប្រហែលជាលោកអ្នកនោះ មិនជឿពាក្យចាស់ៗ ឃ្លា ដែលថា : រីបុណ្យនិងបាប អំពើជាកទាប នោះវាតែងតាម បីដូចស្រមោល អន្ទោលតាមប្រាណ ពុំដែលជៀសបាន ត្រង់ក្តីវិលវល់ ។

សូមបញ្ជាក់បញ្ចប់ ១ ភាគនេះថា ខ្ញុំមិនសំគាល់ថា ការស្បថចំពោះព្រះពុទ្ធរូប ហើយព្រះពុទ្ធរូបទៅធ្វើគេឱ្យទៅជាយ៉ាងនេះយ៉ាងនោះ ។ ទេ ដ្បិតព្រះពុទ្ធរូបគ្មានវិញ្ញាណ គ្មានទៅធ្វើអ្វីកើតទេ គ្រាន់តែស្តាប់ពាក្យយើងស្បថ ក៏គ្មានប្រដាប់និងឱ្យពុថាដូចម្តេចដែរ បើមិនពុក៏មិនដឹង បើមិនដឹងហើយ ទៅបណ្តាលឱ្យគេទៅជាមាន ជាក្រម្តេចនឹងបាន ។

បើគេបង់ដឹងអំពីគំនិតដែលខ្ញុំគិតយល់ឃើញថា អ្វីដែលនាំឱ្យមានបាបកម្ម ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់នោះ? បើនិយាយដោយ

ចំពោះ ថាយើងស្បថចំពោះព្រះភក្ត្រព្រះ ដល់យើងបំពានសំបថ តើអ្វី ដែលទៅធ្វើទោសយើង? តាមខ្ញុំយល់ ខ្ញុំឆ្លើយថា គឺ "ធម្មជាតិ" វាមិនតែបណ្ដាលឲ្យមានហេតុ មានផលជាធម្មតាយ៉ាងនេះ គ្មានតួអង្គ ណាទៅធ្វើឲ្យទឹកសមុទ្រប្រៃ ទឹកភ្លៀងសាប ឬក៏ថា គ្មានតួអង្គណា ធ្វើឲ្យទឹកក្រូចឆ្មាជូរ ធ្វើទឹកអំពៅផ្អែមនោះទេ គឺធម្មជាតិបណ្ដាលឲ្យទៅ ជាយ៉ាងនោះ ចាំងពាក្យសំបថដែលស្បថហើយ មិនប្រតិបត្តិតាម ធម្ម-ជាតិទីងនាំបណ្ដាលឲ្យទៅជាយ៉ាងនេះយ៉ាងនោះ តាមតែពាក្យដែលយើង ស្បថ បើយើងមិនស្បថ ក៏គ្មានហេតុផលអ្វីដែរ ដូចជាថាតែពន្លឺមកប៉ះ ទីងយើង ៗ តែងតែមានស្រមោល បើគ្មានពន្លឺមកប៉ះទីងយើង ៗ ក៏គ្មាន ស្រមោលដែរ ។

មានរឿងមិនល្អរបស់ខ្ញុំមួយទៀត ដែលខ្ញុំមិនចង់លាក់ ដោយមាន ពន្លឺទុកគ្រាន់បំភ្លឺកូលបុត្រខ្មែរនៅខាងក្រោយ ឲ្យដើរចៀសវាងផ្លូវដែលមាន សត្វពស់មានពិសជាច្រើននៅព្រៃសងខាងផ្លូវ ដែលខ្ញុំបានដើរម្ដងរួចមក ហើយ ហើយបានជួបប្រទះនឹងគ្រោះថ្នាក់យ៉ាងធំ ទើបខ្ញុំលើកយករឿង នេះមកធ្វើបន្លាស្រោសផ្លូវនោះ កុំឲ្យក្មេងជាន់ក្រោយដើរទៅទៀត ។

ខ្ញុំជាមនុស្សត្រេកត្រអាល ស្រើបស្រាលនិងស្រីញញួលហួសពេក តាំងពីក្មេងមកមានរឿងកប់មិនអស់ ។ កាលនាំនាងម្នាក់ទៅនៅខេត្ត កំពង់ឆ្នាំង ដែលទៅធ្វើគ្រូបង្រៀនគំនូរនោះ នាងនេះមានផ្ទៃពោះគ្រប់ខែ

ត្រឡប់មកជួនទន្ទេងក្នុងពេញ ដោយមានម្តាយជាចាស់ទុំជួយមើលនៅឯណោះ ៗ

ចំណែកខ្ញុំជាប្រុសរិលខូច គឺពេលដែលគ្មានស្រីនៅផ្ទះ ពេលយប់ទៅលេងផ្សារក្រោម ដោយរដូវទឹកទន្លេឡើងទីដីផ្សារក្រោមទឹកលិចតាំងអស់ ផ្ទះផ្សារតាំងប៉ុន្មាន នៅជាអណ្តែតលើទឹកដោយមានក្បូនឬស្សីក្រ តាំងពេងល្ខោនក៏នៅលើទឹកដែរ សប្បាយប្លែកពីទីក្រុងឯទៀត ទៅមកតាមប្រកល្ហកផ្ទះផ្សារអណ្តែតទឹក មានទូកតូច ៗ ជាច្រើន គេស៊ីឈ្នួលអុំឲ្យយើងជិះចង់ឈប់ត្រង់ណា ចង់ទៅណាស្រួលណាស់ ៗ ពេលយប់មួយនោះ ខ្ញុំអង្គុយមើលល្ខោនឃើញស្រីយួនម្នាក់ រូបល្អស្អាតអង្គុយជិតខ្ញុំ ដោយខ្ញុំចេះភាសាយួន ខ្ញុំនិយាយលេងនឹងវា ១ ក៏និយាយឆ្លងឆ្លើយមកកេខ្ញុំ លុះល្ខោនឈប់លេង ខ្ញុំឃើញវាគ្មានគូគា ខ្ញុំសូមជូនវាទៅផ្ទះ ហើយនាំគ្នាជិះទូក ១ ពីនាក់មកដល់ផ្លូវដីគោក នាំគ្នាជិះរទេះសេះមកផ្សារលើ ខ្ញុំតាមតែវា ដោយចង់ដឹងផ្ទះវានៅឯណា លុះមកដល់ផ្ទះថ្មមួយធំ វាបញ្ឈប់រទេះ ខ្ញុំដឹងថាផ្ទះនេះជាផ្ទះលោកមេក្រួយលោករ៉េស៊ីដង់ត៍ វានាំខ្ញុំចូលទៅខាងក្រោយ ដល់បន្ទប់ដំណេកវា ខ្ញុំនៅមួយយប់ជាមួយវា ដល់ម៉ោង ៤ ជិតភ្លឺ ទើបបានខ្ញុំទៅផ្ទះខ្ញុំ ។ ទៅមករកវា ជួនកាលខ្ញុំនាំវាទៅលេងនៅផ្ទះខ្ញុំ លុះតែប្រពន្ធដែលមកជូនទន្ទេងបានកូនប្រុស ១ ត្រឡប់ទៅវិញ ទើបកំបុតការទាក់ទងនឹង

មីយួនស្រីបំរើប្រពន្ធបារាំងនោះ ហើយខ្ញុំក៏មានផ្ទៃគភ៌ពេលនោះ ដោយ តាមរោគ ដោយមានការរៀនភាសាលោកវេជ្ជបណ្ឌិត ខ្ញុំមិនបានព្យាបាល រោគតាមពេទ្យបារាំងទេ ខ្ញុំឲ្យគ្រូខ្មែរមើលវិញជាហេតុឲ្យរោគនោះកាន់តែ ដុនដាបទៅ ដោយមានហើមច្រើនអន្លើ នាំឲ្យក្តៅខ្លួនរហូតដល់បាត់ ស្មារតី លុះបានដឹងខ្លួនបន្តិច ដឹងថាមានឈឺនៅក្រលៀន មានឈឺ ត្រង់សៀតផ្កា ឈឺក្នុងក្បាលមុំត្រចៀក ពេលនោះភ្នែកប្រាំង ត្រចៀក ហឹង មើលមិនច្បាស់ ស្តាប់មិនឮ ។ តែសូរសព្ទក្នុងក្បាល លុះបាន ងើបពីឈឺមក ខ្ញុំជាមនុស្សចួនចន់ទៅជាមនុស្សខ្វាក់ផង តែដោយគ្រូឡប់ មកកែគ្រូពេទ្យបារាំងវិញ ភ្នែកខ្ញុំគ្រាន់តែស្រវាំង មើលឃើញតែមិនសូវ ច្បាស់ ឯត្រចៀកខ្វះរហូតកែមិនបាន គ្រាន់តែឮ តែមិនឮដូចពីដើមទេ ខ្ញុំទៅជាមនុស្សធ្ងន់ត្រចៀកតាំងពីអាយុបាន ២០ ឆ្នាំមកដល់ឥឡូវនេះ ។

មានរឿងមានរោគតែហូរហែមក រកលះបង់ល្បែងស្រីញីនេះមិន បានសោះ អស់ពីក្រមុំព្រហ្មចារី ស្រីប្រពន្ធគេ ស្រីខិលខូច ស្រីពេស្យា ។

បើមានៈហាគអ្នកណាបន្ទោសខ្ញុំថា ខ្ញុំជាមនុស្សចេះដឹងគ្រាន់បើ ដែរ ម្តេចក៏ទៅខិលខូចដូចជាមនុស្សពាលទៅវិញ ។ ខ្ញុំនឹងឆ្លើយថា គឺក្រឡាក្រយៅ ដែលព្រហ្មលិខិតរបស់ខ្ញុំពីនាយមក ។

ខ្ញុំសូមផ្តាំផ្ញើថា ល្បែងស្រីជាល្បែងហិនហោច ខ្ញុំមានការ ពិសោធន៍ផ្ទាល់ខ្លួនច្រើន មានរឿងទាស់ទែងកាប់ចាក់គ្នា, មានរឿង

ជាប់ចោទតាមផ្លូវច្បាប់, មានរឿងឱនអាប់កិត្តិយស, មានរឿងបាបគ្រោះដោយកាមរោគ និងមានរឿងទុក្ខសោកក្នុងគ្រួសារ ។

ប្រវត្តិខ្ញុំពីរឿងក្លាយទៅជារឿងរំឭកដាស់ស្មារតី ទៅជាអ្វីទៅហើយ តាមតែលោកកាត់ចោលត្រង់ណាដែលឥតប្រយោជន៍នោះទៅផងចុះ ។

ខ្ញុំបញ្ចប់ប្រវត្តិខ្ញុំ ដោយមានបញ្ជីឈ្មោះមេដាយ ដែលខ្ញុំបានទទួល នៅខាងខ្នងទំព័រនេះ ។

សរសេរដោយឥតព្រាងពីថ្ងៃ១៩ មិថុនា ដល់ ២៦ កក្កដា ១៩៦៦ ចប់

## ជឿ ក្បួន ហោរ ឬ ទេ ?

តាមពាក្យហោរថា ខ្ញុំនេះ លេខ ថ្ងៃ – ខែ – ឆ្នាំ ល្អណាស់ ថ្នាក់ទៅហ្វាយស្រុក ទៅហ្វាយខេត្ត ។

ឥឡូវនេះខ្ញុំបានធ្វើជាគ្រូបង្ហាត់ការតិចនិកថ្នាក់ផុតលេខ តាមឋានន្តរសក្តិមន្ត្រីអប់រំជាតិ គឺថ្នាក់ទី១កញ្ញា សក្តិ ៧ ហូពាន់ ខ្ញុំមានគ្រឿងឥស្សរិយយសប្រចាំមួយគឺ ៖

១– មេដាយប្រាក់វឌ្ឍកាល

២– មេដាយប្រាក់អនុស្សរ

៣– មេដាយប្រាក់វឌ្ឍនាការណ៍

៤– មេដាយអស្សឫទ្ធិមុនីសារាភណ៍

៥– មេដាយអស្សឫទ្ធិសុវត្ថារា

៦– មេដាយអស្សឫទ្ធិព្រះរាជាណាចក្រកម្ពុជា ។

# ឯកសារ កម្ពុជសុរិយា

( ត )

លោក ឌឹក-គាម ប្រមូលរៀបរៀង

សុតនុជាតក : ព្រះញាណវិរយៈ ឡុង ទ.ក. ១២, ទំព័រ ២៨២, ឆ្នាំ ១៩៣១, (ម.៥២/៤) ។

សុមនមាណការ : ឧកញ៉ាកក្ដីសាទេព កែ-នេត ទ.ក. ៩, ទំព័រ ៤៥១, ឆ្នាំ ១៩៤៥, (ម.៥២/១៧) ។

សុវណ្ណសាមជាតក (កាព្យ) : ព្រះសមុហ៍ឃោសាចារ្យ យូរ-ប៉ុណ ទ.ក ៤, ទំព័រ ១៧០, ឆ្នាំ ១៩៤៤, (ម.៥២/១៦) ។

សុរិដ្ឋា : ជី ធ.គិមហាក់ ទ.ក. ៨, ទំព័រ ២៧, ឆ្នាំ ១៩២៧, (ម.៥២/២) ។

សួរឆ្លើយក្នុងរឿងបតាសតាកជ : លោក ប៊ូ-ប៉ូ ទ.ក. ១២, ទំព័រ ៩០១, ឆ្នាំ ១៩៥២, (ម.៥២/២៤) ។

សួរឆ្លើយអំពីជម្ងឺដើមឈើប្រភេទខ្លះ : ទ.ក. ១៩, ទំព័រ ១៥, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

សួស្ដី និង អពមង្គល : ព្រះអគ្គលេខា ណុប ទ.ក. ១-២-៣, ទំព័រ ១៧៤, ឆ្នាំ ១៩៣៣, (ម.៥២/៦) ។

សេចក្តីកត់សំគាល់របស់អ្នកប្រែ : លោក ហ៊ុយ-ប៊ុក ទ.ក. ៥, ទំព័រ ៣២៦, ឆ្នាំ ១៩៤៨, (ម.៥២/៤០) ។

សេចក្តីកត់ហេតុប្លែកៗ : ទ.ក. ២៤, ទំព័រ ៤៣, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។ ខេមរវង្ស ទ.ក. ១៦, ទំព័រ ៥៤, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។ ទ.ក. ២១-២២, ទំព័រ ៣២, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

សេចក្តីកត់ហេតុព្រះអង្គម្ចាស់សាវ៉ង់ទតមើលពុទ្ធសាសនបណ្ឌិត្យ : ទ.ក. ១០-១១-១២, ទំព័រ ១៩, ឆ្នាំ ១៩៣៥, (ម.៥២/៧) ។

សេចក្តីកត់ហេតុ អំពីគ្រោងការណ៍ បុណ្យពាក់កណ្តាលព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា : ទ.ក ៤, ទំព័រ ៣៧០, ឆ្នាំ ១.៥៦, (ម.៥២/២៨) ។

សេចក្តីក្រាបបង្គំទូលព្រះករុណាសូមសាងវត្តកំពង់ នៅខេត្តពោធិ៍សាត់ជាថ្មីឡើងវិញ : ទ.ក. ១០ ១១-១២, ទំព័រ ៨៧, ឆ្នាំ ១៩៣៥, (ម.៥២/៧) ។

សេចក្តីខ្លះនិយាយអំពីអក្សរសាស្ត្រព្រះពុទ្ធសាសនា : ទ.ក. ១៣, ទំព័រ ៣, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

(នៅមានត)

# ផ្នែកកំណត់ និង ប្រវត្តិការណ៍

## ពុទ្ធសាសនបណ្ឌិត្យ បានទទួលព្រះរាជបុតហ្វាយ

ក្រោយអំពីការរៀបចំពិធីបុណ្យរំឭកថ្ងៃកំណើតនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ហើយនិងពិធីថ្វាយកុសល ចំពោះព្រះមហាក្សត្រិយានី និង សម្ដេចសហជីវិនជាអម្ចាស់ រួចមក សហជីវិននាយកនៃវិទ្យាស្ថាន បានថ្វាយព្រះបុតហ្វាយក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទអំពីដំណឹងនេះ សម្ដេចសហជីវិនព្រះប្រមុខរដ្ឋ ទ្រង់ថ្លែងព្រះបុតហ្វាយឆ្លើយតប រួមទាំងព្រះបរមនាម នៃព្រះមាតាជាតិផង មានសេចក្ដីដូចតទៅនេះ :

ព្រះរាជាណាចក្រកម្ពុជា

លេខ ៣៤៨ SPU

សម្ដេចព្រះ នរោត្ដម សីហនុ

*សហជីវិន នាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ជាទីស្នេហា*

*សម្ដេចព្រះមហាក្សត្រិយានី និង ខ្ញុំមានចិត្តសោមនស្សឥតឧបមា នៅពេលដែលបានទទួលពត៌មានថា សហជីវិន ដោយរួមជាមួយនឹងបុគ្គលិកទាំងអស់ ទាំងព្រះសង្ឃ ទាំងគ្រហស្ថ បានប្រារព្ធធ្វើពិធីបុណ្យខួបទី ៣៧ នៃឆ្នាំកំណើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្រោមព្រះកិច្ចដឹកនាំដ៏ឧត្ដមនៃសម្ដេចព្រះពោធិវង្ស ដើម្បីឧទ្ទិសបុណ្យកុសលដល់ដួងវិញ្ញាណក្ខន្ធនៃបុព្វបុរសយើងគ្រប់រូប ដែលបានបំរើព្រះពុទ្ធសាសនា វប្បធម៌ និងអក្សរសាស្ត្រជាតិ ជាអាទិ ថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធនៃព្រះករុណាព្រះបាទ សម្ដេចព្រះ ស៊ីសុវត្ថិ-មុនីវង្ស ដែលទ្រង់សព្វព្រះរាជហឫទ័យ*

បើកពិធីសម្ពោធជាផ្លូវការនៃវិជ្ជាឋាននេះកាលពីថ្ងៃទី១២ ឧសភា ១៩៣០ ។

ដូចសហជីវិនមានប្រសាសន៍ត្រូវណាស់ ពិធីបុណ្យនេះជាសក្ខី-ភាពនៃកតញ្ញូតាធម៌ ចំពោះព្រះមហាករុណាទិគុណរបស់ព្រះមហាក្សត្រ និងបុព្វបុរស ដែលមានគុណចំពោះជាតិ - សាសនា - ព្រះរាជបល្ល័ង្ក ព្រមទាំងជាសញ្ញានៃសាមគ្គីភាព រវាងបុគ្គលិកក្នុងក្រសួងធម្មការ ដែលជាកម្លាំងយ៉ាងមាំនៃកម្ពុជរដ្ឋក្នុងសម័យនេះ និងតទៅអនាគត ។

ហេតុនេះ ខ្ញុំសូមថ្លែងសេចក្ដីអំណរគុណ និង សេចក្ដីសរសើរ ប្រកបដោយសេចក្ដីស្នេហាយ៉ាងជ្រាលជ្រៅរបស់ខ្ញុំ ប្រគេនព្រះតេជៈព្រះគុណគ្រប់ព្រះអង្គ និងជូនកូនចៅជាទីពំនឹងយ៉ាងមាំគ្រប់រូបរបស់ខ្ញុំ, សូមឲ្យបានប្រកបតែនឹងពុទ្ធពរទាំង ៤ ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។

ភ្នំពេញ ថ្ងៃទី ២៨ ឧសភា ១៩៦៧

សម្ដេចទ្រង់ឡាយព្រះហស្តលេខា : នរោត្តម - សីហនុ

បន្ទាប់ពីទ្រង់បានទទួលព្រះតង្វាយជាសៀវភៅរបស់ពុទ្ធសាសនបណ្ឌិត្យមក សម្ដេចព្រះមហាក្សត្រិយានី បរមបពិត្រ និង សម្ដេចសហជីវិនព្រះប្រមុខរដ្ឋជាអម្ចាស់ ទ្រង់ប្រោសប្រទានត្រាស់បញ្ជា អ្នកអង្គម្ចាស់ អគ្គនាយកនៃក្រសួងនានាក្នុងព្រះបរមរាជវាំង និង សហជីវិន នាយកខុទ្ទកាល័យ ថ្លែងចុតហ្មាយឆ្លើយតប ដោយមានសេចក្ដីដូចតទៅ :

អគ្គនាយក

នៃ

ក្រសួងនានាក្នុងព្រះបរមរាជវាំង

លេខ ៣៣៨ sdt

ព្រះរាជាណាចក្រកម្ពុជា

ភ្នំពេញ ថ្ងៃទី ១៦ ឧសភា ១៩៦៧

អ្នកអង្គម្ចាស់ អគ្គនាយកក្រសួងនានា នៃព្រះបរមរាជវាំង

ជំរាបសហជីវិន ឈាង-ហ៊ាបអាន នាយក វិជ្ជាឋាន

ពុទ្ធសាសនបណ្ឌិត្យ បានជ្រាប ។

សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ទ្រង់មានព្រះរាជហឫទ័យសោមនស្សណាស់ ដោយព្រះអង្គទ្រង់បានទទួលនូវសៀវភៅ ៤ ក្បាលគឺ : សៀវភៅ កាតាឡុកភាគ ២ មួយក្បាល, កាតាឡុករបស់សមាគមអ្នកនិពន្ធខ្មែរ ១ ក្បាល, ពិធីប្រចាំដប់ពីរខែ ១ ក្បាល, ភិក្ខុប្បាតិមោក្ខបាលី ១ ក្បាល ដែលសហជីវិនបានផ្ញើទៅថ្វាយតាមលិខិតលេខ ៨០៧ ពប ចុះថ្ងៃទី ៩ ឧសភា ១៩៦៧ នោះហើយ ។

សម្តេចជាម្ចាស់ ទ្រង់ត្រាស់បង្គាប់ឲ្យខ្ញុំថ្លែងជូននូវព្រះរាជអំណរគុណដ៏ជ្រាលជ្រៅ ជាទីបំផុតចំពោះសហជីវិន ។

សូមសហជីវិន ទទួលនូវសេចក្តីគាប់អានដ៏ស្មោះចំពោះ អំពីខ្ញុំ ។

ព្រះហស្តលេខា: ឈេកន្តម ភាគុល

---

ខុទ្ទកាល័យនៃសម្តេចសហជីវិន

ព្រះប្រមុខរដ្ឋ ភ្នំពេញ ថ្ងៃទី ២៤ ឧសភា ១៩៦៧

លេខ ៨៨៩ SPU

ទទួលព្រះបរមរាជឱង្ការដំកល់លើត្បូង

នាយកខុទ្ទកាល័យសម្តេចសហជីវិន ព្រះប្រមុខរដ្ឋ

ជំរាបមក សហជីវិន នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ក្រុងភ្នំពេញ ។

យោង : តាមលិខិតលេខ ៨០៦ ពប ចុះថ្ងៃទី ៩ ៥-៦៧ ។

ខ្ញុំបានទទួលកិត្តិយសដ៏ខ្ពង់ខ្ពស់ពីសម្តេចព្រះប្រមុខរដ្ឋ ទ្រង់ត្រាស់បង្គាប់ឲ្យខ្ញុំឆ្លើយតបសហជីវិនវិញថា ព្រះអង្គមានព្រះរាជហឫទ័យរីករាយសោមនស្សជាអតិបរមា ចំពោះដង្វាយជាសៀវភៅ ៦ ក្បាល ដែលវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ បានថ្វាយចំពោះព្រះអង្គ ។

សម្តេចទ្រង់ថ្លែងសរសើរយ៉ាងឱឡារិក ចំពោះក្រុមអ្នកនិពន្ធ

សៀវភៅទាំងនេះ ដែលទុកជាអត្ថប្រយោជន៍យ៉ាងសំខាន់សំរាប់ជាតិ និងកុលបុត្រ ក្នុងព្រះពុទ្ធសាសនា នៃប្រទេសយើង ។

ទីបំផុតព្រះអង្គទ្រង់សង្ឃឹមថា បុគ្គលិកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ដែលជាពន្លឺសំរាប់ត្រាលបំភ្លឺជាតិយើងនេះ នឹងបញ្ចេញឧត្តមវិជ្ជាដល់ជាតិយើងឲ្យបានចំរើនរុងរឿងទៅអនាគតជាពុំខាន ។

សូមសហជីវិនទទួលនូវសេចក្តីរាប់អាន ជាភាតរភាព អំពីខ្ញុំ ។

ហត្ថលេខា : អ៊ុង-ហ៊ុងសាង

# សកម្មភាព នៃ ពុទ្ធសាសនបណ្ឌិត្យ

## ក្នុងខែ ឧសភា ១៩៦៧

### ១-ផ្នែករដ្ឋបាល

### ក-ចលនានៃបុគ្គលិក

– សហជីវិន ពេជ-សល់ នាយការិយាល័យទំនៀមទម្លាប់បាន ច្បាប់ឈប់សំរាកដោយមានបៀវត្សចំនួន ៦ ខែ ចាប់ពីថ្ងៃទី ៦ ឧសភា ទៅហើយ (ប្រកាសក្រសួងមហាផ្ទៃលេខ ១១៥៦ ចុះថ្ងៃទី២.៥-៦៧) ។

–តាមដីកាចាត់នៃក្រសួងធម្មការលេខ ៩៨/ប ចុះថ្ងៃ ទី ១០-៥-៦៧ សហជីវិន លឹម-លានជិន និង លី-ឆាមគេង ត្រូវបានចាត់តាំងឲ្យកាន់មុខងារបន្ថែមជានាយការិយាល័យ និង ជានាយផ្នែកនៃការិយាល័យ ទំនៀមទម្លាប់ ជំនួសសហជីវិន ពេជ-សល់ ។

– តាម លិខិតក្រសួងមហាផ្ទៃលេខ ៦៧៦ ប.ក. ចុះថ្ងៃ ១០-៥-៦៧ សហជីវិន គុយ-សូត្រ អ្នកនិពន្ធផែនសេចក្ដី ថ្នាក់លេខ ៣ មាននាទីជាអ្នក កាន់ហិបចំណូល អំពីការជាវសៀវភៅ របស់ក្រសួង ត្រូវចូលនិវត្តន៍ចាប់ពីថ្ងៃទី ២១ មិថុនា ១៩៦៧ តទៅ ។

– ដើម្បីរៀបចំបុគ្គលិកជំនួស សហ. គុយ សូត្រ ដែលត្រូវចូលនិវត្តន៍នេះ តាមការសំរេចនៃកិច្ចប្រជុំការងារ ពីថ្ងៃទី ១.៣.៦៧ សហ. ខឹម-សួរ អ្នកនិពន្ធផែនសេចក្ដីថ្នាក់លេខ ៦ ធ្វើការនៅ

បណ្ណាល័យ ត្រូវចាត់ឲ្យទៅរៀនការអំពីសហជីវិនរូបនេះ តាំងពីដើមខែមេសាម្ល៉េះ, ក្រសួង នឹងធ្វើសេចក្តីសុំតែងតាំង សហ. ខឹម-សួរ នេះ ជាបេឡាធិការជំនួស សហ. គុយ-សូត្រ ទៅក្រសួងហិរញ្ញវត្ថុ ។

## ខ–លិខិតឆ្លងឆ្លើយ

ក្នុងខែឧសភានេះ វិជ្ជាឋានបានចាត់ចែងផ្ញើ និងទទួលលិខិតផ្សេង ៗ ពីគ្រប់អង្គការនានា គឺ :-

– លិខិតចូលចំនួន ១០០ ច្បាប់ ពីលេខបញ្ជី ២៣៦ ដល់ ៣៣៦ ។

– លិខិតចេញចំនួន ១៧៦ ច្បាប់ ពីលេខបញ្ជី ៧៩០ ដល់ ៦៩៩ ។

## ២–ការិយាល័យបណ្ណាល័យ

– ចំនួនអ្នកចូលមកអានក្នុងខែឧសភានេះ មាន ២៨៥ នាក់ ។

– ចំនួនអ្នកខ្ចីសៀវភៅផ្សេង ៗ យកទៅស្រាវជ្រាវនៅផ្ទះក្នុងខែឧសភា នេះ មាន ៦៧ នាក់ ។

– ក្នុងខែឧសភានេះ បណ្ណាល័យបានទទួលអំណោយជាសៀវភៅភាសាជាតិ ភាសាបរទេស ៦៤ ក្បាល និងទស្សនាវដ្តីសារុប ១៣៥ ក្បាល (គឺសៀវភៅខ្មែរ ៦ ក្បាល ជាភាសាបរទេស ៦៤ ក្បាល និងទស្សនាវដ្តីនានា ៦៥ ក្បាល) ។

មកដល់ទីងថ្ងៃ ៣១ ឧសភា នេះ បណ្ណាល័យមានសៀវភៅទាំងអស់ ៥២.២៣៤ ក្បាលហើយ ។

៣ ការិយាល័យទំនៀមទម្លាប់ :

— ក្នុងខែមេសានេះ ការិយាល័យបានទទួលឯកសារសំរាប់ប្រឡង ផ្នែកទំនៀមទម្លាប់ និងរក្សាទុក ចំនួន ៣៣ មុខ ។ រួមឯកសារប្រឡង បានទទួលរហូតមកដល់ពេលនេះមាន ៦៣ មុខហើយ ។

— មានអ្នកមកស្រាវជ្រាវ ចំនួន ៣៩ នាក់ ដែលមានជនបរទេស ១២ នាក់ផង ។

— បានឆ្លើយចំពោះសំនួរផ្សេងៗ ទាក់ទងនឹងទំនៀមទម្លាប់ខ្មែរ ដែលក្រសួងនានាផ្ញើមកសួរ បានចំនួន ៨ រឿង ។

៤-ការទទួលភ្ញៀវបរទេស :

ក្នុងខែមេសានេះ វិជ្ជាឋានបានទទួល ៖

— អ្នកនិពន្ធជាតិកាមេរូណម្នាក់ ជាភ្ញៀវរបស់សមាគមអ្នកនិពន្ធខ្មែរ ឈ្មោះលោក ហ្វេហ្សិ-ម៉ារសែល (កាលពីថ្ងៃ ២៩ មេសា ១៩៦៧ វេលាម៉ោង ៩ ព្រឹក) ។

— លោក លីង-ចាវយាន់ ជាលេខាធិការទី ២ នៃស្ថានទូតចិន ទទួលភារៈខាងវប្បធម៌ ដែលបាននាំទស្សនាវដ្ដីអក្សរសាស្ត្រ ចំនួន ៦ ក្បាល មកជាមួយអ្នកបកប្រែភាសាម្នាក់ (ថ្ងៃទី ២៩-៤-៦៧ ម៉ោង ១១ ព្រឹក) ។

៥- ពិធីបុណ្យរំលឹកខួបទី ៣៧ :

ក្រោមអធិបតីភាពនៃសម្ដេចព្រះពោធិវង្ស ហួត-តាត និង ការណែនាំរបស់ ឯ.ឧ. ទេសរដ្ឋមន្ត្រី និង សហជីវិន អនុរដ្ឋលេខាធិការក្រសួងធម្មការ វិជ្ជាឋានបានធ្វើពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន ៣៧ អង្គ ដើម្បីរំលឹកខួបទី ៣៧ នៃការបង្កើតវិជ្ជាឋាននេះ ព្រមទាំងថ្វាយព្រះរាជកុសលចំពោះព្រះវិញ្ញាណក្ខន្ធ ព្រះមហាក្សត្រដែលទ្រង់មានព្រះគុណចំពោះវប្បធម៌ជាតិ-សាសនាជាតិ ថ្វាយព្រះរាជកុសលចំពោះ សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត សម្ដេចព្រះប្រមុខរដ្ឋ ព្រះបិតាជាតិ, សម្ដេចព្រះសង្ឃរាជ, សម្ដេចព្រះសង្ឃនាយក ព្រមទាំងជូនកុសលដល់បុព្វបុរសអ្នកមានគុណចំពោះក្រសួង កាលពីថ្ងៃទី ១២ ឧសភា ១៩៦៧ ម៉ោង ៩ ព្រឹក ។

ចំពោះបុញ្ញកុសលនេះ វិជ្ជាឋានបានធ្វើបុគហ្វាយថ្វាយព្រះរាជកុសល ចំពោះសម្ដេចព្រះមហាក្សត្រិយានី លេខ ៨១៣-ពប សម្ដេចព្រះប្រមុខរដ្ឋលេខ ០១៤ ព.ប និងសម្ដេចព្រះសង្ឃរាជលេខ ៨១៥ ពប ចុះថ្ងៃ ១៣-៥-៦៧ ។

៦- ការធ្វើអំណោយសៀវភៅ និង ពិធីផាផា :

— ក្នុងខែឧសភានេះ វិជ្ជាឋានបានទទួលបង្គាប់ពីក្រសួងធម្មការ បញ្ជូនគណៈប្រតិភូមួយទៅធ្វើពិធីប្រគល់សៀវភៅចំនួន ៤៦៣ ក្បាល

ជូនឯ.ព.ប្រតិភូពជរដ្ឋាភិបាលប្រចាំបូរ៉ែកប ដើម្បីគំគល់ទុកក្នុងបណ្ណាល័យ នៃមជ្ឈមណ្ឌលយុវជនពជសង្គមនិយមខ្មែរ ( កាលពីថ្ងៃទី ២៦.៥.៦៧ ម៉ោង ៩ ព្រឹក ) ។

ក្នុងក្របខ័ណ្ឌផ្សាយនិងប្តូរវប្បធម៌ជាមួយអង្គការនានា វិជ្ជាឋានបាន:

– ធ្វើអំណោយសៀវភៅ ៣ ក្បាលទៅទីភ្នាក់ងារសារពត៌មានខ្មែរ សំរាប់ជាឯកសារខាងទំនៀមទម្លាប់ ។

– ប្រគេនព្រះតេជព្រះគុណគន្ធមុនី សេក - នាង ចំនួន ភមកើត ខ្មែរ ១២ ក្បាល ដើម្បីជាឯកសារ បង្រៀនវិជ្ជាខ្មែរ នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុពជ ។

– ជូនគណ:ប្រតិភូខាងពុទ្ធសាសនាខ្មែរ ដែលដឹកនាំដោយព្រះសិរីសម្មតិវង្ស ប៉ុណ្ណ-សុគាជ និងមានសហជីវិន អេង-សុទ្ធ ជាសមាជិក ទៅកាន់ក្រុងមូស្គូ នូវសៀវភៅ ឯកសារពុទ្ធសាសនាចំនួន ៤០ ក្បាល ។

---